# វ៉ាក់សាំងបង្ការរោគដុះឫសលើអង្គជាតិមនុស្ស (HPV)

Human papillomavirus (HPV)

## សន្លឹកព័ត៌មានសម្រាប់ឪពុកម្ដាយ

NSW Health (ក្រសួងសុខាភិបាល រដ្ឋញូវសៅវែល) ផ្ដល់ជូនវ៉ាក់សាំងដែលបានណែនាំសម្រាប់មនុស្សជំទង់ ដោយក្រុមប្រឹក្សាស្រាវជ្រាវផ្នែកសុខភាព និងវេជ្ជសាស្ត្រជាតិក្នុងកម្មវិធីចាក់វ៉ាក់សាំងនៅតាមសាលារៀន។ ត្រូវផ្ដល់ការយល់ព្រមដែលបានចុះហត្ថលេខាដោយឪពុកម្ដាយ/អាណាព្យាបាល។

ជំហានបន្ទាប់របស់អ្នក

- សូមអានសន្លឹកព័ត៌មាននេះដោយប្រុងប្រយ័ត្ន។
- ប្រសិនបើអ្នកចង់ឱ្យកូនរបស់អ្នកចាក់វ៉ាក់សាំងប្រឆាំងទល់នឹងរោគដុះឫសលើអង្គជាតិមនុស្ស (HPV) សូមបំពេញបែបបទយល់ព្រម ហើយប្រគល់បែបបទយល់ព្រមដែលបានចុះហត្ថលេខារួច ទៅឱ្យកូនរបស់អ្នកដើម្បីយកទៅសាលារៀនវិញ។
- ប្រសិនបើអ្នកមិនចង់ឱ្យកូនរបស់អ្នកចាក់វ៉ាក់សាំងប្រឆាំងនឹង HPV ទេ សូមកុំផ្ដល់ការយល់ព្រម។

### សំណួរ. តើអ្វីជារោគ **HPV** ហើយតើវាឆ្លងរាលដាលដោយរបៀបណា**?**

រោគដុះឫសលើអង្គជាតិមនុស្ស (HPV) គឺជាវីរុសដែលកើតមានទូទៅប៉ះពាល់បុរស និងស្ត្រី។ រោគ HPV ឆ្លងរាលដាលតាមរយៈការប៉ះពាល់អង្គជាតិក្នុងអំឡុងពេលរួមភេទជាមួយមនុស្សដែលមានវីរុសនេះ។ វីរុសឆ្លងតាមកន្លែងដាច់ស្បែកដ៏តូច ហើយមិនឆ្លងតាមរយៈឈាម ឬវត្ថុរាវដទៃទៀតក្នុងរាងកាយទេ។ ស្រោមអនាម័យផ្ដល់នូវកិច្ចការពារមានកម្រិត ដោយហេតុថាវាពុំបានគ្របដណ្ដប់លើស្បែកអង្គជាតិទាំងអស់ឡើយ។

មិនមែនគ្រប់ប្រភេទនៃមេរោគ HPV នឹងបង្ករោគសញ្ញានានាដែលអាចមើលឃើញនោះទេ។ មនុស្សជាច្រើនដែលឆ្លងមេរោគ HPV នឹងមិនដឹងថាខ្លួនមានមេរោគឡើយ។

ប្រភេទមេរោគ HPV មួយចំនួនអាចបង្ករោគដុះឫសនៅលើផ្នែកណាមួយនៃរាងកាយ។ នេះរួមមានតំបន់ប្រដាប់បន្តពូជ (ផ្នែកខាងក្រៅទ្វារមាស ទ្វារមាស មាត់ស្បូន លិង្គ ពងស្វាស រន្ធគូថ និងផ្នែកចន្លោះរន្ធគូថនិងទ្វារមាស)។ ជាធម្មតា រោគដុះឫសមិនមានការឈឺចាប់ទេ ប៉ុន្តែជួនកាលបណ្ដាលឱ្យរមាស់ ឬមិនស្រួល។ ប្រភេទនៃមេរោគ HPV ដែលបង្ករោគដុះឫសត្រូវបានគេហៅថា “ហានិភ័យទាប” ពីព្រោះវាមិនទាក់ទងទៅនឹងជំងឺមហារីកទេ។

ប្រភេទមេរោគ HPV ផ្សេងទៀតត្រូវបានគេហៅថា “ហានិភ័យខ្ពស់” ពីព្រោះវាអាចបណ្ដាលឱ្យកោសិកាមុនកើតជំងឺមហារីកលូតលាស់។ កោសិកាទាំងនេះអាចក្លាយទៅជាជំងឺមហារីក ប្រសិនបើទុកចោលមិនបានព្យាបាល។

មេរោគ HPV ហានិភ័យខ្ពស់ទទួលខុសត្រូវចំពោះ5ភាគរយ នៃជំងឺមហារីកទាំងអស់នៅទូទាំងពិភពលោក រួមមាន៖

- ស្ទើរតែគ្រប់ករណីនៃជំងឺមហារីកមាត់ស្បូន
- 90 ភាគរយនៃជំងឺមហារីកគូទ
- 78 ភាគរយនៃជំងឺមហារីកទ្វារមាស
- 60 ភាគរយនៃជំងឺមហារីកផ្នែកខាងក្រោយនៃបំពង់ក អណ្ដាត និង ដុំសាច់នៅខាងក្រោយបំពង់ក
- 25 ភាគរយនៃជំងឺមហារីកបបូរមាត់ទ្វារមាស
- 50 ភាគរយនៃជំងឺមហារីកប្រដាប់បន្តពូជបុរស

ការចាក់វ៉ាក់សាំងមនុស្សប្រុស នឹងការពារជំងឺមហារីក និងរោគដុះឫសលើអង្គជាតិ ហើយក៏នឹងជួយការពារស្ត្រីពីជំងឺមហារីកមាត់ស្បូនផងដែរ។

### សំណួរ. តើវ៉ាក់សាំងដំណើរការដោយរបៀបណា?

វ៉ាក់សាំងដំណើរការដោយធ្វើឱ្យប្រព័ន្ធភាពស៊ាំ ប្រយុទ្ធប្រឆាំងនឹងមេរោគជាក់លាក់មួយចំនួន។ ប្រសិនបើមនុស្សដែលបានចាក់វ៉ាក់សាំងប៉ះពាល់ជាមួយមេរោគទាំងនេះ ប្រព័ន្ធភាពស៊ាំរបស់គេអាចឆ្លើយតបបានកាន់តែប្រសិទ្ធិភាពដោយបង្ការកុំឱ្យជំងឺវិវត្ត ឬកាត់បន្ថយភាពធ្ងន់ធ្ងររបស់វាបានយ៉ាងច្រើន។

### សំណួរ. តើវ៉ាក់សាំងមួយណានឹងត្រូវបានប្រើប្រាស់?

វ៉ាក់សាំង HPV ដែលការពារប្រឆាំងទល់នឹងរោគ HPV 9 ប្រភេទ (6, 11, 16, 18, 31, 33, 45, 52 និង 58)។

### សំណួរ. តើកូនរបស់ខ្ញុំត្រូវការចាក់វ៉ាក់សាំង **HPV** ប៉ុន្មានដូស**?**

ការស្រាវជ្រាវអន្តរជាតិបង្ហាញថាការចាក់វ៉ាក់សាំង HPV មួយដូស ផ្ដល់ការការពារដូចគ្នានឹងការចាក់វ៉ាក់សាំងពីរដូស។ ផ្អែកលើភ័ស្តុតាងនេះ ក្រុមប្រឹក្សាបច្ចេកទេសអូស្ត្រាលីស្ដីពីការចាក់ថ្នាំបង្ការ (ATAGI) បានផ្ដល់អនុសាសន៍ឱ្យប្រទេសអូស្ត្រាលីផ្លាស់ប្ដូរ ទៅកាលវិភាគវ៉ាក់សាំង HPV មួយដូសវិញក្នុងឆ្នាំ2023។

ក្មេងជំទង់មួយចំនួនដែលមានប្រព័ន្ធការពាររាងកាយខ្សោយសំខាន់ ត្រូវបានណែនាំឱ្យចាក់វ៉ាក់សាំង HPV បីដូស។ កាលវិភាគចាក់វ៉ាក់សាំង 3 ដូស
តម្រូវឱ្យមានចន្លោះពេល 2 ខែរវាងដូសទី 1 និងដូសទី 2 ហើយ 4 ខែ រវាងដូសទី 2 និងដូសទី 3។

ប្រព័ន្ធការពាររាងកាយខ្សោយសំខាន់ត្រូវបានកំណត់ថា អ្នកដែលមាន៖

- កង្វះភាពស៊ាំជាបឋម ឬជាបន្ទាប់បន្សំ (កង្វះអង្គបដិបក្ខកោសិកាឈាមស B និងកង្វះកោសិកាឈាមស T ទាំងស្រុង ឬដោយអន្លើ)
- មេរោគ HIV
- មនុស្សមានជំងឺមហារីក
- ការប្តូរសរីរាង្គ
- ជំងឺស្វ័យភាពស៊ាំ
- ការព្យាបាលប្រព័ន្ធភាពស៊ាំចុះខ្សោយសំខាន់ (មិនរាប់បញ្ចូលភាពអវត្តមាននៃលំពែង ឬការអន់ថយនៃមុខងារលំពែង)។

### សំណួរ. ចុះចំណែកក្មេងជំទង់វិញដែលបានចាក់វ៉ាក់សាំងមួយដូសរួចហើយ?

សិស្សណាដែលបានចាក់វ៉ាក់សាំង HPV មួយដូសរួចហើយ គឺលែងត្រូវការដូសលើកទីពីរទៀតហើយ។ ពួកគេត្រូវបានចាត់ទុកថាបានចាក់វ៉ាក់សាំងទាន់បច្ចុប្បន្នភាពយ៉ាងពេញលេញ។

ការពិនិត្យមើលមាត់ស្បូន (ពីមុនហៅថាផែបស្មៀ) ជាទៀងទាត់នៅតែមានសារសំខាន់សម្រាប់ស្ត្រីដែលបានចាក់វ៉ាក់សាំង ដ្បិតអីវ៉ាក់សាំងបង្ការរោគ HPV មិនការពារប្រឆាំងគ្រប់ទាំងប្រភេទនៃរោគ HPV ទេ ដែលអាចបណ្តាលឱ្យកើតជំងឺមហារីកមាត់ស្បូន។ ស្ត្រីទាំងអស់ដែលមានអាយុចាប់ពី 25 ឆ្នាំឡើងទៅ ដែលធ្លាប់មានសកម្មភាពផ្លូវភេទ គួរតែបានធ្វើតេស្តពិនិត្យមើលមាត់ស្បូនរៀងរាល់ 5 ឆ្នាំម្តង ដោយមិនគិតពីស្ថានភាពនៃការចាក់វ៉ាក់សាំង HPV

### សំណួរ. តើអ្នកណាគួរចាក់វ៉ាក់សាំង?

សិស្សថ្នាក់ទី7 និងសិស្សមជ្ឈមណ្ឌលភាសាអង់គ្លេសសកម្មទាំងអស់ចាប់ពីអាយុ12ឆ្នាំ គួរតែចាក់វ៉ាក់សាំង HPV តែមួយដូសតាមកាលវិភាគ។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកអង្គភាពសុខភាពសាធារណៈក្នុងតំបន់របស់អ្នក តាមទូរសព្ទលេខ 1300 066 055។

### សំណួរ. តើអ្នកណាខ្លះមិនគួរចាក់វ៉ាក់សាំង ?

មិនគួរចាក់វ៉ាក់សាំ HPV ឱ្យមនុស្សដែល៖

- មាន ឬអាចមានផ្ទៃពោះ
- ធ្លាប់មានប្រតិកម្មទាស់អាណាហ្វីឡាក់ស៊ី បន្ទាប់ពីបានចាក់វ៉ាក់សាំងពីលើកមុន
- ធ្លាប់មានប្រតិកម្មទាស់អាណាហ្វីឡាក់ស៊ី បន្ទាប់ពីសារធាតុផ្សំបន្ថែមនៃវ៉ាក់សាំងណាមួយ (ចុះនៅទំព័រម្ខាងទៀត)។
- មានប្រវត្តិប្រតិកម្មទាស់អាណាហ្វីឡាក់ស៊ីទៅនឹងមេដំបែ (ផ្សិត)

### សំណួរ. តើវ៉ាក់សាំងមានប្រសិទ្ធិភាពយ៉ាងណាដែរ?

វ៉ាក់សាំងការពារប្រឆាំងទល់នឹងប្រភេទរោគ HPV ហានិភ័យខ្ពស់ដែលបណ្តាលឱ្យកើតជំងឺមហារីកមាត់ស្បូនច្រើនជាង 90 ភាគរយក្នុងចំណោម
ស្ត្រី ហើយក៏ការពារប្រឆាំងទល់នឹងប្រភេទរោគ HPV បន្ថែមទៀត ដែលបណ្តាលឱ្យកើតជំងឺមហារីកចំពោះបុរសផងដែរ។

ការស្រាវជ្រាវចុងក្រោយបំផុតបានបង្ហាញថា វ៉ាក់សាំងនៅតែផ្តល់កិច្ចការពារជិត 100 ភាគរយក្នុងរយៈពេលជាង 10 ឆ្នាំ បន្ទាប់ពីគេចាប់ផ្តើមប្រើវា។ ចាប់តាំងពីការណែនាំកម្មវិធីចាក់វ៉ាក់សាំង HPV ថ្នាក់ជាតិ (ក្នុងឆ្នាំ2007 សម្រាប់ស្ត្រី និងឆ្នាំ2013 សម្រាប់បុរស) ឧប្បត្តិហេតុនៃ៖

- ភាពមិនធម្មតានៃមាត់ស្បូនកម្រិតខ្ពស់ នៅក្នុងក្រុមអាយុដែលមានសិទ្ធិចាក់វ៉ាក់សាំងបានថយចុះជិត50ភាគរយ
- រោគដុះឬសនៅប្រដាប់បន្តពូជចំពោះមនុស្សវ័យក្មេង (អាយុក្រោម21 ឆ្នាំ) កាត់បន្ថយ90ភាគរយ។

ដោយសារជំងឺមហារីកមាត់ស្បូន ជាធម្មតាលូតលាស់ឡើង 10 ឆ្នាំ ឬច្រើនជាងនេះ តួនាទីរបស់វ៉ាក់សាំងក្នុងការកាត់បន្ថយជំងឺមហារីកមាត់ស្បូន នឹងមិនបានបង្ហាញឱ្យឃើញនៅពេលនេះទេ។

ឧប្បត្តិហេតុនៃជំងឺមហារីកមាត់ស្បូនបានថយចុះយ៉ាងខ្លាំង ចាប់តាំងពីកម្មវិធីពិនិត្យមាត់ស្បូនថ្នាក់ជាតិបានចាប់ផ្តើមនៅឆ្នាំ1991 ហើយកម្មវិធីវ៉ាក់សាំងវីរុសដុះឬសលើអង្គជាតិមនុស្ស (HPV) ថ្នាក់ជាតិ ត្រូវបានណែនាំក្នុងឆ្នាំ2007។

### សំណួរ. ចុះប្រសិនបើខ្ញុំពេញចិត្តនឹងរង់ចាំ រហូតទាល់តែកូនរបស់ខ្ញុំមានអាយុច្រើនជាងនេះ?

ការចាក់វ៉ាក់សាំង HPV មានប្រសិទ្ធិភាពបំផុតនៅពេលផ្តល់ឱ្យមនុស្សជំទង់មុនពេលពួកគេក្លាយជាសកម្មខាងផ្លូវភេទ។ វ៉ាក់សាំងទាំងនេះអាចផ្តល់ជូននៅសាលារៀនប៉ុណ្ណោះ ពេលណាអ្នកប្រគល់ទម្រង់បែបបទយល់ព្រមដើម ខណៈពេលដែលកូនរបស់អ្នកនៅសាលារៀន។ ប្រសិនបើអ្នកជ្រើសរើសរង់ចាំរហូតដល់កូនរបស់អ្នកមានអាយុច្រើនជាងនេះ អ្នកចាំបាច់ត្រូវធ្វើការរៀបចំជាមួយ GP របស់អ្នក ឬឱសថការីចាក់ថ្នាំបង្ការ។

ប្រសិនបើការចាក់វ៉ាក់សាំងត្រូវបានផ្តល់តាមរយៈ GP ឬឱសថការីវ៉ាក់សាំងនេះនឹងមិនគិតថ្លៃទេ ប៉ុន្តែអ្នកអាចនឹងត្រូវគេគិតថ្លៃចំពោះការពិគ្រោះយោបល់។

### សំណួរ. តើវ៉ាក់សាំង **HPV** មានផ្ទុកសារធាតុផ្សំបន្ថែមអ្វីខ្លះ**?**

វ៉ាក់សាំងមានផ្ទុកសារធាតុមេផ្សិតដំបែ aluminium adjuvant, sodium chloride, L-histidine, polysorbate និង sodium borate។ សារធាតុផ្សំបន្ថែមក្នុងបរិមាណយ៉ាងតិចបំផុត ត្រូវបានដាក់បញ្ចូលដើម្បីជួយឱ្យវ៉ាក់សាំងបំពេញមុខការរបស់វា ឬក៏ជួយកុំឱ្យវាខូច។

### សំណួរ. តើវ៉ាក់សាំងមានប្រសិទ្ធិភាពយ៉ាងណាដែរ?

វ៉ាក់សាំងដែលប្រើប្រាស់នៅក្នុងប្រទេសអូស្ត្រាលីមានសុវត្ថិភាព ហើយត្រូវតែឆ្លងកាត់ការធ្វើតេស្តសុវត្ថិភាពយ៉ាងតឹងរ៉ឹង មុនពេលត្រូវបានអនុម័តដោយរដ្ឋបាលគ្រប់គ្រងលើទំនិញទាក់ទងនឹងការព្យាបាល (TGA)។ លើសពីនេះទៀត TGA តាមដានសុវត្ថិភាពនៃវ៉ាក់សាំងនៅពេលកំពុងត្រូវបានប្រើប្រាស់។

### សំណួរ. តើការចាក់វ៉ាក់សាំងមានផលប៉ះពាល់បន្ទាប់បន្សំអ្វីខ្លះ?

ផលប៉ះពាល់បន្ទាប់បន្សំ ជាទូទៅមិនធ្ងន់ធ្ងរ ហើយតាមធម្មតាទាក់ទិននឹងការឈឺចាប់ ហើមប៉ោង និងឡើងក្រហមនៅកន្លែងចាក់ថ្នាំ។ ផលប៉ះពាល់បន្ទាប់បន្សំដែលធ្ងន់ធ្ងរកម្រកើតមានណាស់។ ឪពុកម្តាយក្នុងរដ្ឋ NSW ដែលត្រូវបានតាមដានក្នុងប៉ុន្មានថ្ងៃ បន្ទាប់ពីការចាក់វ៉ាក់សាំងHPV បានរាយការណ៍ថា តិចជាង11 ភាគរយនៃសិស្សមានផលប៉ះពាល់បន្ទាប់បន្សំស្រាល ខណៈពេលដែលមានតែ0.5ភាគរយប៉ុណ្ណោះដែលត្រូវការការថែទាំផ្នែកវេជ្ជសាស្ត្រ។ ព័ត៌មានបន្ថែមអំពីផលប៉ះពាល់បន្ទាប់បន្សំ អាចរកបាននៅក្នុងព័ត៌មានផ្នែកវេជ្ជសាស្ត្រសម្រាប់អ្នកប្រើប្រាស់ (CMI) សម្រាប់វ៉ាក់សាំងដែលអាចរកបានពីគេហទំព័រ www.health.nsw.gov.au/schoolvaccination ។ ឪពុកម្តាយដែលព្រួយបារម្ភអំពីផលប៉ះពាល់បន្ទាប់បន្សំបន្ទាប់ពីការចាក់វ៉ាក់សាំង គួរទាក់ទងមក GP របស់ពួកគេ ដែលពេលនោះវេជ្ជបណ្ឌិតគួរធ្វើរបាយការណ៍ទៅអង្គភាពសុខភាពសាធារណៈផងដែរ។

### សំណួរ. តើអ្វីជាប្រតិកម្មទាស់អាណាហ្វីឡាក់ស៊ី **(anaphylaxis)?**

អាណាហ្វីឡាក់ស៊ី គឺជាប្រតិកម្មទាស់នឹងសារធាតុយ៉ាងធ្ងន់ធ្ងរដែលអាចនាំឱ្យសន្លប់ពុំដឹងខ្លួន និងស្លាប់បាត់បង់ជីវិតទៀតផង ប្រសិនបើពុំបានព្យាបាលជាបន្ទាន់ទេ។ ការនេះកើតឡើងដោយកម្របំផុតបន្ទាប់ពីការចាក់វ៉ាក់សាំងណាមួយ។ គិលានុបដ្ឋាកចាក់វ៉ាក់សាំងនៅតាមសាលារៀន មានការហ្វឹកហ្វឺនយ៉ាងពេញលេញក្នុងការព្យាបាលប្រតិកម្មទាស់អាណាហ្វីឡាក់ស៊ី។

### សំណួរ. តើកូនស្រីរបស់ខ្ញុំនឹងនៅតែត្រូវការពិនិត្យមាត់ស្បូនឬ?

ប្រាកដណាស់។ ការពិនិត្យមាត់ស្បូន (ពីមុនហៅថាផែបស្មៀ) ជាទៀងទាត់ នៅតែមានសារសំខាន់សម្រាប់ស្ត្រីដែលបានចាក់វ៉ាក់សាំង ដ្បិតអីវ៉ាក់សាំង HPV មិនការពារប្រឆាំងគ្រប់ទាំងប្រភេទនៃរោគ HPV ទេ ដែលអាចបណ្តាលឱ្យកើតជំងឺមហារីកមាត់ស្បូន។

ស្ត្រីទាំងអស់ដែលមានអាយុចាប់ពី25ឆ្នាំឡើងទៅ ដែលធ្លាប់មានសកម្មភាពផ្លូវភេទ គួរតែបានធ្វើតេស្តពិនិត្យមើលមាត់ស្បូនរៀងរាល់5ឆ្នាំម្តង ដោយមិនគិតពីស្ថានភាពនៃការចាក់វ៉ាក់សាំង HPV របស់ពួកគេឡើយ។

### សំណួរ. ចុះប្រសិនបើកូនរបស់ខ្ញុំកើតរោគហឺត ហើយប្រើថ្នាំ **cortisone** ‘ខទីហ្សូន’ ឬ **prednisone** ‘ប្រឺននីហ្សូន’ ដោយប្រើ ‘បំពង់ហឺត’ **(puffer)?**

វ៉ាក់សាំងអាចផ្តល់ឱ្យអ្នកណាម្នាក់ដែលកើតរោគហឺត បានដោយសុវត្ថិភាព ដោយមិនគិតអំពីថ្នាំពេទ្យណាមួយដែលគេកំពុងប្រើប្រាស់ឡើយ។

### សំណួរ. តើអ្នកណាអាចយល់ព្រមលើការចាក់វ៉ាក់សាំង ហើយតើគេអាចដកចេញការយល់ព្រមបានទេ?

មានតែមាតាបិតា/អាណាព្យាបាលប៉ុណ្ណោះ អាចផ្តល់ការយល់ព្រមលើការចាក់វ៉ាក់សាំងសម្រាប់សិស្សអាយុតិចជាង១៨ឆ្នាំ។ សិស្សទាំងឡាយដែលមានអាយុ១៨ឆ្នាំ និងលើសពីនេះ អាចធ្វើការយល់ព្រមដោយខ្លួនឯងដើម្បីចាក់វ៉ាក់សាំង ហើយគួរតែបំពេញ និងចុះហត្ថលេខាលើបែបបទយល់ព្រមនៅកន្លែងណាដែលមានបង្ហាញ ‘មាតាបិតា/អាណាព្យាបាល’។ ការយល់ព្រមអាចដកចេញបាននៅពេលណាក៏បាន ដោយផ្តល់ដំណឹងជាលាយលក្ខណ៍អក្សរទៅសាលារៀន អំពីការដកចេញការយល់ព្រម ឬទូរសព្ទទៅសាលារៀនដើម្បីដកចេញការយល់ព្រម។

### សំណួរ. តើគួរចាក់វ៉ាក់សាំងដល់សិស្សស្រីដែលមាន ឬដែលគិតថាប្រហែលជាមានផ្ទៃពោះទេ?

ទេ។ សិស្សស្រីណាដែលមាន ឬដែលគិតថាប្រហែលជាមានផ្ទៃពោះ ពុំគួរចាក់វ៉ាក់សាំងទេ។ នៅថ្ងៃចាក់វ៉ាក់សាំង គិលានុបដ្ឋាកផ្នែកចាក់វ៉ាក់សាំងនឹងសួរសិស្សស្រីទាំងឡាយ ប្រសិនបើគេមាន ឬអាចមានផ្ទៃពោះ។ ប្រសិនបើសិស្សឆ្លើយទៅនឹងសំណួរនេះថាមាន នោះពុំត្រូវបានគេចាក់វ៉ាក់សាំងឱ្យឡើយ។

សិស្សនឹងត្រូវបានណែនាំឱ្យពិភាក្សាអំពីរឿងនេះជាបន្ទាន់ជាមួយឪពុកម្តាយ/អាណាព្យាបាល ហើយស្វែងរកជំនួយផ្នែកវេជ្ជសាស្ត្រ។ សិស្សក៏នឹងទទួលបានព័ត៌មានលម្អិតផងដែរ ដើម្បីទាក់ទងជាមួយសេវាកម្មបញ្ជូនបន្តសុខភាពដទៃទៀតដែលនឹងផ្តល់ដំបូន្មានការគាំទ្រ និងការណែនាំ។

### សំណួរ. តើខ្ញុំត្រូវធ្វើដូចម្តេច ប្រសិនបើកូនរបស់ខ្ញុំខកខានការចាក់វ៉ាក់សាំងដោយសារមានជំងឺ ឬអវត្តមាននៅចំថ្ងៃគិលានុបដ្ឋាកអញ្ជើញមក**?**

ប្រសិនបើការចាក់វ៉ាក់សាំង HPV ត្រូវបានខកខាននៅសាលារៀន វ៉ាក់សាំងតាមឱ្យទាន់គួរតែត្រូវបានធ្វើឡើង ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ សាលារៀនមួយចំនួននឹងរៀបចំគ្លីនិកចាក់វ៉ាក់សាំងតាមឱ្យទាន់ បើមិនដូច្នេះទេ ឪពុកម្តាយគួរទាក់ទងមកវេជ្ជបណ្ឌិតព្យាបាលរោគទូទៅ (GP) ឬឱសថការីក្នុងតំបន់របស់ពួកគេ ដើម្បីរៀបចំការចាក់វ៉ាក់សាំង។

### សំណួរ. តើខ្ញុំអាចចូលប្រើកំណត់ត្រានៃការចាក់វ៉ាក់សាំងដោយរបៀបណា?

ព័ត៌មានអំពីការចាក់វ៉ាក់សាំងរបស់កូនអ្នក នឹងត្រូវបានផ្ទុកទៅក្នុងបញ្ជីចាក់ថ្នាំបង្ការរោគអូស្ត្រាលី (AIR) ដើម្បីភ្ជាប់វាទៅនឹងប្រវត្តិនៃការចាក់ថ្នាំបង្ការរោគដែលមានស្រាប់របស់កូនអ្នក។

ឪពុកម្តាយអាចស្នើសុំច្បាប់ចម្លងនៃសេចក្តីថ្លែងអំពីប្រវត្តិចាក់ថ្នាំបង្ការរោគ AIR របស់កូនពួកគេនៅពេលណាមួយ រហូតដល់កូនរបស់ពួកគេចូលអាយុ14ឆ្នាំ ហើយសិស្សដែលមានអាយុចាប់ពី14ឆ្នាំឡើងទៅអាចស្នើសុំសេចក្តីថ្លែងអំពីប្រវត្តិចាក់ថ្នាំបង្ការដោយខ្លួនឯងដូចខាងក្រោម៖

- ដោយប្រើគណនី Medicare តាមអនឡាញ តាមរយៈ myGov my.gov.au/
- ដោយប្រើកម្មវិធី Medicare Express Plus App www.servicesaustralia.gov.au/express-plus-mobile-apps
- ទូរសព្ទទៅបណ្ដាញទូរសព្ទសាកសួរទូទៅរបស់ AIR តាមលេខ 1800 653 809.

### សំណួរ. តើមានអ្វីកើតឡើងដល់ព័ត៌មានរបស់កូនខ្ញុំ?

ព័ត៌មានដែលអ្នកផ្ដល់នៅលើទម្រង់បែបបទយល់ព្រម នឹងត្រូវបានរក្សាទុកជាសម្ងាត់យ៉ាងម៉ឺងម៉ាត់ និងជាកិច្ចការពារភាពឯកជនដែលមានចែងនៅក្នុងច្បាប់រដ្ឋ NSW និងសហព័ន្ធ (សូមអានសេចក្ដីថ្លែងអំពីឯកជនភាពដែលភ្ជាប់មកជាមួយ)។

ព័ត៌មាននេះនឹងត្រូវបានដាក់បញ្ចូលទៅក្នុងបញ្ជីចាក់ថ្នាំបង្ការរោគរបស់ NSW Health រួចមកនឹងត្រូវបានផ្ទុកទៅក្នុងបញ្ជីចាក់ថ្នាំបង្ការរោគអូស្ត្រាលី (AIR) ដើម្បីភ្ជាប់វាទៅនឹងប្រវត្តិនៃការចាក់ថ្នាំបង្ការរោគដែលមានស្រាប់របស់កូនអ្នក ហើយមើលឃើញនៅលើ MyGov។

សិស្សស្រីដែលចាក់វ៉ាក់សាំង HPV - ដោយការចុះហត្ថលេខាលើទម្រង់បែបបទយល់ព្រម បានសេចក្ដីថាអ្នកយល់ព្រមឱ្យលាតត្រដាងនូវព័ត៌មានសុខភាពរបស់កូនអ្នកសម្រាប់ការភ្ជាប់ទៅបញ្ជីកម្មវិធីជាតិលើការពិនិត្យមើលមាត់ស្បូននៅថ្ងៃអនាគត។

### សំណួរ. តើខ្ញុំអាចស្វែងរកព័ត៌មានបន្ថែមនៅកន្លែងណា អំពីការចាក់វ៉ាក់សាំងនៅសាលារៀន?

ព័ត៌មានបន្ថែមអាចទទួលយកបាន៖

- ដោយចូលមើលគេហទំព័រ NSW Health www.health.nsw.gov.au/schoolvaccination
- ដោយទាក់ទងអង្គភាពសុខភាពសាធារណៈក្នុងតំបន់របស់អ្នក តាមទូរសព្ទលេខ 1300 066 055

# Human papillomavirus (HPV) vaccine
# Parent Information Sheet

October 2023 © NSW Health. SHPN (HP NSW) 230689-1-13

## កិច្ចការដែលត្រូវធ្វើ បន្ទាប់ពីការចាក់វ៉ាក់សាំង

- សូមរក្សាទុកកំណត់ត្រានេះ ដោយហេតុថាអ្នកនឹងតម្រូវឱ្យផ្ដល់ព័ត៌មាននេះនៅពេលក្រោយទៀត។
- ព័ត៌មានអំពីការចាក់វ៉ាក់សាំងរបស់កូនអ្នក នឹងត្រូវបានផ្ទុកឡើងដោយស្វ័យប្រវត្តិទៅក្នុងបញ្ជីចាក់ថ្នាំបង្ការអូស្ត្រាលី (AIR)។ អ្នកប្រហែលជាចង់ធ្វើបច្ចុប្បន្នភាព GP របស់អ្នក ទាក់ទងនឹងកាលបរិច្ឆេទការចាក់វ៉ាក់សាំង។

## អ្វីដែលត្រូវធ្វើ ប្រសិនបើកើតមានប្រតិកម្មនៅត្រង់កន្លែងចាក់ថ្នាំ

- ដាក់ក្រណាត់សើមត្រជាក់ទៅលើកន្លែងចាក់ថ្នាំ ដើម្បីបន្ថយការឈឺចាប់។
- ផឹកថ្នាំផារ៉ាស៊ីតាម៉ុល ដើម្បីបន្ថយការឈឺចាប់។
- ផឹកវត្ថុរាវឱ្យច្រើន។

**ប្រសិនបើកូនរបស់អ្នករងទុក្ខពីប្រតិកម្មណាមួយដែលអ្នកកើតមានកង្វល់ សូមទាក់ទងជាមួយវេជ្ជបណ្ឌិតក្នុងតំបន់អ្នក។**

NSW GOVERNMENT

## កិច្ចការដែលត្រូវធ្វើ បន្ទាប់ពីការចាក់វ៉ាក់សាំង

- សូមរក្សាទុកកំណត់ត្រានេះ ដោយហេតុថាអ្នកនឹងតម្រូវឱ្យផ្ដល់ព័ត៌មាននេះនៅពេលក្រោយទៀត។
- ព័ត៌មានអំពីការចាក់វ៉ាក់សាំងរបស់កូនអ្នក នឹងត្រូវបានផ្ទុកឡើងដោយស្វ័យប្រវត្តិទៅក្នុងបញ្ជីចាក់ថ្នាំបង្ការអូស្ត្រាលី (AIR)។ អ្នកប្រហែលជាចង់ធ្វើបច្ចុប្បន្នភាព GP របស់អ្នក ទាក់ទងនឹងកាលបរិច្ឆេទការចាក់វ៉ាក់សាំង។

## អ្វីដែលត្រូវធ្វើ ប្រសិនបើកើតមានប្រតិកម្មនៅត្រង់កន្លែងចាក់ថ្នាំ

- ដាក់ក្រណាត់សើមត្រជាក់ទៅលើកន្លែងចាក់ថ្នាំ ដើម្បីបន្ថយការឈឺចាប់។
- ផឹកថ្នាំផារ៉ាស៊ីតាម៉ុល ដើម្បីបន្ថយការឈឺចាប់។
- ផឹកវត្ថុរាវឱ្យច្រើន។

**ប្រសិនបើកូនរបស់អ្នករងទុក្ខពីប្រតិកម្មណាមួយដែលអ្នកកើតមានកង្វល់ សូមទាក់ទងជាមួយវេជ្ជបណ្ឌិតក្នុងតំបន់អ្នក។**

NSW GOVERNMENT

220730-2-13

Khmer

# ការយល់ព្រមដើម្បីចាក់វ៉ាក់សាំង HPV

NSW GOVERNMENT

ត្រូវបំពេញដោយឪពុកម្ដាយ/អាណាព្យាបាល។ សូមសរសេរជា**អក្សរពុម្ព**ដោយប្រើប៊ិចពណ៌**ខ្មៅ** ឬ**ខៀវ**។

### 1. ព័ត៌មានលម្អិតរបស់សិស្ស

នាមត្រកូល

នាមខ្លួន

លេខមេឌីឃែរ __ __ / __ __ / __ __ __ __

ភេទ ☐ ប្រ ☐ ស្រ ☐ មិនជាក់លាក់/អន្តរភេទ/មិនបានបញ្ជាក់

ថ្នាក់រៀន

ឈ្មោះសាលារៀន

លេខមេឌីឃែរ __ __ __ __ 2 0 __ __ __ __ ☐ លេខនៅក្បែរឈ្មោះកូនរបស់អ្នកនៅលើប័ណ្ណមេឌីឃែរ

### 2. ស្ថានភាពជាជនជាតិដើម

☐ ទេ ☐ បាទ/ចាស ជនជាតិដើម ☐ បាទ/ចាស អ្នកកោះ Torres Strait ☐ បាទ/ចាស ទាំងជនជាតិដើម និងអ្នកកោះ Torres Strait

### 3. ព័ត៌មានលម្អិតរបស់អ្នក – ឪពុកម្ដាយ/អាណាព្យាបាល

ខ្ញុំបានអាន ហើយយល់ដឹងអំពីព័ត៌មានដែលបានផ្ដល់មកឱ្យខ្ញុំ ទាក់ទិននឹងគុណប្រយោជន៍ និងផលប៉ះពាល់បន្ទាប់បន្សំនៃវ៉ាក់សាំង HPV។

តាមរយៈនេះ ខ្ញុំផ្ដល់ការយល់ព្រមឱ្យកូនរបស់ខ្ញុំដែលមានឈ្មោះខាងលើ ដើម្បីចាក់វ៉ាក់សាំង HPV តែមួយដូស ហើយយល់ព្រមចំពោះការលាតត្រដាងព័ត៌មានសុខភាពរបស់កូនខ្ញុំ សម្រាប់ការភ្ជាប់នាពេលអនាគតទៅនឹងបញ្ជីកម្មវិធីពិនិត្យមាត់ស្បូនថ្នាក់ជាតិ។

ខ្ញុំសូមប្រកាស តាមដែលខ្ញុំដឹងជាក់ច្បាស់ថាកូនរបស់ខ្ញុំ៖

1. ពុំដែលមានប្រតិកម្មអាណាហ្វីឡាក់ទិច (ប្រតិកម្មទាស់យ៉ាងធ្ងន់ធ្ងរ) បន្ទាប់ពីចាក់វ៉ាក់សាំងណាមួយ។
2. ពុំមានប្រតិកម្មអាណាហ្វីឡាក់ទិច (ប្រតិកម្មទាស់យ៉ាងធ្ងន់ធ្ងរ) ចំពោះសមាសធាតុវ៉ាក់សាំងណាមួយ ដែលមានរាយក្នុងសន្លឹកព័ត៌មានសម្រាប់ឪពុកម្ដាយដែលបានដាក់ភ្ជាប់មកជាមួយ។
3. ពុំមានផ្ទៃពោះ។

ឈ្មោះឪពុកម្ដាយ/អាណាព្យាបាល (ឧទាហរណ៍ JOHN SMITH)

អាសយដ្ឋានផ្ទះ (ឧទាហរណ៍ 5 SMITH LANE)

តំបន់ លេខកូដតំបន់

លេខទូរសព្ទចល័ត

លេខទូរសព្ទផ្សេងទៀតដែលប្រសើរជាងគេ (រួមទាំងលេខតំបន់ ឧទាហរណ៍ 02)

ហត្ថលេខារបស់ឪពុកម្ដាយ/អាណាព្យាបាល

X

កាលបរិច្ឆេទ __ __ / __ __ / 2 0 __ __

## កំណត់ត្រានៃការចាក់វ៉ាក់សាំង HPV

✍ ត្រូវបំពេញដោយឪពុកម្ដាយ/អាណាព្យាបាល។

**ឈ្មោះសិស្ស** (ឧទាហរណ៍ JANE SMITH)

### សម្រាប់ការិយាល័យប្រើប៉ុណ្ណោះ

ដូសទី 1

**ដៃ** ឆ្វេង ស្ដាំ

ម៉ោងចាក់វ៉ាក់សាំង (24 ម៉ោង) :

លេខក្រុមថ្នាំ

ហត្ថលេខារបស់គិលានុបដ្ឋាក ✕

ថ្ងៃទី / 2 0

**កំណត់ចំណាំរបស់គិលានុបដ្ឋាក**

មូលហេតុមិនបានចាក់ថ្នាំ

- ☐ អវត្តមាន
- ☐ បដិសេធ
- ☐ មិនស្រួលខ្លួន
- ☐ ពុំមានហត្ថលេខា
- ☐ ដកចេញការយល់ព្រម
- ☐ ផ្សេងទៀត

## **ឪពុកម្ដាយ/អាណាព្យាបាល** កំណត់ត្រានៃការចាក់វ៉ាក់សាំង HPV

### កំណត់ត្រានៃការចាក់វ៉ាក់សាំង HPV

ដូសទី 1

✍ ត្រូវបំពេញដោយឪពុកម្ដាយ/អាណាព្យាបាល។

**ឈ្មោះសិស្ស** (ឧទាហរណ៍ JANE SMITH)

### សម្រាប់ការិយាល័យប្រើប៉ុណ្ណោះ

**ដៃ** ឆ្វេង ស្ដាំ

ម៉ោងចាក់វ៉ាក់សាំង (24 ម៉ោង) :

លេខក្រុមថ្នាំ

ហត្ថលេខារបស់គិលានុបដ្ឋាក ✕

កាលបរិច្ឆេទ /

គ្រាន់តែជាឧទាហរណ៍ប៉ុណ្ណោះ។ សូមបំពេញបែបបទយល់ព្រមជាភាសាអង់គ្លេស

# វ៉ាក់សាំងបង្ការរោគខាន់ស្លាក់-តេតាណូស-និងក្អកមាន់ (dTpa)

Diphtheria, tetanus and pertussis (dTpa) vaccine

NSW Health (ក្រសួងសុខាភិបាល រដ្ឋញូវសៅវែល) ផ្តល់ជូនវ៉ាក់សាំងដែលបានណែនាំសម្រាប់មនុស្សជំទង់ ដោយក្រុមប្រឹក្សាស្រាវជ្រាវផ្នែកសុខភាព និងវេជ្ជសាស្ត្រជាតិក្នុងកម្មវិធីចាក់វ៉ាក់សាំងនៅតាមសាលារៀន។ ត្រូវផ្តល់ការយល់ព្រមដែលបានចុះហត្ថលេខាដោយមាតាបិតាឬបិតា/អាណាព្យាបាល។

## វិធានការបន្ទាប់របស់អ្នក

- សូមអានសន្លឹកព័ត៌មាននេះដោយប្រុងប្រយ័ត្ន។
- ប្រសិនបើអ្នកចង់ឱ្យកូនរបស់អ្នកចាក់វ៉ាក់សាំងប្រឆាំងទល់នឹងរោគខាន់ស្លាក់-តេតាណូស-ក្អកមាន់ សូមបំពេញបែបបទយល់ព្រម ហើយប្រគល់បែបបទយល់ព្រមដែលបានចុះហត្ថលេខារួចទៅឱ្យកូនរបស់អ្នកដើម្បីយកទៅសាលារៀនវិញ។
- ប្រសិនបើអ្នកមិនចង់ឱ្យកូនរបស់អ្នកចាក់វ៉ាក់សាំងប្រឆាំងទល់នឹងរោគខាន់ស្លាក់-តេតាណូស-ក្អកមាន់ទេ សូមកុំបំពេញ ឬក៏បញ្ជូនបែបបទយល់ព្រមនេះទៅសាលារៀនវិញឱ្យសោះ។

## សំណួរ. តើអ្វីជារោគខាន់ស្លាក់-តេតាណូស-ក្អកមាន់?

រោគខាន់ស្លាក់ គឺជារោគឆ្លងបាក់តេរីដែលឆ្លងរាលដាល ហើយមានគ្រោះថ្នាក់ធ្ងន់ធ្ងរដល់ជីវិតដែលបណ្តាលឱ្យពិបាកដកដង្ហើមយ៉ាងខ្លាំង គាំងបេះដូង និងខូចសរសៃប្រសាទ។

រោគតេតាណូស គឺជាជំងឺប្រព័ន្ធសរសៃប្រសាទដ៏ធ្ងន់ធ្ងរ ជាញឹកញាប់បណ្តាលឱ្យស្លាប់។ អ្នកជំងឺរងទុក្ខដោយការកន្ត្រាក់សាច់ដុំយ៉ាងឈឺចាប់ ប្រកាច់ ហើយរឹងថ្គាមយ៉ាងធ្ងន់ធ្ងរ។ ផលវិបាកនានារួមមានជំងឺរលាកសួត បាក់ឆ្អឹង (ពីការកន្ត្រាក់សាច់ដុំ) ជំងឺខ្សោយផ្លូវដង្ហើម និងជំងឺគាំងបេះដូង។

រោគក្អកមាន់ គឺជារោគបាក់តេរីឆ្លងយ៉ាងខ្លាំង ដែលបណ្តាលឱ្យក្អកជាប់ៗគ្នាយ៉ាងខ្លាំងក្នុងមួយលើកៗ។ មនុស្សជំទង់ និងមនុស្សពេញវ័យអាចកើតរោគក្អកដែលធ្វើទុក្ខរហូតដល់ទៅ៣ខែ។ ការក្អកជាប់ៗគ្នាយ៉ាងខ្លាំងក្នុងមួយលើកៗអាចបណ្តាលឱ្យក្អួត បាក់ឆ្អឹងជំនីរ ដាច់សរសៃឈាមតូចៗ និងជំងឺខ្វិន។ មានទារកប្រហែល១នាក់ ក្នុងចំណោមទារក១២៥នាក់ដែលមានអាយុតិចជាង៦ខែ បានឆ្លងរោគក្អកមាន់ពីអ្នកមានរោគ ហើយត្រូវស្លាប់ដោយការរលាកសួត ឬខូចខួរក្បាល។

## សំណួរ. តើរោគខាន់ស្លាក់-តេតាណូស-ក្អកមាន់ឆ្លងរាលដាលដោយរបៀបណា?

បាក់តេរីនៃរោគខាន់ស្លាក់ អាចរស់នៅក្នុងមាត់ ច្រមុះ បំពង់ក ឬស្បែករបស់បុគ្គលដែលបានឆ្លងរោគ។ មនុស្សអាចឆ្លងរោគខាន់ស្លាក់ ដោយការដកដង្ហើមចូលបាក់តេរីក្រោយពេលអ្នកឆ្លងរោគបានក្អក ឬកណ្តាស់។ មនុស្សក៏អាចឆ្លងរោគខាន់ស្លាក់បានដែរ ដោយការប៉ះពាល់យ៉ាងជិតស្និទ្ធជាមួយវត្ថុរាវចេញពីមាត់ ច្រមុះ បំពង់ក ឬស្បែករបស់អ្នកឆ្លងរោគ។

រោគតេតាណូស បណ្តាលមកពីបាក់តេរីដែលគេរកឃើញនៅក្នុងដី ហើយការឆ្លងរោគអាចកើតនៅក្រោយពេលមានរបួសធ្ងន់ ឬរបួសបន្តិចបន្តួច (ជួនកាលការមុតស្បែកបន្តិចបន្តួចដែលពុំបានបានកត់សំគាល់ដែលឆ្លងរោគតាមដី ធូលី ឬលាមកសត្វ)។

រោគក្អកមាន់ អាចឆ្លងរាលដាលទៅមនុស្សឯទៀតដោយសារដំណក់តូចៗនៃវត្ថុរាវចេញមកពីការក្អក ឬកណ្តាស់។ បើពុំបានព្យាបាលទេ មនុស្សដែលមានរោគក្អកមាន់អាចឆ្លងរាលដាលរោគទៅដល់មនុស្សឯទៀត រហូតដល់៣សប្តាហ៍ក្រោយពេលចាប់ផ្តើមមានរោគក្អក។

## សំណួរ. តើវ៉ាក់សាំងដំណើរការដោយរបៀបណា?

វ៉ាក់សាំងដំណើរការដោយធ្វើឱ្យប្រព័ន្ធភាពស៊ាំ ប្រយុទ្ធប្រឆាំងនឹងមេរោគជាក់លាក់មួយចំនួន។ ប្រសិនបើមនុស្សដែលបានចាក់វ៉ាក់សាំងប៉ះពាល់ជាមួយមេរោគទាំងនេះ ប្រព័ន្ធភាពស៊ាំរបស់គេអាចឆ្លើយតបបានកាន់តែប្រសិទ្ធិភាពដោយបង្ការកុំឱ្យជំងឺវិវត្ត ឬកាត់បន្ថយភាពធ្ងន់ធ្ងររបស់វាបានយ៉ាងច្រើន។

## សំណួរ. តើវ៉ាក់សាំងមានប្រសិទ្ធិភាពយ៉ាងណាដែរ?

វ៉ាក់សាំងមានប្រសិទ្ធិភាពណាស់ក្នុងកិច្ចការពាររោគខាន់ស្លាក់ និងរោគតេតាណូស ហើយមានប្រសិទ្ធិភាពប្រហែលជា៨០ភាគរយ ក្នុងកិច្ចការពាររោគក្អកមាន់។

## សំណួរ. តើកូនរបស់ខ្ញុំចាំបាច់ត្រូវចាក់វ៉ាក់សាំងប៉ុន្មានដូសដើម្បីទទួលបានកិច្ចការពារ?

វ៉ាក់សាំង dTpa មួយដូស គឺចាំបាច់ដើម្បីផ្តល់នូវកិច្ចការពារប្រឆាំងទល់នឹងរោគខាន់ស្លាក់-តេតាណូស-ក្អកមាន់ រហូតដល់វ័យជំទង់ដំបូង។

## សំណួរ. តើអ្នកណាខ្លះគួរតែចាក់វ៉ាក់សាំង?

គ្រប់មនុស្សជំទង់គួរតែចាក់វ៉ាក់សាំង dTpa មួយដូស ដើម្បីផ្តល់កិច្ចការពារប្រឆាំងទល់នឹងរោគខាន់ស្លាក់-តេតាណូស-ក្អកមាន់។ ដូសជំរុញនេះមានសារៈសំខាន់សម្រាប់ការរក្សាភាពស៊ាំនៅក្នុងភាពវ័យជំទង់ បន្ទាប់ពីបានចាក់វ៉ាក់សាំងរោគខាន់ស្លាក់-តេតាណូស-ក្អកមាន់ពីលើកមុនក្នុងកុមារភាព។ សិស្សទាំងឡាយណាដែលបានទទួលវ៉ាក់សាំងបង្ការជំងឺខាន់ស្លាក់-តេតាណូស (ADT) ពីកាលកន្លងមក ក៏អាចទទួលវ៉ាក់សាំង dTpa ផងដែរដើម្បីការពារពួកគេប្រឆាំងទល់នឹងរោគក្អកមាន់។

## សំណួរ. តើអ្នកណាខ្លះមិនគួរចាក់វ៉ាក់សាំង?

មិនគួរចាក់វ៉ាក់សាំង dTpa ឱ្យមនុស្សដែល៖

- ធ្លាប់មានប្រតិកម្មទាស់អាណាហ្វីឡាក់ស៊ី បន្ទាប់ពីបានចាក់វ៉ាក់សាំងមួយដូសពីលើកមុន
- ធ្លាប់មានប្រតិកម្មទាស់អាណាហ្វីឡាក់ស៊ី បន្ទាប់ពីសារធាតុផ្សំបន្ថែមនៃវ៉ាក់សាំងណាមួយ (ចុះនៅទំព័រម្ខាងទៀត)។

## សំណួរ. ចុះប្រសិនបើខ្ញុំពេញចិត្តនឹងរង់ចាំ រហូតទាល់តែកូនរបស់ខ្ញុំមានអាយុច្រើនជាងនេះ?

វ៉ាក់សាំង dTpa អាចផ្តល់ជូននៅសាលារៀន ពេលណាអ្នកចុះហត្ថលេខាលើបែបបទយល់ព្រមប៉ុណ្ណោះ ខណៈពេលដែលកូនរបស់អ្នករៀននៅមជ្ឈមណ្ឌលបង្រៀនភាសាអង់គ្លេសយ៉ាងល្អិតល្អន់ ឬរៀននៅថ្នាក់ទី៧។ ប្រសិនបើអ្នកជ្រើសរើសរង់ចាំរហូតដល់កូនរបស់អ្នកមានអាយុច្រើនជាងនេះ អ្នកនឹងចាំបាច់ត្រូវធ្វើការរៀបចំជាមួយវេជ្ជបណ្ឌិតព្យាបាលរោគទូទៅរបស់អ្នក។

## សំណួរ. តើវ៉ាក់សាំងមានប្រសិទ្ធិភាពយ៉ាងណាដែរ?

វ៉ាក់សាំងដែលប្រើប្រាស់នៅក្នុងប្រទេសអូស្ត្រាលីមានសុវត្ថិភាព ហើយត្រូវតែឆ្លងកាត់ការធ្វើតេស្តសុវត្ថិភាពយ៉ាងតឹងរ៉ឹង មុនពេលត្រូវបានអនុម័តដោយរដ្ឋបាលគ្រប់គ្រងលើទំនិញទាក់ទងនឹងការព្យាបាល (TGA)។ លើសពីនេះទៀត TGA តាមដានសុវត្ថិភាពនៃវ៉ាក់សាំងនៅពេលកំពុងត្រូវបានប្រើប្រាស់។

## សំណួរ. តើវ៉ាក់សាំងមានសារធាតុផ្សំបន្ថែមអ្វីខ្លះ?

វ៉ាក់សាំងមានផ្ទុកនូវសារធាតុអាលុយមីនីញ៉ូម អ៊ីដ្រុកស៊ីល (aluminium hydroxide) និងហ្វូសស្វាត (phosphate), បរិមាណតិចតួចនៃឧស្ម័ន formaldehyde, polysorbate 80 និងគ្លាយស៊ីន (glycine) ហើយត្រូវបានដាក់ប៉ះពាល់ទៅនឹងសម្ភារៈ ដែលទទួលបានមកពីសត្វសន្តានគោក្នុងអំឡុងពេលផលិត។

## សំណួរ. តើការចាក់វ៉ាក់សាំងមានផលប៉ះពាល់បន្ទាប់បន្សំអ្វីខ្លះ?

ផលប៉ះពាល់បន្ទាប់បន្សំជាទូទៅមិនធន់ធ្ងរទេ ហើយតាមធម្មតាទាក់ទិននឹងការឡើងក្រហម ការឈឺចាប់ និងហើមប៉ោងនៅត្រង់កន្លែងចាក់ថ្នាំ ឬកើតគ្រុនក្តៅ។ ផលប៉ះពាល់បន្ទាប់បន្សំដែលធ្ងន់ធ្ងរកម្រកើតមានណាស់។ ព័ត៌មានបន្ថែមអំពីផលប៉ះពាល់បន្ទាប់បន្សំ អាចរកបាននៅក្នុងព័ត៌មានផ្នែកវេជ្ជសាស្ត្រសម្រាប់អ្នកប្រើប្រាស់ (CMI) សម្រាប់វ៉ាក់សាំង ដែលអាចរកបានពីគេហទំព័រ www.health.nsw.gov.au/schoolvaccination។ មាតាបិតាដែលព្រួយបារម្ភអំពីផលប៉ះពាល់បន្ទាប់បន្សំបន្ទាប់ពីការចាក់វ៉ាក់សាំង គួរទាក់ទងមកវេជ្ជបណ្ឌិតព្យាបាលរោគទូទៅរបស់ពួកគេ ដែលពេលនោះវេជ្ជបណ្ឌិតគួរធ្វើរបាយការណ៍ទៅអង្គភាពសុខភាពសាធារណៈផងដែរ។

## សំណួរ. តើអ្វីជាប្រតិកម្មទាស់អាណាហ្វីឡាក់ស៊ី (anaphylaxis)?

អាណាហ្វីឡាក់ស៊ី គឺជាប្រតិកម្មទាស់នឹងសារធាតុយ៉ាងធ្ងន់ធ្ងរដែលអាចនាំឱ្យសន្លប់ពុំដឹងខ្លួន និងស្លាប់បាត់បង់ជីវិតទៀតផង ប្រសិនបើពុំបានព្យាបាលជាបន្ទាន់ទេ។ **ការនេះកើតឡើង*ដោយកម្របំផុត*បន្ទាប់ពីការចាក់វ៉ាក់សាំង។** គិលានុបដ្ឋាកចាក់វ៉ាក់សាំងនៅតាមសាលារៀន មានការហ្វឹកហ្វឺនយ៉ាងពេញលេញក្នុងការព្យាបាលប្រតិកម្មទាស់អាណាហ្វីឡាក់ស៊ី។

## សំណួរ. ចុះប្រសិនបើកូនរបស់ខ្ញុំមានប្រតិកម្មធ្ងន់ធ្ងរទាស់នឹងវ៉ាក់សាំង Triple Antigen ពីមុន ឬវ៉ាក់សាំង DTP កាលពីនៅទារក?

លើកលែងតែកូនរបស់អ្នកធ្លាប់មានប្រតិកម្មទាស់ ឬមានប្រតិកម្មទាស់អាណាហ្វីឡាក់ស៊ីភ្លាមៗជាមួយវ៉ាក់សាំងពីពេលមុនមក បើពុំដូច្នោះទេ កូនរបស់អ្នកអាចចាក់វ៉ាក់សាំង dTpa បានដោយសុវត្ថិភាព។

## សំណួរ. ចុះប្រសិនបើកូនរបស់ខ្ញុំកើតរោគហឺត ហើយប្រើថ្នាំ cortisone 'ខទីហ្សូន' ឬ prednisone 'ប្រឺននីហ្សូន) ដោយប្រើ "បំពង់ហឺត" (puffer)?

វ៉ាក់សាំងបង្ការ dTpa អាចផ្តល់ឱ្យអ្នកណាម្នាក់ដែលកើតរោគហឺតបានដោយសុវត្ថិភាព ដោយមិនគិតអំពីថ្នាំពេទ្យណាមួយដែលគេកំពុងប្រើប្រាស់ឡើយ។

## សំណួរ. តើអ្នកណាអាចយល់ព្រមលើការចាក់វ៉ាក់សាំង ហើយតើគេអាចដកចេញការយល់ព្រមបានទេ?

មានតែមាតាបិតា/អាណាព្យាបាលប៉ុណ្ណោះ អាចផ្តល់ការយល់ព្រមលើការចាក់វ៉ាក់សាំងសម្រាប់សិស្សអាយុតិចជាង១៨ឆ្នាំ។ សិស្សទាំងឡាយដែលមានអាយុ ១៨ឆ្នាំ និងលើសពីនេះ អាចធ្វើការយល់ព្រមដោយខ្លួនឯងដើម្បីចាក់វ៉ាក់សាំង ហើយគួរតែបំពេញ និងចុះហត្ថលេខាលើបែបបទយល់ព្រមនៅកន្លែងណាដែលមានបង្ហាញ 'មាតាបិតា/អាណាព្យាបាល'។ ការយល់ព្រមអាចដកចេញបាននៅពេលណាក៏បាន ដោយផ្តល់ដំណឹងជាលាយលក្ខណ៍អក្សរទៅសាលារៀនអំពីការដកចេញការយល់ព្រម ឬទូរសព្ទទៅសាលារៀនដើម្បីដកចេញការយល់ព្រម។

## សំណួរ. តើគួរចាក់វ៉ាក់សាំងដល់សិស្សស្រីដែលមាន ឬដែលគិតថាប្រហែលជាមានផ្ទៃពោះទេ?

ទេ។ សិស្សស្រីណាដែលមាន ឬដែលគិតថាប្រហែលជាមានផ្ទៃពោះ ពុំគួរចាក់វ៉ាក់សាំងទេ។ នៅថ្ងៃចាក់ថ្នាំ គិលានុបដ្ឋាកផ្នែកចាក់វ៉ាក់សាំងនឹងសួរសិស្សស្រីទាំងឡាយប្រសិនបើគេមាន ឬអាចមានផ្ទៃពោះ។ ប្រសិនបើសិស្សឆ្លើយទៅនឹងសំណួរនេះថាមាន នោះពុំត្រូវបានគេចាក់វ៉ាក់សាំងឱ្យឡើយ។ សិស្សនឹងត្រូវបានណែនាំឱ្យពិភាក្សាអំពីរឿងនេះជាបន្ទាន់ ជាមួយមាតាបិតា/អាណាព្យាបាល ហើយស្វែងរកជំនួយផ្នែកវេជ្ជសាស្ត្រ។ សិស្សក៏នឹងទទួលបានព័ត៌មានលម្អិតផងដែរ ដើម្បីទាក់ទងជាមួយសេវាកម្មបញ្ជូនបន្តសុខភាពដទៃទៀតដែលនឹងផ្តល់ដំបូន្មាន ការគាំទ្រ និងការណែនាំ។

## សំណួរ. តើខ្ញុំត្រូវធ្វើដូចម្តេច ប្រសិនបើកូនរបស់ខ្ញុំខកខានការចាក់វ៉ាក់សាំងដោយសារមានជំងឺ ឬអវត្តមាននៅថ្ងៃគិលានុបដ្ឋាកអញ្ជើញមក?

អ្នកគួរទាក់ទងមកវេជ្ជបណ្ឌិតក្នុងតំបន់របស់អ្នក ហើយរៀបចំការចាក់វ៉ាក់សាំងសម្រាប់កូនរបស់អ្នក។

## សំណួរ. តើខ្ញុំអាចចូលប្រើកំណត់ត្រានៃការចាក់វ៉ាក់សាំងដោយរបៀបណា?

ព័ត៌មានអំពីការចាក់វ៉ាក់សាំងរបស់កូនអ្នក នឹងត្រូវបានផ្ទុកទៅក្នុងបញ្ជីចាក់ថ្នាំបង្ការរោគអូស្ត្រាលី (AIR) ដើម្បីភ្ជាប់វាទៅនឹងប្រវត្តិនៃការចាក់ថ្នាំបង្ការរោគដែលមានស្រាប់របស់កូនអ្នក។

មាតាបិតាអាចស្នើសុំច្បាប់ចម្លងនៃសេចក្តីថ្លែងអំពីប្រវត្តិចាក់ថ្នាំបង្ការរោគ AIR របស់កូនពួកគេនៅពេលណាមួយ រហូតដល់កូនរបស់ពួកគេមានអាយុ១៤ឆ្នាំ ហើយសិស្សដែលមានអាយុចាប់ពី១៤ឆ្នាំឡើងទៅ អាចស្នើសុំសេចក្តីថ្លែងអំពីប្រវត្តិចាក់ថ្នាំបង្ការរោគដោយខ្លួនឯងដូចខាងក្រោម៖

- ដោយប្រើគណនី Medicare តាមអនឡាញ តាមរយៈ myGov my.gov.au/
- ដោយប្រើកម្មវិធី Medicare Express Plus App www.humanservices.gov.au/individuals/subjects/express-plus-mobile-apps
- ទូរសព្ទទៅបណ្តាញទូរសព្ទសាកសួរទូទៅរបស់ AIR តាមលេខ 1800 653 809។

## សំណួរ. តើមានអ្វីកើតឡើងដល់ព័ត៌មានរបស់កូនខ្ញុំ?

ព័ត៌មានដែលអ្នកផ្តល់នៅលើបែបបទយល់ព្រម នឹងត្រូវបានរក្សាទុកជាសម្ងាត់យ៉ាងម៉ឺងម៉ាត់ និងជាកិច្ចការពារភាពឯកជនដែលមានចែងនៅក្នុងច្បាប់រដ្ឋ NSW និងសហព័ន្ធ (សូមអានសេចក្តីថ្លែងអំពីឯកជនភាពដែលភ្ជាប់មកជាមួយ)។ ព័ត៌មាននេះនឹងត្រូវបានដាក់បញ្ចូលទៅក្នុងបញ្ជីចាក់ថ្នាំបង្ការរោគរបស់ NSW Health រួចមកនឹងត្រូវបានផ្ទុកទៅក្នុងបញ្ជីចាក់ថ្នាំបង្ការរោគអូស្ត្រាលី (AIR) ដើម្បីភ្ជាប់វាទៅនឹងប្រវត្តិនៃការចាក់ថ្នាំបង្ការរោគដែលមានស្រាប់របស់កូនអ្នក ហើយមើលឃើញនៅលើ MyGov។

## សំណួរ. តើខ្ញុំអាចស្វែងរកព័ត៌មានបន្ថែមនៅកន្លែងណាអំពីការចាក់វ៉ាក់សាំងនៅសាលារៀន?

ព័ត៌មានបន្ថែមអាចទទួលយកបាន៖

- ដោយចូលមើលគេហទំព័រ NSW Health នៅត្រង់គេហទំព័រ www.health.nsw.gov.au/schoolvaccination
- ដោយទាក់ទងអង្គភាពសុខភាពសាធារណៈក្នុងតំបន់របស់អ្នក តាមទូរសព្ទលេខ 1300 066 055

September 2022 © NSW Ministry of Health. SHPN (HP NSW) 220728-1-13

Khmer

# ការយល់ព្រមដើម្បីទទួលការចាក់វ៉ាក់សាំង រោគខាន់ស្លាក់ តេតាណូស និងក្អកមាន់ (dTpa)

NSW GOVERNMENT

ត្រូវបំពេញដោយឪពុក ឬម្ដាយ/អាណាព្យាបាល។ សូមសរសេរជា**អក្សរពុម្ព**ដោយប្រើប៊ិចពណ៌**ខ្មៅ** ឬ**ខៀវ**។

## 1. ព័ត៌មានលម្អិតរបស់សិស្ស

នាមត្រកូល

នាមខ្លួន

ថ្ងៃខែឆ្នាំកំណើត ☐☐ / ☐☐ / 2 0 ☐☐

ភេទ ☐ ប្រ ☐ ស្រ ☐ មិនជាក់លាក់/អន្តរភេទ/មិនបានបញ្ជាក់

ថ្នាក់រៀន

ឈ្មោះសាលារៀន

លេខមេឌីឃែរ

☐ លេខនៅក្បែរឈ្មោះកូនរបស់អ្នកនៅលើប័ណ្ណមេឌីឃែរ

## 2. ស្ថានភាពជាជនជាតិដើម

☐ ទេ ☐ បាទ/ចាស ជនជាតិដើម ☐ បាទ/ចាស អ្នកកោះ Torres Strait ☐ បាទ/ចាស ជនជាតិដើម និងអ្នកកោះ Torres Strait

## 3. ព័ត៌មានលម្អិតរបស់អ្នក – ឪពុក ឬម្ដាយ/អាណាព្យាបាល

ខ្ញុំបានអាន ហើយយល់ដឹងអំពីព័ត៌មានដែលផ្ដល់ ទាក់ទិននឹងគុណប្រយោជន៍ និងផលប៉ះពាល់បន្ទាប់បន្សំដែលអាចកើតមានពីវ៉ាក់សាំងរោគខាន់ស្លាក់ តេតាណូស និងក្អកមាន់ (dTpa)។

តាមរយៈនេះ ខ្ញុំសូមផ្ដល់ការយល់ព្រមឱ្យកូនរបស់ខ្ញុំ ដូចមានឈ្មោះខាងលើ ទទួលការចាក់តែមួយដូសនៃវ៉ាក់សាំងរោគខាន់ស្លាក់ តេតាណូស និងក្អកមាន់ (dTpa)។

ខ្ញុំសូមប្រកាស តាមដែលខ្ញុំដឹងជាក់ច្បាស់ថាកូនរបស់ខ្ញុំ៖

1. ពុំដែលមានប្រតិកម្មអាណាហ្វីឡាក់ទិច (ប្រតិកម្មទាស់យ៉ាងធ្ងន់ធ្ងរ) បន្ទាប់ពីចាក់វ៉ាក់សាំងណាមួយឡើយ។
2. មិនមានប្រតិកម្មអាណាហ្វីឡាក់ទិច (ប្រតិកម្មទាស់យ៉ាងធ្ងន់ធ្ងរ) ចំពោះសមាសធាតុវ៉ាក់សាំងណាមួយដែលមានរាយក្នុងសន្លឹកព័ត៌មានសម្រាប់ឪពុកម្ដាយដែលដាក់ភ្ជាប់មកជាមួយទេ។
3. មិនមានផ្ទៃពោះទេ។

ឈ្មោះឪពុក ឬម្ដាយ/អាណាព្យាបាល (ឧទាហរណ៍ JOHN SMITH)

អាសយដ្ឋានផ្ទះ (ឧទាហរណ៍ 5 SMITH LANE)

តំបន់

លេខកូដប្រៃសណីយ៍

លេខទូរសព្ទចល័ត

លេខទូរសព្ទផ្សេងទៀតដែលល្អជាងគេ (មានរួមទាំងលេខតំបន់ ឧទាហរណ៍ 02)

ហត្ថលេខាឪពុក ឬម្ដាយ/អាណាព្យាបាល

✕

ថ្ងៃទី ☐☐ / ☐☐ / 2 0 ☐☐

NSW GOVERNMENT

220728-2-13

## កំណត់ត្រានៃការចាក់វ៉ាក់សាំងរោគ dTpa

✍ ត្រូវបំពេញដោយឪពុក ឬម្ដាយ/អាណាព្យាបាល

**ឈ្មោះសិស្ស** (ឧទាហរណ៍ JANE SMITH)

### សម្រាប់ការិយាល័យប្រើប៉ុណ្ណោះ

**ដៃ** ☐ ឆ្វេង ☐ ស្ដាំ

ម៉ោងចាក់វ៉ាក់សាំង (24 ម៉ោង) __ __ : __ __

លេខក្រុមវ៉ាក់សាំង

ហត្ថលេខារបស់គិលានុបដ្ឋាក ✕

ថ្ងៃទី __ __ / __ __ / 2 0 __ __

**កំណត់ចំណាំរបស់គិលានុបដ្ឋាក**

មូលហេតុមិនបានចាក់ថ្នាំ

- ☐ អវត្តមាន
- ☐ បដិសេធ
- ☐ មិនស្រួលខ្លួន
- ☐ ពុំមានហត្ថលេខា
- ☐ ដកចេញការយល់ព្រម
- ☐ ផ្សេងទៀត

# ឪពុក ឬម្ដាយ/អាណាព្យាបាល
## កំណត់ត្រានៃការចាក់វ៉ាក់សាំងរោគខាន់ស្លាក់ តេតាណូស និងក្អកមាន់ (dTpa)

## កំណត់ត្រានៃការចាក់វ៉ាក់សាំងរោគ dTpa

✍ ត្រូវបំពេញដោយឪពុក ឬម្ដាយ/អាណាព្យាបាល

**ឈ្មោះសិស្ស** (ឧទាហរណ៍ JANE SMITH)

### សម្រាប់ការិយាល័យប្រើប៉ុណ្ណោះ

**ដៃ** ☐ ឆ្វេង ☐ ស្ដាំ

ម៉ោងចាក់វ៉ាក់សាំង (24 ម៉ោង) __ __ : __ __

លេខក្រុមវ៉ាក់សាំង

ហត្ថលេខារបស់គិលានុបដ្ឋាក ✕

ថ្ងៃទី __ __ / __ __ / 2 0 __ __

### កិច្ចការដែលត្រូវធ្វើ បន្ទាប់ពីការចាក់វ៉ាក់សាំង

- សូមរក្សាទុកកំណត់ត្រានេះ ដោយហេតុថាអ្នកនឹងត្រូវបានតម្រូវឱ្យផ្ដល់ព័ត៌មាននេះនៅពេលក្រោយទៀត។
- ព័ត៌មានអំពីការចាក់វ៉ាក់សាំងរបស់កូនអ្នក នឹងត្រូវបានផ្ទុកឡើងដោយស្វ័យប្រវត្តិទៅក្នុងបញ្ជីចាក់ថ្នាំបង្ការអូស្ត្រាលី (AIR)។ អ្នកប្រហែលជាចង់ធ្វើបច្ចុប្បន្នភាព GP របស់អ្នក ទាក់ទងនឹងកាលបរិច្ឆេទការចាក់វ៉ាក់សាំង។

### អ្វីដែលត្រូវធ្វើ ប្រសិនបើកើតមានប្រតិកម្មនៅត្រង់កន្លែងចាក់ថ្នាំ

- ដាក់ក្រណាត់សើមត្រជាក់ទៅលើកន្លែងចាក់ថ្នាំ ដើម្បីបន្ថយការឈឺចាប់។
- ផឹកថ្នាំផារ៉ាស៊ីតាម៉ុល ដើម្បីបន្ថយការឈឺចាប់។
- ផឹកវត្ថុរាវឱ្យច្រើន។

**ប្រសិនបើកូនរបស់អ្នករងទុក្ខពីប្រតិកម្មណាមួយដែលអ្នកកើតមានកង្វល់ សូមទាក់ទងជាមួយវេជ្ជបណ្ឌិតក្នុងតំបន់អ្នក។**

NSW GOVERNMENT

# វ៉ាក់សាំងបង្ការរោគអុតស្វាយ (ស្អូច)

Varicella (chickenpox) vaccine

NSW Health (ក្រសួងសុខាភិបាល រដ្ឋញូវសៅវែល) ផ្តល់ជូនវ៉ាក់សាំងដែលបានណែនាំសម្រាប់មនុស្សជំទង់ ដោយក្រុមប្រឹក្សាស្រាវជ្រាវផ្នែកសុខភាព និងវេជ្ជសាស្ត្រជាតិក្នុងកម្មវិធីចាក់វ៉ាក់សាំងនៅតាមសាលារៀន។ ត្រូវផ្តល់ការយល់ព្រមដែលបានចុះហត្ថលេខាដោយមាតាបិតាឬបិតា/អាណាព្យាបាល។

## វិធានការបន្ទាប់របស់អ្នក

- សូមអានសន្លឹកព័ត៌មាននេះដោយប្រុងប្រយ័ត្ន។
- ប្រសិនបើអ្នកចង់ឱ្យកូនរបស់អ្នកចាក់វ៉ាក់សាំងប្រឆាំងទល់នឹងរោគអុតស្វាយ សូមបំពេញបែបបទយល់ព្រម ហើយប្រគល់បែបបទយល់ព្រមដែលបានចុះហត្ថលេខារួច ទៅឱ្យកូនរបស់អ្នកដើម្បីយកទៅសាលារៀនវិញ។
- ប្រសិនបើអ្នកមិនចង់ឱ្យកូនរបស់អ្នកចាក់វ៉ាក់សាំងប្រឆាំងទល់នឹងរោគអុតស្វាយទេ សូមកុំបំពេញ ឬក៏បញ្ជូនបែបបទយល់ព្រមនេះទៅសាលារៀនវិញឱ្យសោះ។

## សំណួរ. តើអ្វីជារោគអុតស្វាយ (រោគស្អូច)?

រោគស្អូចគឺជារោគឆ្លងយ៉ាងខ្លាំង បណ្តាលមកពីវីរុសដំបៅស្អូច (varicella-zoster)។ តាមធម្មតា វាជារោគអន់ខ្សោយមានរយៈពេលខ្លីក្នុងខ្លួនកុមារដែលមានសុខភាពល្អ ដោយមានរោគសញ្ញានានាដូចជាជំងឺគ្រុនក្តៅបន្តិចបន្តួច ហៀរសំបោរ ជាទូទៅមានអារម្មណ៍មិនស្រួលខ្លួន ហើយមានកន្ទួលលើស្បែកដែលក្លាយជាពងបែក។ ទោះជាយ៉ាងនេះក្តី រោគនេះមានលក្ខណៈធ្ងន់ធ្ងរជាងចំពោះមនុស្សពេញវ័យ ហើយអាចបណ្តាលឱ្យកើតជំងឺធ្ងន់ធ្ងរ និងអាចស្លាប់ទៀតផងចំពោះបុគ្គលដែលបានកាត់បន្ថយភាពស៊ាំ។ ករណីមួយក្នុងចំណោម៤០០០ករណី នឹងបាត់បង់ចលនាសាច់ដុំភ្លាមៗ (រោគប៉ះពាល់សរសៃប្រសាទខួរក្បាលធ្ងន់ធ្ងរ) ខណៈ១នាក់ ក្នុងចំណោម១០០,០០០នាក់នឹងកើតជំងឺរលាកខួរក្បាល (ជំងឺរលាកស្រោមខួរក្បាល)។ ការឆ្លងមេរោគក្នុងអំឡុងពេលមានផ្ទៃពោះ អាចបណ្តាលឱ្យទារកកើតមកមិនប្រក្រតី រួមមានស្នាមស្បែក និងពិការអវយវៈ។

## សំណួរ. តើរោគអុតស្វាយឆ្លងរាលដាលដោយរបៀបណា?

នៅពេលមានជំងឺជាដំបូង វីរុសឆ្លងតាររយៈមការក្អក។ ក្រោយមកទៀត វីរុសឆ្លងតាមរយៈការប៉ះពាល់ដោយផ្ទាល់ជាមួយវត្ថុរាវក្នុងពងបែក។ ការឆ្លងរាលដាលជាខ្លាំងដល់មនុស្សដែលពុំធ្លាប់មានរោគស្អូច ឬដែលបានចាក់ថ្នាំបង្ការរោគសោះ។ មនុស្សបានឆ្លងរោគក្នុងមួយថ្ងៃ ឬពីរថ្ងៃ មុនពេលកន្ទួលលេចឡើង (គឺថានៅក្នុងដំណាក់កាលហៀរសំបោរ) ហើយរហូតដល់ទៅប្រាំពីរថ្ងៃក្រោយមក (នៅពេលពងបែកទៅជាក្រៀម ឬក្រម៉រ)។

## សំណួរ. តើវ៉ាក់សាំងដំណើរការដោយរបៀបណា?

វ៉ាក់សាំងដំណើរការដោយធ្វើឱ្យប្រព័ន្ធភាពស៊ាំ ប្រយុទ្ធប្រឆាំងនឹងមេរោគជាក់លាក់មួយចំនួន។ ប្រសិនបើមនុស្សដែលបានចាក់វ៉ាក់សាំងប៉ះពាល់ជាមួយមេរោគទាំងនេះ ប្រព័ន្ធភាពស៊ាំរបស់គេអាចឆ្លើយតបបានកាន់តែប្រសិទ្ធិភាពដោយបង្ការកុំឱ្យជំងឺវិវត្ត ឬកាត់បន្ថយភាពធ្ងន់ធ្ងររបស់វាបានយ៉ាងច្រើន។

## សំណួរ. តើវ៉ាក់សាំងមានប្រសិទ្ធិភាពយ៉ាងណាដែរ?

វ៉ាក់សាំងបង្ការរោគអុតស្វាយតែមួយដូស មានប្រសិទ្ធភាព៨០-៨៥ភាគរយក្នុងការបង្ការរោគអុតស្វាយ ហើយមានប្រសិទ្ធិភាពយ៉ាងខ្លាំងប្រឆាំងទល់នឹងជំងឺធ្ងន់ធ្ងរ។

## សំណួរ. តើអ្នកណាខ្លះគួរតែចាក់វ៉ាក់សាំង?

សិស្សដែលមានអាយុរហូតដល់ទៅ១៤ឆ្នាំ តម្រូវការចាក់វ៉ាក់សាំងបង្ការរោគអុតស្វាយមួយដូស លុះត្រាតែពួកគេបានចាក់ថ្នាំពីលើកមុនរួចហើយ (ជាទូទៅ នៅអាយុ១៨ខែ) ឬធ្លាប់មានរោគអុតស្វាយ។ សិស្សដែលមានអាយុ១៤ឆ្នាំ និងច្រើនជាងនេះ ត្រូវការចាក់វ៉ាក់សាំងបង្ការរោគអុតស្វាយពីរដូសដែលផ្តល់ឱ្យយ៉ាងហោចណាស់១-២ខែគម្លាតពីគ្នា តាមរយៈវេជ្ជបណ្ឌិតរបស់ពួកគេ។

## សំណួរ. តើអ្នកណាខ្លះមិនគួរចាក់វ៉ាក់សាំង?

មិនគួរចាក់វ៉ាក់សាំងបង្ការរោគអុតស្វាយឱ្យមនុស្សដែល៖

- ធ្លាប់មានប្រតិកម្មទាស់អាណាហ្វីឡាក់ស៊ី បន្ទាប់ពីបានចាក់វ៉ាក់សាំងមួយដូសពីលើកមុន
- ធ្លាប់មានប្រតិកម្មទាស់អាណាហ្វីឡាក់ស៊ី បន្ទាប់ពីសារធាតុផ្សំបន្ថែមនៃវ៉ាក់សាំងណាមួយ (ចុះនៅទំព័រម្ខាងទៀត)។
- មានផ្ទៃពោះ (គួរជៀសវាងការមានផ្ទៃពោះក្នុងរយៈពេល២៨ថ្ងៃ បន្ទាប់ពីការចាក់វ៉ាក់សាំង)
- បានចាក់បញ្ចូលឈាម/ការចាក់បញ្ចូលអង្គបដិបក្ខក្នុងរយៈពេល១២ខែកន្លងទៅ។
- បានចាក់វ៉ាក់សាំងមានផ្ទុកវីរុសសកម្ម ក្នុងរយៈពេល៤សប្តាហ៍កន្លងមក (ឧទាហរណ៍ រោគកញ្ជ្រឹល ស្រឡទែន និងស្អូច), BCG (ជំងឺរបេង) ឬរោគខាន់លឿង
- មានភាពស៊ាំចុះថយ ពោលគឺ៖
  - (i) មនុស្សដែលមានរោគហេដ្ឋអាយវី/ជំងឺអេដស៍ (HIV/AIDS)
  - (ii) មនុស្សដែលដែលកំពុងទទួលការព្យាបាលដោយប្រព័ន្ធការពារភាពស៊ាំចុះខ្សោយដូសខ្ពស់ ការព្យាបាលដោយវិទ្យុសកម្មទូទៅ ឬមនុស្សដែលលេបថ្នាំ corticosteroid ដូសខ្ពស់
  - (iii) មនុស្សដែលមានប្រព័ន្ធការពាររាងកាយខ្សោយ រួមមានជំងឺមហារីកកូនកណ្តុរ ជំងឺមហារីកឈាមឬជំងឺមហារីកដែលឆ្លងរាលដាលពេញរាងកាយ។

## សំណួរ. តើអ្វីជាប្រតិកម្មទាស់អាណាហ្វីឡាក់ស៊ី (anaphylaxis)?

អាណាហ្វីឡាក់ស៊ី គឺជាប្រតិកម្មទាស់នឹងសារធាតុយ៉ាងធ្ងន់ធ្ងរដែលអាចនាំឱ្យសន្លប់ពុំដឹងខ្លួន និងស្លាប់បាត់បង់ជីវិតទៀតផង ប្រសិនបើពុំបានព្យាបាលជាបន្ទាន់ទេ។ **ការនេះកើតឡើង*ដោយកម្របំផុត*បន្ទាប់ពីការចាក់វ៉ាក់សាំណាមួយ។** គិលានុបដ្ឋាកចាក់វ៉ាក់សាំងនៅតាមសាលារៀន មានការហ្វឹកហ្វឺនយ៉ាងពេញលេញក្នុងការព្យាបាលប្រតិកម្មទាស់អាណាហ្វីឡាក់ស៊ី។

## សំណួរ. តើខ្ញុំគួរធ្វើដូចម្តេចប្រសិនបើខ្ញុំមិនមានកំណត់ត្រា ឬខ្ញុំមិនអាចចាំបានថាកូនរបស់ខ្ញុំកើតរោគអុតស្វាយ ឬបានចាក់វ៉ាក់សាំងរួចហើយ?

កូនក្មេង និងមនុស្សជំទង់អាចចាក់វ៉ាក់សាំងបង្ការរោគអុតស្វាយដោយសុវត្ថិភាព ប្រសិនបើមិនបានដឹងច្បាស់លាស់អំពីប្រវត្តិនៃការកើតរោគអុតស្វាយ ឬប្រសិនបើពុំមានភស្តុតាងបញ្ជាក់ពីការចាក់វ៉ាក់សាំងរោគអុតស្វាយពីមុនទេ។

## សំណួរ. តើវ៉ាក់សាំងបង្ការរោគអុតស្វាយ មានសារធាតុផ្សំបន្ថែមអ្វីខ្លះ?

វ៉ាក់សាំងមានផ្ទុកនូវសារធាតុជាតិស្ករក្នុងរុក្ខជាតិ ជាតិប្រូតេអ៊ីនខាប់អន្ទិលដែលបានញែកធាតុដោយទឹក (hydrolysed porcine gelatin), អ៊ុយរ៉េ (urea), ម៉ូណូសូដ្យូម គ្លូតាម៉េត (monosodium glutamate), សំណល់សារធាតុនៃកោសិកា MRC-5, បរិមាណតិចនៃនីអូមីស៊ីន (neomycin និងជាតិប្រូតេអ៊ីនសេរ៉ូមសត្វសន្តានគោ (bovine serum)។ សារធាតុផ្សំបន្ថែមក្នុងបរិមាណយ៉ាងតិចបំផុតត្រូវបានដាក់បញ្ចូល ដើម្បីជួយឱ្យថ្នាំបង្ការរោគបំពេញមុខការរបស់វា ឬក៏ជួយកុំឱ្យវាខូច។ វ៉ាក់សាំងនេះត្រូវបានដាក់ប៉ះពាល់ទៅនឹងសម្ភារៈដែលទទួលបានមកពីសត្វគោក្នុងអំឡុងពេលផលិត។

## សំណួរ. តើវ៉ាក់សាំងមានប្រសិទ្ធិភាពយ៉ាងណាដែរ?

វ៉ាក់សាំងដែលប្រើប្រាស់នៅក្នុងប្រទេសអូស្ត្រាលីមានសុវត្ថិភាព ហើយត្រូវតែឆ្លងកាត់ការធ្វើតេស្តសុវត្ថិភាពយ៉ាងតឹងរ៉ឹង មុនពេលត្រូវបានអនុម័តដោយរដ្ឋបាលគ្រប់គ្រងលើទំនិញទាក់ទងនឹងការព្យាបាល (TGA)។ លើសពីនេះទៀត TGA តាមដានសុវត្ថិភាពនៃវ៉ាក់សាំងនៅពេលកំពុងត្រូវបានប្រើប្រាស់។

## សំណួរ. តើការចាក់វ៉ាក់សាំងបង្ការរោគអុតស្វាយ មានផលប៉ះពាល់បន្ទាប់បន្សំអ្វីខ្លះ?

ផលប៉ះពាល់បន្ទាប់បន្សំជាទូទៅមិនធ្ងន់ធ្ងរទេ ហើយតាមធម្មតាទាក់ទិននឹងការកើតមានជំងឺគ្រុនក្ដៅ ឈឺក្បាល វិលមុខ ឬការឈឺចាប់ និងហើមប៉ោងនៅកន្លែងចាក់ថ្នាំ។ ប្រតិកម្មនៅកន្លែងចាក់ថ្នាំ ជាទូទៅនឹងជាឡើងវិញក្នុងរយៈពេល២-៣ថ្ងៃ។ ផលប៉ះពាល់បន្ទាប់បន្សំធ្ងន់ធ្ងរកម្រឃើញមានណាស់។ ព័ត៌មានបន្ថែមអំពីផលប៉ះពាល់បន្ទាប់បន្សំ អាចរកបាននៅក្នុងព័ត៌មានផ្នែកវេជ្ជសាស្ត្រសម្រាប់អ្នកប្រើប្រាស់ (CMI) សម្រាប់វ៉ាក់សាំង ដែលអាចរកបានពីគេហទំព័រ www.health.nsw.gov.au/schoolvaccination។ មាតាបិតាដែលព្រួយបារម្ភអំពីផលប៉ះពាល់បន្ទាប់បន្សំបន្ទាប់ពីការចាក់វ៉ាក់សាំង គួរទាក់ទងមកវេជ្ជបណ្ឌិតព្យាបាលរោគទូទៅរបស់ពួកគេ ដែលពេលនោះវេជ្ជបណ្ឌិតគួរធ្វើរបាយការណ៍ទៅអង្គភាពសុខភាពសាធារណៈផងដែរ។

## សំណួរ. តើគួរចាក់វ៉ាក់សាំងដល់សិស្សស្រីដែលមាន ឬដែលគិតថាប្រហែលជាមានផ្ទៃពោះទេ?

ទេ។ សិស្សស្រីណាដែលមាន ឬដែលគិតថាប្រហែលជាមានផ្ទៃពោះ ពុំគួរចាក់វ៉ាក់សាំងទេ។ នៅថ្ងៃចាក់ថ្នាំ គិលានុបដ្ឋាកផ្នែកចាក់វ៉ាក់សាំងនឹងសួរសិស្សស្រីទាំងឡាយប្រសិនបើគេមាន ឬអាចមានផ្ទៃពោះ។ ប្រសិនបើសិស្សឆ្លើយទៅនឹងសំណួរនេះថាមាន នោះពុំត្រូវបានគេចាក់វ៉ាក់សាំងឱ្យឡើយ។ សិស្សនឹងត្រូវបានណែនាំឱ្យពិភាក្សាអំពីរឿងនេះជាបន្ទាន់ ជាមួយមាតាបិតា/អាណាព្យាបាល ហើយស្វែងរកជំនួយផ្នែកវេជ្ជសាស្ត្រ។ សិស្សក៏នឹងទទួលបានព័ត៌មានលម្អិតផងដែរ ដើម្បីទាក់ទងជាមួយសេវាកម្មបញ្ជូនបន្តសុខភាពដទៃទៀតដែលនឹងផ្តល់ដំបូន្មាន ការគាំទ្រ និងការណែនាំ។

សិស្សស្រីទាំងឡាយណាដែលបានចាក់វ៉ាក់សាំងបង្ការរោគអុតស្វាយ មិនគួរមានផ្ទៃពោះឡើយក្នុងអំឡុងពេល២៨ថ្ងៃ បន្ទាប់ពីការចាក់វ៉ាក់សាំង។

## សំណួរ. ចុះប្រសិនបើកូនរបស់ខ្ញុំកើតរោគហឺត ហើយប្រើថ្នាំ cortisone 'ខទីហ្សូន' ឬ prednisone 'ប្រឹននីហ្សូន) ដោយប្រើ "បំពង់ហឺត" (puffer)?

វ៉ាក់សាំងបង្ការរោគអុតស្វាយ អាចផ្តល់ឱ្យអ្នកណាម្នាក់ដែលកើតរោគហឺតបានដោយសុវត្ថិភាព ដោយមិនគិតអំពីថ្នាំពេទ្យណាមួយដែលគេកំពុងប្រើប្រាស់ឡើយ។

## សំណួរ. តើខ្ញុំអាចដកចេញការយល់ព្រមបានទេ?

ការយល់ព្រមអាចដកចេញបាននៅពេលណាក៏បាន ដោយផ្តល់ដំណឹងជាលាយលក្ខណ៍អក្សរទៅសាលារៀនអំពីការដកចេញការយល់ព្រម ឬទូរសព្ទទៅសាលារៀនដើម្បីដកចេញការយល់ព្រម។

## សំណួរ. តើខ្ញុំត្រូវធ្វើដូចម្តេច ប្រសិនបើកូនរបស់ខ្ញុំខកខានការចាក់វ៉ាក់សាំងដោយសារមានជំងឺ ឬអវត្តមាននៅចំថ្ងៃគិលានុបដ្ឋាកអញ្ជើញមក?

អ្នកគួរទាក់ទងមកវេជ្ជបណ្ឌិតក្នុងតំបន់របស់អ្នក ហើយរៀបចំការចាក់វ៉ាក់សាំងសម្រាប់កូនរបស់អ្នក។

## សំណួរ. តើខ្ញុំអាចចូលប្រើកំណត់ត្រានៃការចាក់វ៉ាក់សាំងដោយរបៀបណា?

ព័ត៌មានអំពីការចាក់វ៉ាក់សាំងរបស់កូនអ្នក នឹងត្រូវបានផ្ទុកទៅក្នុងបញ្ជីចាក់ថ្នាំបង្ការរោគអូស្ត្រាលី (AIR) ដើម្បីភ្ជាប់វាទៅនឹងប្រវត្តិនៃការចាក់ថ្នាំបង្ការរោគដែលមានស្រាប់របស់កូនអ្នក។

មាតាបិតាអាចស្នើសុំច្បាប់ចម្លងនៃសេចក្តីថ្លែងអំពីប្រវត្តិចាក់ថ្នាំបង្ការរោគ AIR របស់កូនពួកគេនៅពេលណាមួយ រហូតដល់កូនរបស់ពួកគេមានអាយុ១៤ឆ្នាំ ហើយសិស្សដែលមានអាយុចាប់ពី១៤ឆ្នាំឡើងទៅ អាចស្នើសុំសេចក្តីថ្លែងអំពីប្រវត្តិចាក់ថ្នាំបង្ការរោគដោយខ្លួនឯងដូចខាងក្រោម៖

- ដោយប្រើគណនី Medicare តាមអនឡាញ តាមរយៈ myGov my.gov.au/
- ដោយប្រើកម្មវិធី Medicare Express Plus App www.humanservices.gov.au/individuals/subjects/express-plus-mobile-apps
- ទូរសព្ទទៅបណ្តាញទូរសព្ទសាកសួរទូទៅរបស់ AIR តាមលេខ 1800 653 809។

## សំណួរ. តើមានអ្វីកើតឡើងដល់ព័ត៌មានរបស់កូនខ្ញុំ?

ព័ត៌មានដែលអ្នកផ្តល់នៅលើបែបបទយល់ព្រម នឹងត្រូវបានរក្សាទុកជាសម្ងាត់យ៉ាងម៉ឺងម៉ាត់ និងជាកិច្ចការពារភាពឯកជនដែលមានចែងនៅក្នុងច្បាប់រដ្ឋ NSW និងសហព័ន្ធ (សូមអានសេចក្តីថ្លែងអំពីឯកជនភាពដែលភ្ជាប់មកជាមួយ)។ ព័ត៌មាននេះនឹងត្រូវបានដាក់បញ្ចូលទៅក្នុងបញ្ជីចាក់ថ្នាំបង្ការរោគរបស់ NSW Health រួចមកនឹងត្រូវបានផ្ទុកទៅក្នុងបញ្ជីចាក់ថ្នាំបង្ការរោគអូស្ត្រាលី (AIR) ដើម្បីភ្ជាប់វាទៅនឹងប្រវត្តិនៃការចាក់ថ្នាំបង្ការរោគដែលមានស្រាប់របស់កូនអ្នក ហើយមើលឃើញនៅលើ MyGov។

## សំណួរ. តើខ្ញុំអាចស្វែងរកព័ត៌មានបន្ថែមនៅកន្លែងណា អំពីការចាក់វ៉ាក់សាំងនៅសាលារៀន?

ព័ត៌មានបន្ថែមអាចទទួលយកបាន៖

- ដោយចូលមើលគេហទំព័រ NSW Health នៅត្រង់គេហទំព័រ www.health.nsw.gov.au/schoolvaccination
- ដោយទាក់ទងអង្គភាពសុខភាពសាធារណៈក្នុងតំបន់របស់អ្នក តាមទូរសព្ទលេខ 1300 066 055

September 2022 © NSW Ministry of Health. SHPN (HP NSW) 220733-1-13

NSW GOVERNMENT

# ការយល់ព្រមដើម្បីទទួលការចាក់វ៉ាក់សាំងរោគអុតស្វាយ (ស្អូច)

ត្រូវបំពេញដោយឪពុក ឬម្តាយ/អាណាព្យាបាល។ សូមសរសេរជា**អក្សរពុម្ព**ដោយប្រើប៊ិចពណ៌**ខ្មៅ** ឬ**ខៀវ**។

## 1. ព័ត៌មានលម្អិតរបស់សិស្ស

នាមត្រកូល

នាមខ្លួន

ថ្ងៃខែឆ្នាំកំណើត ___ / ___ / 2 0 ___

ភេទ ☐ ប្រ ☐ ស្រ ☐ មិនជាក់លាក់/អន្តរភេទ/មិនបានបញ្ជាក់

ថ្នាក់រៀន

ឈ្មោះសាលារៀន

លេខមេឌីឃែរ

☐ លេខនៅក្បែរឈ្មោះកូនរបស់អ្នកនៅលើប័ណ្ណមេឌីឃែរ

## 2. ស្ថានភាពជាជនជាតិដើម

☐ ទេ ☐ បាទ/ចាស ជនជាតិដើម ☐ បាទ/ចាស អ្នកកោះ Torres Strait ☐ បាទ/ចាស ជនជាតិដើម និងអ្នកកោះ Torres Strait

## 3. ព័ត៌មានលម្អិតរបស់អ្នក – ឪពុក ឬម្តាយ/អាណាព្យាបាល

ខ្ញុំបានអាន ហើយយល់ដឹងអំពីព័ត៌មានដែលផ្តល់ ទាក់ទិននឹងគុណប្រយោជន៍ និងផលប៉ះពាល់បន្ទាប់បន្សំដែលអាចកើតមានពីវ៉ាក់សាំងរោគអុតស្វាយ។

តាមរយៈនេះ ខ្ញុំសូមផ្តល់ការយល់ព្រមឱ្យកូនរបស់ខ្ញុំ ដូចមានឈ្មោះខាងលើ ទទួលការចាក់តែមួយដូសនៃវ៉ាក់សាំងរោគអុតស្វាយ។

ខ្ញុំសូមប្រកាស តាមដែលខ្ញុំដឹងជាក់ច្បាស់ថាកូនរបស់ខ្ញុំ៖

1. ពុំដែលមានប្រតិកម្មអាណាហ្វីឡាក់ទិច (ប្រតិកម្មទាស់យ៉ាងធ្ងន់ធ្ងរ) បន្ទាប់ពីចាក់វ៉ាក់សាំងណាមួយឡើយ។
2. មិនមានប្រតិកម្មអាណាហ្វីឡាក់ទិច (ប្រតិកម្មទាស់យ៉ាងធ្ងន់ធ្ងរ) ចំពោះសមាសធាតុវ៉ាក់សាំងណាមួយដែលមានរាយក្នុងសន្លឹកព័ត៌មានសម្រាប់ឪពុកម្តាយដែលដាក់ភ្ជាប់មកជាមួយទេ។
3. មិនមានផ្ទៃពោះទេ។

ឈ្មោះឪពុក ឬម្តាយ/អាណាព្យាបាល (ឧទាហរណ៍ JOHN SMITH)

អាសយដ្ឋានផ្ទះ (ឧទាហរណ៍ 5 SMITH LANE)

តំបន់

លេខកូដប្រៃសណីយ៍

លេខទូរសព្ទចល័ត

លេខទូរសព្ទផ្សេងទៀតដែលល្អជាងគេ (មានរួមទាំងលេខតំបន់ ឧទាហរណ៍ 02)

ហត្ថលេខាឪពុក ឬម្តាយ/អាណាព្យាបាល

✕

ថ្ងៃទី ___ / ___ / 2 0 ___

NSW GOVERNMENT

220733-2-13

# កំណត់ត្រានៃការចាក់វ៉ាក់សាំងរោគអុតស្វាយ (ស្អូច)

✍ ត្រូវបំពេញដោយឪពុក ឬម្ដាយ/អាណាព្យាបាល

**ឈ្មោះសិស្ស** (ឧទាហរណ៍ JANE SMITH)

## សម្រាប់ការិយាល័យប្រើប៉ុណ្ណោះ

**ដៃ** ☐ ឆ្វេង ☐ ស្ដាំ

ម៉ោងចាក់វ៉ាក់សាំង (24 ម៉ោង) __ __ : __ __

លេខក្រុមវ៉ាក់សាំង

ហត្ថលេខារបស់គិលានុបដ្ឋាក

ថ្ងៃទី __ __ / __ __ / 2 0 __ __

### កំណត់ចំណាំរបស់គិលានុបដ្ឋាក

មូលហេតុមិនបានចាក់ថ្នាំ

- ☐ អវត្តមាន
- ☐ បដិសេធ
- ☐ មិនស្រួលខ្លួន
- ☐ ពុំមានហត្ថលេខា
- ☐ ដកចេញការយល់ព្រម
- ☐ ផ្សេងទៀត

# **ឪពុក ឬម្ដាយ/អាណាព្យាបាល** កំណត់ត្រានៃការចាក់វ៉ាក់សាំងរោគអុតស្វាយ (ស្អូច)

## កំណត់ត្រានៃការចាក់វ៉ាក់សាំងរោគអុតស្វាយ (ស្អូច)

✍ ត្រូវបំពេញដោយឪពុក ឬម្ដាយ/អាណាព្យាបាល

**ឈ្មោះសិស្ស** (ឧទាហរណ៍ JANE SMITH)

## សម្រាប់ការិយាល័យប្រើប៉ុណ្ណោះ

**ដៃ** ☐ ឆ្វេង ☐ ស្ដាំ

ម៉ោងចាក់វ៉ាក់សាំង (24 ម៉ោង) __ __ : __ __

លេខក្រុមវ៉ាក់សាំង

ហត្ថលេខារបស់គិលានុបដ្ឋាក

✕

ថ្ងៃទី __ __ / __ __ / 2 0 __ __

## កិច្ចការដែលត្រូវធ្វើ បន្ទាប់ពីការចាក់វ៉ាក់សាំង

- សូមរក្សាទុកកំណត់ត្រានេះ ដោយហេតុថាអ្នកនឹងត្រូវបានតម្រូវឱ្យផ្ដល់ព័ត៌មាននេះនៅពេលក្រោយទៀត។
- ព័ត៌មានអំពីការចាក់វ៉ាក់សាំងរបស់កូនអ្នក នឹងត្រូវបានផ្ទុកឡើងដោយស្វ័យប្រវត្តិទៅក្នុងបញ្ជីចាក់ថ្នាំបង្ការអូស្ត្រាលី (AIR)។ អ្នកប្រហែលជាចង់ធ្វើបច្ចុប្បន្នភាព GP របស់អ្នក ទាក់ទងនឹងកាលបរិច្ឆេទការចាក់វ៉ាក់សាំង។

## អ្វីដែលត្រូវធ្វើ ប្រសិនបើកើតមានប្រតិកម្មនៅត្រង់កន្លែងចាក់ថ្នាំ

- ដាក់ក្រណាត់សើមត្រជាក់ទៅលើកន្លែងចាក់ថ្នាំ ដើម្បីបន្ថយការឈឺចាប់។
- ផឹកថ្នាំផារ៉ាស៊ីតាម៉ុល ដើម្បីបន្ថយការឈឺចាប់។
- ផឹកវត្ថុរាវឱ្យច្រើន។

**ប្រសិនបើកូនរបស់អ្នករងទុក្ខពីប្រតិកម្មណាមួយដែលអ្នកកើតមានកង្វល់ សូមទាក់ទងជាមួយវេជ្ជបណ្ឌិតក្នុងតំបន់អ្នក។**

NSW GOVERNMENT

# វ៉ាក់សាំងបង្ការជំងឺរលាកថ្លើមប្រភេទ B

Hepatitis B vaccine

NSW Health (ក្រសួងសុខាភិបាល រដ្ឋញូវសៅវែល) ផ្ដល់ជូនវ៉ាក់សាំងដែលបានណែនាំសម្រាប់មនុស្សជំទង់ ដោយក្រុមប្រឹក្សាស្រាវជ្រាវផ្នែកសុខភាព និងវេជ្ជសាស្ត្រជាតិក្នុងកម្មវិធីចាក់វ៉ាក់សាំងនៅតាមសាលារៀន។ ត្រូវផ្ដល់ការយល់ព្រមដែលបានចុះហត្ថលេខាដោយមាតាបិតាឬបិតា/អាណាព្យាបាល។

### វិធានការបន្ទាប់របស់អ្នក

- សូមអានសន្លឹកព័ត៌មាននេះដោយប្រុងប្រយ័ត្ន។
- ប្រសិនបើអ្នកចង់ឱ្យកូនរបស់អ្នកចាក់វ៉ាក់សាំងប្រឆាំងទល់នឹងជំងឺរលាកថ្លើប្រភេទ B សូមបំពេញបែបបទយល់ព្រម ហើយប្រគល់បែបបទយល់ព្រមដែលបានចុះហត្ថលេខារួច ទៅឱ្យកូនរបស់អ្នកដើម្បីយកទៅសាលារៀនវិញ។
- ប្រសិនបើអ្នកមិនចង់ឱ្យកូនរបស់អ្នកចាក់វ៉ាក់សាំងប្រឆាំងទល់នឹងជំងឺរលាកថ្លើប្រភេទ B ទេ សូមកុំបំពេញ ឬក៏បញ្ជូនបែបបទយល់ព្រមនេះទៅសាលារៀនវិញឱ្យសោះ។

## សំណួរ. តើអ្វីជាជំងឺរលាកថ្លើមប្រភេទ B?

ជំងឺរលាកថ្លើមប្រភេទ B គឺជារោគឆ្លងដោយវីរុសដែលបណ្ដាលឱ្យមានរោគសញ្ញាទាំងឡាយដូចជាជំងឺគ្រុនក្ដៅ ជំងឺខាន់លឿង ជាទូទៅមានអារម្មណ៍មិនស្រួលខ្លួន ហើយអាចនាំឱ្យមានរោគក្រិនថ្លើម ឬជំងឺមហារីកថ្លើម។ មនុស្សមួយចំនួនអាចកើតជំងឺរលាកថ្លើមប្រភេទ B ហើយពុំដឹងខ្លួនថាគេបានឆ្លងរោគឡើយ។ មនុស្សទាំងនេះអាចចម្លងរោគបានដោយពុំដឹងខ្លួន។

## សំណួរ. តើជំងឺរលាកថ្លើមប្រភេទ B ឆ្លងរាលដាលដោយរបៀបណា?

- ពីម្ដាយដែលបានឆ្លងរោគ ទៅទារករបស់គេនៅពេលសម្រាលកូន និងតាមរយៈការបំបៅដោះកូន
- ពីកូនក្មេងទៅកូនក្មេង តាមធម្មតា ឆ្លងតាមការប៉ះពាល់ដំបៅ ឬរបួសដែលបើកមុខ
- ការរួមភេទដែលពុំបានការពារសុវត្ថិភាព
- របួសដោយការរមុតម្ជុលចាក់
- ការចាក់សាក់ស្បែក ឬចោះរាងកាយដោយប្រើគ្រឿងបរិក្ខារដែលពុំបានសម្លាប់មេរោគ
- ការប្រើប្រាស់គ្រឿងបរិក្ខារចាក់ថ្នាំរួមគ្នា។

## សំណួរ. តើវ៉ាក់សាំងដំណើរការដោយរបៀបណា?

វ៉ាក់សាំងដំណើរការដោយធ្វើឱ្យប្រព័ន្ធភាពស៊ាំ ប្រយុទ្ធប្រឆាំងនឹងមេរោគជាក់លាក់មួយចំនួន។ ប្រសិនបើមនុស្សដែលបានចាក់វ៉ាក់សាំងប៉ះពាល់ជាមួយមេរោគទាំងនេះ ប្រព័ន្ធភាពស៊ាំរបស់គេអាចឆ្លើយតបបានកាន់តែប្រសិទ្ធិភាពដោយបង្ការកុំឱ្យជំងឺវិវត្ត ឬកាត់បន្ថយភាពធ្ងន់ធ្ងររបស់វាបានយ៉ាងច្រើន។

## សំណួរ. តើវ៉ាក់សាំងមានប្រសិទ្ធិភាពយ៉ាងណាដែរ?

វ៉ាក់សាំងបង្ការជំងឺរលាកថ្លើមប្រភេទ B មានប្រសិទ្ធិភាពខ្លាំងក្នុងកិច្ចការពារប្រឆាំងទល់នឹងការឆ្លងជំងឺរលាកថ្លើមប្រភេទ B។

## សំណួរ. តើការចាក់វ៉ាក់សាំងនេះតម្រូវប៉ុន្មានដូស?

នៅមជ្ឈមណ្ឌលបង្រៀនភាសាអង់គ្លេសល្បិតល្បន់ វ៉ាក់សាំងបង្ការជំងឺរលាកថ្លើមប្រភេទ B នឹងត្រូវចាក់២ដូស ការចាក់ដូសទីពីរត្រូវធ្វើនៅពេល៤ ទៅ៦ខែបន្ទាប់ពីការចាក់ដូសទីមួយ។

## សំណួរ. តើកូនរបស់ខ្ញុំនឹងបានទទួលកិច្ចការពារទប់ទល់នឹងជំងឺរលាកថ្លើមប្រភេទ B ទេ ប្រសិនបើពួកគេបានចាក់វ៉ាក់សាំងបង្ការជំងឺរលាកថ្លើមប្រភេទ B តែមួយដូសប៉ុណ្ណោះ?

ទេ។ មនុស្សជំទង់ (អាយុ១១-១៥ឆ្នាំ) ត្រូវការចាក់វ៉ាក់សាំងសម្រាប់មនុស្សពេញវ័យចំនួន២ដូស ដើម្បីទទួលបានកិច្ចការពារទប់ទល់នឹងជំងឺរលាកថ្លើមប្រភេទ B។

## សំណួរ. តើអ្នកណាខ្លះគួរតែចាក់វ៉ាក់សាំង?

សិស្សគ្រប់រូបដែលមាន**អាយុ១១-១៥ឆ្នាំ** គួរតែចាក់វ៉ាក់សាំងបង្ការជំងឺរលាកថ្លើមប្រភេទ B **សម្រាប់មនុស្សពេញវ័យចំនួន២ដូស** លើកលែងតែពួកគេធ្លាប់បានចាក់វ៉ាក់សាំងនេះរួចហើយ កាលពីពួកគេនៅទារក/កូនក្មេង។

សិស្សអាយុ**១៦ឆ្នាំ និងលើសពីនេះ**គួរតែចាក់វ៉ាក់សាំង**សម្រាប់កុមារចំនួន៣ដូស។** ការចាក់២ដូសដំបូង អាចផ្ដល់ឱ្យនៅសាលារៀន ហើយបន្ទាប់មកលិខិតមួយច្បាប់នឹងបានផ្ដល់ជូនសម្រាប់យកទៅឱ្យវេជ្ជបណ្ឌិតព្យាបាលរោគទូទៅរបស់ពួកគេ ដើម្បីបំពេញវគ្គចាក់វ៉ាក់សាំង។

## សំណួរ. តើអ្នកណាខ្លះមិនគួរចាក់វ៉ាក់សាំង?

មិនគួរចាក់វ៉ាក់សាំងបង្ការជំងឺរលាកថ្លើមប្រភេទ B ឱ្យមនុស្សដែល៖

- ធ្លាប់មានប្រតិកម្មទាស់អាណាហ្វីឡាក់ស៊ី បន្ទាប់ពីបានចាក់វ៉ាក់សាំងមួយដូសពីលើកមុន
- ធ្លាប់មានប្រតិកម្មទាស់អាណាហ្វីឡាក់ស៊ី បន្ទាប់ពីសារធាតុផ្សំបន្ថែមនៃវ៉ាក់សាំងណាមួយ
- មានផ្ទៃពោះ។

## សំណួរ. តើវ៉ាក់សាំងមានប្រសិទ្ធិភាពយ៉ាងណាដែរ?

វ៉ាក់សាំងដែលប្រើប្រាស់នៅក្នុងប្រទេសអូស្ត្រាលីមានសុវត្ថិភាព ហើយត្រូវតែឆ្លងកាត់ការធ្វើតេស្តសុវត្ថិភាពយ៉ាងតឹងរ៉ឹង មុនពេលត្រូវបានអនុម័តដោយរដ្ឋបាលគ្រប់គ្រងលើទំនិញទាក់ទងនឹងការព្យាបាល (TGA)។ លើសពីនេះទៀត TGA តាមដានសុវត្ថិភាពនៃវ៉ាក់សាំងនៅពេលកំពុងត្រូវបានប្រើប្រាស់។

## សំណួរ. តើវ៉ាក់សាំងបង្ការជំងឺរលាកថ្លើមប្រភេទ B មានសារធាតុផ្សំបន្ថែមអ្វីខ្លះ?

វ៉ាក់សាំងមានផ្ទុកនូវសារធាតុអាលុយមីនីញ៉ូម អ៊ីដ្រុកស៊ីល (aluminium hydroxide) ដើម្បីជួយឱ្យវ៉ាក់សាំងបំពេញមុខការ អាចមានជាតិប្រ៉ូតេអ៊ីនមេដំបែ(ផ្សិត) ហើយត្រូវបានដាក់ប៉ះពាល់ទៅនឹងសម្ភារៈដែលទទួលបានមកពីសត្វសន្ដានគោក្នុងអំឡុងពេលផលិត។

## សំណួរ. តើការចាក់វ៉ាក់សាំងបង្ការជំងឺរលាកថ្លើមប្រភេទ B មានផលប៉ះពាល់បន្ទាប់បន្សំអ្វីខ្លះ?

ផលប៉ះពាល់បន្ទាប់បន្សំជាទូទៅមិនធ្ងន់ធ្ងរទេ ហើយតាមធម្មតាទាក់ទិននឹងការឡើងក្រហម ការឈឺចាប់ និងហើមប៉ោងនៅត្រង់កន្លែងចាក់ថ្នាំ ឬកើតគ្រុន

ក្តៅ។ ផលប៉ះពាល់បន្ទាប់បន្សំដែលធ្ងន់ធ្ងរកម្រកើតមានណាស់។ ព័ត៌មានបន្ថែមអំពីផលប៉ះពាល់បន្ទាប់បន្សំ អាចរកបាននៅក្នុងព័ត៌មានផ្នែកវេជ្ជសាស្រ្តសម្រាប់អ្នកប្រើប្រាស់ (CMI) សម្រាប់វ៉ាក់សាំង ដែលអាចរកបានពីគេហទំព័រ www.health.nsw.gov.au/schoolvaccination។ មាតាបិតាដែលព្រួយបារម្ភអំពីផលប៉ះពាល់បន្ទាប់បន្សំបន្ទាប់ពីការចាក់វ៉ាក់សាំង គួរទាក់ទងមកវេជ្ជបណ្ឌិតព្យាបាលរោគទូទៅរបស់ពួកគេ ដែលពេលនោះវេជ្ជបណ្ឌិតគួរធ្វើរបាយការណ៍ទៅអង្គភាពសុខភាពសាធារណៈផងដែរ។

## សំណួរ. តើអ្វីជាប្រតិកម្មទាស់អាណាហ្វីឡាក់ស៊ី (anaphylaxis)?

អាណាហ្វីឡាក់ស៊ី គឺជាប្រតិកម្មទាស់នឹងសារធាតុយ៉ាងធ្ងន់ធ្ងរដែលអាចនាំឱ្យសន្លប់ពុំដឹងខ្លួន និងស្លាប់បាត់បង់ជីវិតទៀតផង ប្រសិនបើពុំបានព្យាបាលជាបន្ទាន់ទេ។ **ការនេះកើតឡើង*ដោយកម្របំផុត*បន្ទាប់ពីការចាក់វ៉ាក់សាំងណាមួយ។** គិលានុបដ្ឋាកចាក់វ៉ាក់សាំងនៅតាមសាលារៀន មានការហ្វឹកហ្វឺនយ៉ាងពេញលេញក្នុងការព្យាបាលប្រតិកម្មទាស់អាណាហ្វីឡាក់ស៊ី។

## សំណួរ. តើខ្ញុំគួរធ្វើដូចម្តេចប្រសិនបើខ្ញុំមិនមានកំណត់ត្រា ឬខ្ញុំមិនអាចចាំបានថាកូនរបស់ខ្ញុំបានចាក់វ៉ាក់សាំងបង្ការជំងឺរលាកថ្លើមប្រភេទ B រួចហើយ ឬក៏អត់?

វាមានសុវត្ថិភាពសម្រាប់កូនរបស់អ្នក ក្នុងការចាក់វ៉ាក់សាំងបង្ការជំងឺរលាកថ្លើមប្រភេទ B មួយផ្សេងទៀត។

## សំណួរ. កូនរបស់ខ្ញុំធ្លាប់បានទទួលវ៉ាក់សាំងបង្ការជំងឺ Hib។ តើការនេះការពារកូនរបស់ខ្ញុំប្រឆាំងទល់នឹងជំងឺរលាកថ្លើមប្រភេទ B ដែរឬទេ?

ទេ។ វ៉ាក់សាំងបង្ការជំងឺ Hib ការពារប្រឆាំងទល់នឹង*ជំងឺគ្រុនផ្តាសាយ Haemophilus influenzae (រោគតែងតែចេញឈាម) ប្រភេទ b* តែប៉ុណ្ណោះ ហើយសម្រាប់ចាក់ឱ្យទារកដែលមានអាយុ៦សប្តាហ៍ ៤ខែ ៦ខែ និង១៨ខែប៉ុណ្ណោះ។ វានឹងមិនការពារកូនរបស់អ្នកប្រឆាំងទល់នឹងជំងឺរលាកថ្លើមប្រភេទ B ទេ។

## សំណួរ. តើគួរចាក់វ៉ាក់សាំងដល់សិស្សស្រីដែលមាន ឬដែលគិតថាប្រហែលជាមានផ្ទៃពោះទេ?

ទេ។ សិស្សស្រីណាដែលមាន ឬដែលគិតថាប្រហែលជាមានផ្ទៃពោះ ពុំគួរចាក់វ៉ាក់សាំងទេ។ នៅថ្ងៃចាក់ថ្នាំ គិលានុបដ្ឋាកផ្នែកចាក់វ៉ាក់សាំងនឹងសួរសិស្សស្រីទាំងឡាយប្រសិនបើគេមាន ឬអាចមានផ្ទៃពោះ។ ប្រសិនបើសិស្សឆ្លើយទៅនឹងសំណួរនេះថាមាន នោះពុំត្រូវបានគេចាក់វ៉ាក់សាំងឱ្យឡើយ។ សិស្សនឹងត្រូវបានណែនាំឱ្យពិភាក្សាអំពីរឿងនេះជាបន្ទាន់ ជាមួយមាតាបិតា/អាណាព្យាបាល ហើយស្វែងរកជំនួយផ្នែកវេជ្ជសាស្ត្រ។ សិស្សក៏នឹងទទួលបានព័ត៌មានលម្អិតផងដែរ ដើម្បីទាក់ទងជាមួយសេវាកម្មបញ្ជូនបន្តសុខភាពដទៃទៀតដែលនឹងផ្តល់ដំបូន្មាន ការគាំទ្រ និងការណែនាំ។

## សំណួរ. ចុះប្រសិនបើកូនរបស់ខ្ញុំកើតរោគហឺត ហើយប្រើថ្នាំ cortisone 'ខទីហ្សូន' ឬ prednisone 'ប្រឺននីហ្សូន) ដោយប្រើ "បំពង់ហឺត" (puffer)?

វ៉ាក់សាំងបង្ការជំងឺរលាកថ្លើមប្រភេទ B អាចផ្តល់ឱ្យអ្នកណាម្នាក់ដែលកើតរោគហឺតបានដោយសុវត្ថិភាព ដោយមិនគិតអំពីថ្នាំពេទ្យណាមួយដែលគេកំពុងប្រើប្រាស់ឡើយ។

## សំណួរ. តើអ្នកណាអាចយល់ព្រមលើការចាក់វ៉ាក់សាំង ហើយតើគេអាចដកចេញការយល់ព្រមបានទេ?

មានតែមាតាបិតា/អាណាព្យាបាលប៉ុណ្ណោះ អាចផ្តល់ការយល់ព្រមលើការចាក់វ៉ាក់សាំងសម្រាប់សិស្សអាយុតិចជាង១៨ឆ្នាំ។ សិស្សទាំងឡាយដែលមានអាយុ ១៨ឆ្នាំ និងលើសពីនេះ អាចធ្វើការយល់ព្រមដោយខ្លួនឯងដើម្បីចាក់វ៉ាក់សាំង ហើយគួរតែបំពេញ និងចុះហត្ថលេខាលើបែបបទយល់ព្រមនៅកន្លែងណាដែលមានបង្ហាញ 'មាតាបិតា/អាណាព្យាបាល'។ ការយល់ព្រមអាចដកចេញបាននៅពេលណាក៏បាន ដោយផ្តល់ដំណឹងជាលាយលក្ខណ៍អក្សរទៅសាលារៀនអំពីការដកចេញការយល់ព្រម ឬទូរសព្ទទៅសាលារៀនដើម្បីដកចេញការយល់ព្រម។

## សំណួរ. តើខ្ញុំត្រូវធ្វើដូចម្តេច ប្រសិនបើកូនរបស់ខ្ញុំខកខានការចាក់វ៉ាក់សាំងដោយសារមានជំងឺ ឬអវត្តមាននៅថ្ងៃគិលានុបដ្ឋាកអញ្ជើញមក?

អ្នកគួរទាក់ទងមកវេជ្ជបណ្ឌិតក្នុងតំបន់របស់អ្នក ហើយរៀបចំការចាក់វ៉ាក់សាំងសម្រាប់កូនរបស់អ្នក។

## សំណួរ. តើខ្ញុំអាចចូលប្រើកំណត់ត្រានៃការចាក់វ៉ាក់សាំងដោយរបៀបណា?

ព័ត៌មានអំពីការចាក់វ៉ាក់សាំងរបស់កូនអ្នក នឹងត្រូវបានផ្ទុកទៅក្នុងបញ្ជីចាក់ថ្នាំបង្ការរោគអូស្ត្រាលី (AIR) ដើម្បីភ្ជាប់វាទៅនឹងប្រវត្តិនៃការចាក់ថ្នាំបង្ការរោគដែលមានស្រាប់របស់កូនអ្នក។

មាតាបិតាអាចស្នើសុំច្បាប់ចម្លងនៃសេចក្តីថ្លែងអំពីប្រវត្តិចាក់ថ្នាំបង្ការរោគ AIR របស់កូនពួកគេនៅពេលណាមួយ រហូតដល់កូនរបស់ពួកគេមានអាយុ១៤ឆ្នាំ ហើយសិស្សដែលមានអាយុចាប់ពី១៤ឆ្នាំឡើងទៅ អាចស្នើសុំសេចក្តីថ្លែងអំពីប្រវត្តិចាក់ថ្នាំបង្ការរោគដោយខ្លួនឯងដូចខាងក្រោម៖

- ដោយប្រើគណនី Medicare តាមអនឡាញ តាមរយៈ myGov my.gov.au/
- ដោយប្រើកម្មវិធី Medicare Express Plus App www.humanservices.gov.au/individuals/subjects/express-plus-mobile-apps
- ទូរសព្ទទៅបណ្តាញទូរសព្ទសាកសួរទូទៅរបស់ AIR តាមលេខ 1800 653 809។

## សំណួរ. តើមានអ្វីកើតឡើងដល់ព័ត៌មានរបស់កូនខ្ញុំ?

ព័ត៌មានដែលអ្នកផ្តល់នៅលើបែបបទយល់ព្រម នឹងត្រូវបានរក្សាទុកជាសម្ងាត់យ៉ាងម៉ឺងម៉ាត់ និងជាកិច្ចការពារភាពឯកជនដែលមានចែងនៅក្នុងច្បាប់រដ្ឋ NSW និងសហព័ន្ធ (សូមអានសេចក្តីថ្លែងអំពីឯកជនភាពដែលភ្ជាប់មកជាមួយ)។ ព័ត៌មាននេះនឹងត្រូវបានដាក់បញ្ចូលទៅក្នុងបញ្ជីចាក់ថ្នាំបង្ការរោគរបស់ NSW Health រួចមកនឹងត្រូវបានផ្ទុកទៅក្នុងបញ្ជីចាក់ថ្នាំបង្ការរោគអូស្ត្រាលី (AIR) ដើម្បីភ្ជាប់វាទៅនឹងប្រវត្តិនៃការចាក់ថ្នាំបង្ការរោគដែលមានស្រាប់របស់កូនអ្នក ហើយមើលឃើញនៅលើ MyGov។

## សំណួរ. តើខ្ញុំអាចស្វែងរកព័ត៌មានបន្ថែមនៅកន្លែងណាអំពីការចាក់វ៉ាក់សាំងនៅសាលារៀន?

ព័ត៌មានបន្ថែមអាចទទួលយកបាន៖

- ដោយចូលមើលគេហទំព័រ NSW Health នៅត្រង់គេហទំព័រ www.health.nsw.gov.au/schoolvaccination
- ដោយទាក់ទងអង្គភាពសុខភាពសាធារណៈក្នុងតំបន់របស់អ្នក តាមទូរសព្ទលេខ 1300 066 055

## កិច្ចការដែលត្រូវធ្វើ បន្ទាប់ពីការចាក់វ៉ាក់សាំង

- សូមរក្សាទុកកំណត់ត្រានេះ ដោយហេតុថាអ្នកនឹងត្រូវបានតម្រូវឱ្យផ្តល់ព័ត៌មាននេះនៅពេលក្រោយទៀត។
- ព័ត៌មានអំពីការចាក់វ៉ាក់សាំងរបស់កូនអ្នក នឹងត្រូវបានផ្ទុកឡើងដោយស្វ័យប្រវត្តិទៅក្នុងបញ្ជីចាក់ថ្នាំបង្ការអូស្ត្រាលី (AIR)។ អ្នកប្រហែលជាចង់ធ្វើបច្ចុប្បន្នភាព GP របស់អ្នក ទាក់ទងនឹងកាលបរិច្ឆេទការចាក់វ៉ាក់សាំង។

## អ្វីដែលត្រូវធ្វើ ប្រសិនបើកើតមានប្រតិកម្ម នៅត្រង់កន្លែងចាក់ថ្នាំ

- ដាក់ក្រណាត់សើមត្រជាក់ទៅលើកន្លែងចាក់ថ្នាំ ដើម្បីបន្ថយការឈឺចាប់។
- ផឹកថ្នាំផារ៉ាស៊ីតាម៉ុល ដើម្បីបន្ថយការឈឺចាប់។
- ផឹកវត្ថុរាវឱ្យច្រើន។

**ប្រសិនបើកូនរបស់អ្នករងទុក្ខពីប្រតិកម្មណាមួយដែលអ្នកកើតមានកង្វល់ សូមទាក់ទងជាមួយវេជ្ជបណ្ឌិតក្នុងតំបន់អ្នក។**

NSW GOVERNMENT

## កិច្ចការដែលត្រូវធ្វើ បន្ទាប់ពីការចាក់វ៉ាក់សាំង

- សូមរក្សាទុកកំណត់ត្រានេះ ដោយហេតុថាអ្នកនឹងត្រូវបានតម្រូវឱ្យផ្តល់ព័ត៌មាននេះនៅពេលក្រោយទៀត។
- ព័ត៌មានអំពីការចាក់វ៉ាក់សាំងរបស់កូនអ្នក នឹងត្រូវបានផ្ទុកឡើងដោយស្វ័យប្រវត្តិទៅក្នុងបញ្ជីចាក់ថ្នាំបង្ការអូស្ត្រាលី (AIR)។ អ្នកប្រហែលជាចង់ធ្វើបច្ចុប្បន្នភាព GP របស់អ្នក ទាក់ទងនឹងកាលបរិច្ឆេទការចាក់វ៉ាក់សាំង។

## អ្វីដែលត្រូវធ្វើ ប្រសិនបើកើតមានប្រតិកម្ម នៅត្រង់កន្លែងចាក់ថ្នាំ

- ដាក់ក្រណាត់សើមត្រជាក់ទៅលើកន្លែងចាក់ថ្នាំ ដើម្បីបន្ថយការឈឺចាប់។
- ផឹកថ្នាំផារ៉ាស៊ីតាម៉ុល ដើម្បីបន្ថយការឈឺចាប់។
- ផឹកវត្ថុរាវឱ្យច្រើន។

**ប្រសិនបើកូនរបស់អ្នករងទុក្ខពីប្រតិកម្មណាមួយដែលអ្នកកើតមានកង្វល់ សូមទាក់ទងជាមួយវេជ្ជបណ្ឌិតក្នុងតំបន់អ្នក។**

NSW GOVERNMENT

220729-2-13

Khmer

# ការយល់ព្រមដើម្បីទទួលការចាក់វ៉ាក់សាំងជំងឺរលាកថ្លើមជំពូក B

NSW GOVERNMENT

ត្រូវបំពេញដោយឪពុក ឬម្តាយ/អាណាព្យាបាល។ សូមសរសេរជា**អក្សរពុម្ព**ដោយប្រើប៊ិចពណ៌**ខ្មៅ** ឬ**ខៀវ**។

### 1. ព័ត៌មានលម្អិតរបស់សិស្ស

នាមត្រកូល

នាមខ្លួន

ថ្ងៃខែឆ្នាំកំណើត __ __ / __ __ / 2 0 __ __

ភេទ ☐ ប្រ ☐ ស្រ ☐ មិនជាក់លាក់/អន្តរភេទ/មិនបានបញ្ជាក់

ថ្នាក់រៀន

ឈ្មោះសាលារៀន

លេខមេឌីឃែរ

☐ លេខនៅក្បែរឈ្មោះកូនរបស់អ្នកនៅលើប័ណ្ណមេឌីឃែរ

### 2. ស្ថានភាពជាជនជាតិដើម

☐ ទេ ☐ បាទ/ចាស ជនជាតិដើម ☐ បាទ/ចាស អ្នកកោះ Torres Strait ☐ បាទ/ចាស ជនជាតិដើម និងអ្នកកោះ Torres Strait

### 3. ព័ត៌មានលម្អិតរបស់អ្នក – ឪពុក ឬម្តាយ/អាណាព្យាបាល

ខ្ញុំបានអាន ហើយយល់ដឹងអំពីព័ត៌មានដែលផ្តល់ ទាក់ទិននឹងគុណប្រយោជន៍ និងផលប៉ះពាល់បន្ទាប់បន្សំដែលអាចកើតមានពីវ៉ាក់សាំងជំងឺរលាកថ្លើមជំពូក B។

តាមរយៈនេះ ខ្ញុំសូមផ្តល់ការយល់ព្រមឱ្យកូនរបស់ខ្ញុំ ដូចមានឈ្មោះខាងលើ ទទួលការចាក់ថ្នាំពីរដូសនៃវ៉ាក់សាំងជំងឺរលាកថ្លើមជំពូក B។

ខ្ញុំសូមប្រកាស តាមដែលខ្ញុំដឹងជាក់ច្បាស់ថាកូនរបស់ខ្ញុំ៖

1. ពុំដែលមានប្រតិកម្មអាណាហ្វីឡាក់ទិច (ប្រតិកម្មទាស់យ៉ាងធ្ងន់ធ្ងរ) បន្ទាប់ពីចាក់វ៉ាក់សាំងណាមួយឡើយ។
2. មិនមានប្រតិកម្មអាណាហ្វីឡាក់ទិច (ប្រតិកម្មទាស់យ៉ាងធ្ងន់ធ្ងរ) ចំពោះសមាសធាតុវ៉ាក់សាំងណាមួយដែលមានរាយក្នុងសន្លឹកព័ត៌មានសម្រាប់ឪពុកម្តាយដែលដាក់ភ្ជាប់មកជាមួយទេ។
3. មិនមានផ្ទៃពោះទេ។

ឈ្មោះឪពុក ឬម្តាយ/អាណាព្យាបាល (ឧទាហរណ៍JOHN SMITH)

អាសយដ្ឋានផ្ទះ (ឧទាហរណ៍5 SMITH LANE)

តំបន់

លេខកូដប្រៃសណីយ៍

លេខទូរសព្ទចល័ត

លេខទូរសព្ទផ្សេងទៀតដែលល្អជាងគេ (មានរួមទាំងលេខតំបន់ ឧទាហរណ៍ 02)

ហត្ថលេខាឪពុក ឬម្តាយ/អាណាព្យាបាល

ថ្ងៃទី __ __ / __ __ / 2 0 __ __

## កំណត់ត្រានៃការចាក់វ៉ាក់សាំង ជំងឺរលាកថ្លើមជំពូក B

✍ ត្រូវបំពេញដោយឪពុក ឬម្ដាយ/អាណាព្យាបាល

**ឈ្មោះសិស្ស** (ឧទាហរណ៍ JANE SMITH)

### សម្រាប់ការិយាល័យប្រើប៉ុណ្ណោះ

ដូសទី 1

ដៃ ☐ ឆ្វេង ☐ ស្ដាំ

ម៉ោងចាក់វ៉ាក់សាំង (24 ម៉ោង) __ __ : __ __

លេខក្រុមវ៉ាក់សាំង

ហត្ថលេខារបស់គិលានុបដ្ឋាក

×

ថ្ងៃទី __ __ / __ __ 2 0 __ __

ដូសទី 2

ដៃ ☐ ឆ្វេង ☐ ស្ដាំ

ម៉ោងចាក់វ៉ាក់សាំង (24 ម៉ោង) __ __ : __ __

លេខក្រុមវ៉ាក់សាំង

ហត្ថលេខារបស់គិលានុបដ្ឋាក

×

ថ្ងៃទី __ __ / __ __ 2 0 __ __

### កំណត់ចំណាំរបស់គិលានុបដ្ឋាក

មូលហេតុមិនបានចាក់ថ្នាំ

- ☐ អវត្តមាន
- ☐ បដិសេធ
- ☐ មិនស្រួលខ្លួន
- ☐ ពុំមានហត្ថលេខា
- ☐ ដកចេញការយល់ព្រម
- ☐ ផ្សេងទៀត

## **ឪពុក ឬម្ដាយ/អាណាព្យាបាល** កំណត់ត្រានៃការចាក់វ៉ាក់សាំងជំងឺរលាកថ្លើមជំពូក B

### កំណត់ត្រានៃការចាក់វ៉ាក់សាំងជំងឺរលាកថ្លើមជំពូក B — ដូសទី 1

✍ ត្រូវបំពេញដោយឪពុក ឬម្ដាយ/អាណាព្យាបាល

**ឈ្មោះសិស្ស** (ឧទាហរណ៍ JANE SMITH)

សម្រាប់ការិយាល័យប្រើប៉ុណ្ណោះ

ដៃ ☐ ឆ្វេង ☐ ស្ដាំ

ម៉ោងចាក់វ៉ាក់សាំង (24 ម៉ោង) __ __ : __ __

លេខក្រុមវ៉ាក់សាំង

ហត្ថលេខារបស់គិលានុបដ្ឋាក

×

ថ្ងៃទី __ __ / __ __ 2 0 __ __

### កំណត់ត្រានៃការចាក់វ៉ាក់សាំងជំងឺរលាកថ្លើមជំពូក B — ដូសទី 2

✍ ត្រូវបំពេញដោយឪពុក ឬម្ដាយ/អាណាព្យាបាល

**ឈ្មោះសិស្ស** (ឧទាហរណ៍ JANE SMITH)

សម្រាប់ការិយាល័យប្រើប៉ុណ្ណោះ

ដៃ ☐ ឆ្វេង ☐ ស្ដាំ

ម៉ោងចាក់វ៉ាក់សាំង (24 ម៉ោង) __ __ : __ __

លេខក្រុមវ៉ាក់សាំង

ហត្ថលេខារបស់គិលានុបដ្ឋាក

×

ថ្ងៃទី __ __ / __ __ 2 0 __ __

# វ៉ាក់សាំងបង្ការរោគកញ្ជ្រឹល ស្រឡទែន និងស្អូច

Measles, mumps and rubella (MMR) vaccine

NSW Health (ក្រសួងសុខាភិបាល រដ្ឋញូវសៅវែល) ផ្តល់ជូនវ៉ាក់សាំងដែលបានណែនាំសម្រាប់មនុស្សជំទង់ ដោយក្រុមប្រឹក្សាស្រាវជ្រាវផ្នែកសុខភាព និងវេជ្ជសាស្ត្រជាតិក្នុងកម្មវិធីចាក់វ៉ាក់សាំងនៅតាមសាលារៀន។ ត្រូវផ្តល់ការយល់ព្រមដែលបានចុះហត្ថលេខាដោយមាតាបិតាឬបិតា/អាណាព្យាបាល។

## វិធានការបន្ទាប់របស់អ្នក

- សូមអានសន្លឹកព័ត៌មាននេះដោយប្រុងប្រយ័ត្ន។
- ប្រសិនបើអ្នកចង់ឱ្យកូនរបស់អ្នកចាក់វ៉ាក់សាំងប្រឆាំងទល់នឹងរោគកញ្ជ្រឹល ស្រឡទែន និងស្អូច សូមបំពេញបែបបទយល់ព្រម ហើយប្រគល់បែបបទយល់ព្រមដែលបានចុះហត្ថលេខារួច ទៅឱ្យកូនរបស់អ្នកដើម្បីយកទៅសាលារៀនវិញ។
- ប្រសិនបើអ្នកមិនចង់ឱ្យកូនរបស់អ្នកចាក់វ៉ាក់សាំងប្រឆាំងទល់នឹងរោគកញ្ជ្រឹល ស្រឡទែន និងស្អូចទេ សូមកុំបំពេញ ឬក៏បញ្ជូនបែបបទយល់ព្រមនេះទៅសាលារៀនវិញឱ្យសោះ។

## សំណួរ. តើអ្វីជារោគកញ្ជ្រឹល ស្រឡទែន និងស្អូច?

**រោគកញ្ជ្រឹល**គឺជាវីរុសឆ្លងយ៉ាងខ្លាំង ដែលបណ្តាលឱ្យកើតជំងឺគ្រុនក្តៅ ក្អក និងកន្ទួល។ ភាពស្មុគស្មាញជាញឹកញាប់រួមមានជំងឺរលាកសួត រោគចុះរាគ និងជំងឺប៉ៅត្រចៀកកណ្តាល។ រោគរលាកខួរក្បាលកើតឡើងប្រហែល១ករណីក្នុងចំណោម១០០០ករណី ហើយ១០-១៥ភាគរយនៃករណីទាំងនេះនឹងស្លាប់ ហើយមនុស្សជាច្រើននឹងខូចខួរក្បាលជាអចិន្ត្រៃយ៍។

**រោគស្រឡទែន**គឺជារោគឆ្លងដែលបណ្តាលឱ្យហើមក រលាកក្រពេញទឹកមាត់ និងជំងឺគ្រុនក្តៅ។ ប្រហែលជា១០ភាគរយនៃអ្នកដែលឆ្លងរោគនេះនឹងកើតរោគរលាកភ្នាសជុំវិញខួរក្បាល និងខួរឆ្អឹងខ្នង (សញ្ញា និងរោគសញ្ញានៃការកើតជំងឺរលាកស្រោមខួរក្បាល) ខណៈពេលដែលបុរសពី១៥ ទៅ៣០ភាគរយឈានដល់ភាពពេញវ័យ កើតរោគរលាកពងស្វាស (ជំងឺរលាកពងអង្គជាតិបុរស) ។ ការឆ្លងរោគស្រឡទែនក្នុងអំឡុងពេលមានផ្ទៃពោះត្រីមាសដំបូង អាចបណ្តាលឱ្យមានការរំលូតកូនដោយឯកឯង។

**រោគស្អូច** (រោគកញ្ជ្រឹលអាល្លឺម៉ង់) គឺជាវីរុសឆ្លងយ៉ាងខ្លាំងបណ្តាលឱ្យកើតមានកន្ទួល ជំងឺគ្រុនក្តៅ និងហើមក្រពេញទឹកមាត់។ វាបណ្តាលឱ្យទារកនៃស្ត្រីមានផ្ទៃពោះដែលបានឆ្លងរោគ កើតមកមានភាពខុសពីប្រក្រតីដ៏ធ្ងន់ធ្ងរ។ ទារករហូតដល់ទៅ៩០ភាគរយដែលឆ្លងរោគនេះ ក្នុងអំឡុងពេលមានផ្ទៃពោះបីខែដំបូង នឹងមានកំណើតខុសប្លែកពីធម្មតាយ៉ាងធ្ងន់ធ្ងរ រួមមានពិការភាពខាងបញ្ញា ថ្លង់ ខ្វាក់ភ្នែក ឬខូចបេះដូង។

## សំណួរ. តើរោគកញ្ជ្រឹល ស្រឡទែន និងស្អូច ឆ្លងរាលដាលដោយរបៀបណា?

វីរុសទាំងនេះឆ្លងតាមរយៈការក្អក និងកណ្តាស់។ កញ្ជ្រឹលគឺជារោគឆ្លងមួយដែលងាយឆ្លងបំផុតក្នុងចំណោមការឆ្លងមនុស្សទាំងអស់។ ការគ្រាន់តែបាននៅក្នុងបន្ទប់ជាមួយអ្នកណាម្នាក់ដែលមានរោគកញ្ជ្រឹល ក៏អាចនាំឱ្យឆ្លងរោគដែរ។

## សំណួរ. តើវ៉ាក់សាំងដំណើរការដោយរបៀបណា?

វ៉ាក់សាំងដំណើរការដោយធ្វើឱ្យប្រព័ន្ធភាពស៊ាំ ប្រយុទ្ធប្រឆាំងនឹងមេរោគជាក់លាក់មួយចំនួន។ ប្រសិនបើមនុស្សដែលបានចាក់វ៉ាក់សាំងប៉ះពាល់ជាមួយមេរោគទាំងនេះ ប្រព័ន្ធភាពស៊ាំរបស់គេអាចឆ្លើយតបបានកាន់តែប្រសិទ្ធិភាពដោយបង្ការកុំឱ្យជំងឺវិវត្ត ឬកាត់បន្ថយភាពធ្ងន់ធ្ងររបស់វាបានយ៉ាងច្រើន។

## សំណួរ. តើវ៉ាក់សាំងមានប្រសិទ្ធិភាពយ៉ាងណាដែរ?

វ៉ាក់សាំងបង្ការរោគ MMR មានប្រសិទ្ធិភាពខ្លាំងក្នុងកិច្ចការពារប្រឆាំងទល់នឹងការឆ្លងរោគកញ្ជ្រឹល ស្រឡទែន និងស្អូច។

## សំណួរ. តើអ្នកណាខ្លះគួរតែចាក់វ៉ាក់សាំង?

វ៉ាក់សាំងបង្ការរោគកញ្ជ្រឹល-ស្រឡទែន-ស្អូច (MMR) ពីរដូសត្រូវបានណែនាំសម្រាប់មនុស្សវ័យជំទង់ ដើម្បីទទួលបានភាពស៊ាំពេញលេញប្រឆាំងទល់នឹងរោគកញ្ជ្រឹល ស្រឡទែន និងស្អូច លុះត្រាតែពួកគេបានចាក់វ៉ាក់សាំងពីរដូសពីលើកមុន។

## សំណួរ. តើអ្នកណាខ្លះមិនគួរចាក់វ៉ាក់សាំង?

មិនគួរចាក់វ៉ាក់សាំងបង្ការរោគ MMR ឱ្យមនុស្សដែល៖

- ធ្លាប់មានប្រតិកម្មទាស់អាណាហ្វីឡាក់ស៊ី បន្ទាប់ពីបានចាក់វ៉ាក់សាំងបង្ការរោគ MMR មួយដូសពីលើកមុន
- ធ្លាប់មានប្រតិកម្មទាស់អាណាហ្វីឡាក់ស៊ី បន្ទាប់ពីសារធាតុផ្សំបន្ថែមនៃវ៉ាក់សាំងណាមួយ (ចុះនៅទំព័រម្ខាងទៀត)។
- មានផ្ទៃពោះ (គួរជៀសវាងការមានផ្ទៃពោះក្នុងរយៈពេល២៨ថ្ងៃ បន្ទាប់ពីការចាក់វ៉ាក់សាំង)
- បានចាក់វ៉ាក់សាំងមានផ្ទុកវីរុសសកម្ម ក្នុងរយៈពេល៤សប្តាហ៍កន្លងមក ឧទាហរណ៍ រោគស្អូច BCG (ជំងឺរបេង) ឬរោគខាន់លឿង
- បានចាក់បញ្ចូលឈាម/ការចាក់បញ្ចូលអង្គបដិបក្ខក្នុងឆ្នាំកន្លងទៅ។
- មានភាពស៊ាំចុះថយ ពោលគឺ៖
  - (i) មនុស្សដែលមានរោគហេដ្ឋអាយវី/ជំងឺអេដស៍ (HIV/AIDS)
  - (ii) មនុស្សដែលលេបថ្នាំ corticosteroid ដូសខ្ពស់
  - (iii) មនុស្សដែលដែលកំពុងទទួលការព្យាបាលដោយប្រព័ន្ធការពារភាពស៊ាំចុះខ្សោយដូសខ្ពស់ ការព្យាបាលដោយវិទ្យុសកម្មទូទៅ ឬការព្យាបាលដោយកាំរស្មីអ៊ិច
  - (iv) មនុស្សដែលទទួលរងពីស្ថានភាពសាហាវនៃប្រព័ន្ធ reticuloendothelial រួមទាំងជំងឺមហារីកកូនកណ្តុរ ជំងឺមហារីកឈាម និងជំងឺ Hodgkin។

## សំណួរ. តើវ៉ាក់សាំងបង្ការរោគ MMR មានសារធាតុផ្សំបន្ថែមអ្វីខ្លះ?

វ៉ាក់សាំងបង្ការរោគ MMR មានផ្ទុកនូវសារធាតុជាតិស្ករក្នុងទឹកដោះ neomycin, sorbitol និង mannitol។ សារធាតុផ្សំបន្ថែមក្នុងបរិមាណយ៉ាងតិចបំផុត ត្រូវបានដាក់បញ្ចូលដើម្បីជួយឱ្យវ៉ាក់សាំងបំពេញមុខការរបស់វា ឬក៏ជួយកុំឱ្យវាខូច។

## សំណួរ. តើវ៉ាក់សាំងមានប្រសិទ្ធិភាពយ៉ាងណាដែរ?

វ៉ាក់សាំងដែលប្រើប្រាស់នៅក្នុងប្រទេសអូស្ត្រាលីមានសុវត្ថិភាព ហើយត្រូវតែឆ្លងកាត់ការធ្វើតេស្តសុវត្ថិភាពយ៉ាងតឹងរ៉ឹង មុនពេលត្រូវបានអនុម័តដោយរដ្ឋបាលគ្រប់គ្រងលើទំនិញទាក់ទងនឹងការព្យាបាល (TGA)។ លើសពីនេះទៀត TGA តាមដានសុវត្ថិភាពនៃវ៉ាក់សាំងនៅពេលកំពុងត្រូវបានប្រើប្រាស់។

## សំណួរ. តើការចាក់វ៉ាក់សាំងបង្ការរោគ MMR មានផលប៉ះពាល់បន្ទាប់បន្សំអ្វីខ្លះ?

វ៉ាក់សាំងបង្ការរោគ MMR មានសុវត្ថិភាព ប្រសិទ្ធិភាព និងអនុគ្រោះឱ្យច្រើន។ ផលប៉ះពាល់បន្ទាប់បន្សំ ជាទូទៅមានភាពអន់ខ្សោយ ហើយជាទូទៅអាចមានអារម្មណ៍មិនស្រួលខ្លួន គ្រុនក្តៅ និង/ឬមានកន្ទួល (មិនឆ្លងទេ ហើយអាចកើតមានឡើងពី៥-១២ថ្ងៃបន្ទាប់ពីការចាក់វ៉ាក់សាំងបង្ការ MMR)។ ផលប៉ះពាល់ធ្ងន់ធ្ងររួមមានប្រតិកម្មទាស់អាណាហ្វីឡាក់ស៊ី (សូមមើលព័ត៌មានខាងក្រោម) រោគហើមក្រពេញទឹករងៃជាបណ្តោះអាសន្ន (ការហើមប៉ោងក្រពេញទឹករងៃដែលឆាប់ជាបាត់) ការឈឺសន្លាក់ឆ្អឹង ការកើនឡើងនូវសក្តានុពលសម្រាប់ស្នាមជាំ និងការចេញឈាម ទាំងអស់នេះកម្រកើតមានណាស់។ ព័ត៌មានបន្ថែមអំពីផលប៉ះពាល់បន្ទាប់បន្សំ អាចរកបាននៅក្នុងព័ត៌មានផ្នែកវេជ្ជសាស្ត្រសម្រាប់អ្នកប្រើប្រាស់ (CMI) សម្រាប់វ៉ាក់សាំង ដែលអាចរកបានពីគេហទំព័រ www.health.nsw.gov.au/schoolvaccination។ មាតាបិតាដែលព្រួយបារម្ភអំពីផលប៉ះពាល់បន្ទាប់បន្សំបន្ទាប់ពីការចាក់វ៉ាក់សាំង គួរទាក់ទងមកវេជ្ជបណ្ឌិតព្យាបាលរោគទូទៅរបស់ពួកគេ ដែលពេលនោះវេជ្ជបណ្ឌិតគួរធ្វើរបាយការណ៍ទៅអង្គភាពសុខភាពសាធារណៈផងដែរ។

## សំណួរ. តើអ្វីជាប្រតិកម្មទាស់អាណាហ្វីឡាក់ស៊ី (anaphylaxis)?

អាណាហ្វីឡាក់ស៊ី គឺជាប្រតិកម្មទាស់នឹងសារធាតុយ៉ាងធ្ងន់ធ្ងរដែលអាចនាំឱ្យសន្លប់ពុំដឹងខ្លួន និងស្លាប់បាត់បង់ជីវិតទៀតផង ប្រសិនបើពុំបានព្យាបាលជាបន្ទាន់ទេ។ **ការនេះកើតឡើង*ដោយកម្របំផុត*បន្ទាប់ពីការចាក់វ៉ាក់សាំង។** គិលានុបដ្ឋាកចាក់វ៉ាក់សាំងនៅតាមសាលារៀន មានការហ្វឹកហ្វឺនយ៉ាងពេញលេញក្នុងការព្យាបាលប្រតិកម្មទាស់អាណាហ្វីឡាក់ស៊ី។

## សំណួរ. តើគួរចាក់វ៉ាក់សាំងដល់សិស្សស្រីដែលមាន ឬដែលគិតថាប្រហែលជាមានផ្ទៃពោះទេ?

ទេ។ សិស្សស្រីណាដែលមាន ឬដែលគិតថាប្រហែលជាមានផ្ទៃពោះ ពុំគួរចាក់វ៉ាក់សាំងទេ។ នៅថ្ងៃចាក់ថ្នាំ គិលានុបដ្ឋាកផ្នែកចាក់វ៉ាក់សាំងនឹងសួរសិស្សស្រីទាំងឡាយប្រសិនបើគេមាន ឬអាចមានផ្ទៃពោះ។ ប្រសិនបើសិស្សឆ្លើយទៅនឹងសំណួរនេះថាមាន នោះពុំត្រូវបានគេចាក់វ៉ាក់សាំងឱ្យឡើយ។ សិស្សនឹងត្រូវបានណែនាំឱ្យពិភាក្សាអំពីរឿងនេះជាបន្ទាន់ ជាមួយមាតាបិតា/អាណាព្យាបាល ហើយស្វែងរកជំនួយផ្នែកវេជ្ជសាស្ត្រ។ សិស្សក៏នឹងទទួលបានព័ត៌មានលម្អិតផងដែរ ដើម្បីទាក់ទងជាមួយសេវាកម្មបញ្ជូនបន្តសុខភាពដទៃទៀតដែលនឹងផ្តល់ដំបូន្មាន ការគាំទ្រ និងការណែនាំ។

សិស្សស្រីទាំងឡាយណាដែលបានចាក់វ៉ាក់សាំងបង្ការរោគ MMR មិនគួរមានផ្ទៃពោះឡើយក្នុងអំឡុងពេល២៨ថ្ងៃ បន្ទាប់ពីការចាក់វ៉ាក់សាំង។

## សំណួរ. ចុះប្រសិនបើកូនរបស់ខ្ញុំកើតរោគហឺត ហើយប្រើថ្នាំ cortisone ‘ខទីហ្សូន’ ឬ prednisone ‘ប្រ៊ីននីហ្សូន) ដោយប្រើ “បំពង់ហឺត” (puffer)?

វ៉ាក់សាំងបង្ការរោគ MMRa អាចផ្តល់ឱ្យអ្នកណាម្នាក់ដែលកើតរោគហឺតបានដោយសុវត្ថិភាព ដោយមិនគិតអំពីថ្នាំពេទ្យណាមួយដែលគេកំពុងប្រើប្រាស់ឡើយ។

## សំណួរ. តើអ្នកណាអាចយល់ព្រមលើការចាក់វ៉ាក់សាំង ហើយតើគេអាចដកចេញការយល់ព្រមបានទេ?

មានតែមាតាបិតា/អាណាព្យាបាលប៉ុណ្ណោះ អាចផ្តល់ការយល់ព្រមលើការចាក់វ៉ាក់សាំងសម្រាប់សិស្សអាយុតិចជាង១៨ឆ្នាំ។ សិស្សទាំងឡាយដែលមានអាយុ១៨ឆ្នាំ និងលើសពីនេះ អាចធ្វើការយល់ព្រមដោយខ្លួនឯងដើម្បីចាក់វ៉ាក់សាំង ហើយគួរតែបំពេញ និងចុះហត្ថលេខាលើបែបបទយល់ព្រមនៅកន្លែងណាដែលមានបង្ហាញ ‘មាតាបិតា/អាណាព្យាបាល’។ ការយល់ព្រមអាចដកចេញបាននៅពេលណាក៏បាន ដោយផ្តល់ដំណឹងជាលាយលក្ខណ៍អក្សរទៅសាលារៀនអំពីការដកចេញការយល់ព្រម ឬទូរសព្ទទៅសាលារៀនដើម្បីដកចេញការយល់ព្រម។

## សំណួរ. តើខ្ញុំអាចចូលប្រើកំណត់ត្រានៃការចាក់វ៉ាក់សាំងដោយរបៀបណា?

ព័ត៌មានអំពីការចាក់វ៉ាក់សាំងរបស់កូនអ្នក នឹងត្រូវបានផ្ទុកទៅក្នុងបញ្ជីចាក់ថ្នាំបង្ការរោគអូស្ត្រាលី (AIR) ដើម្បីភ្ជាប់វាទៅនឹងប្រវត្តិនៃការចាក់ថ្នាំបង្ការរោគដែលមានស្រាប់របស់កូនអ្នក។

មាតាបិតាអាចស្នើសុំច្បាប់ចម្លងនៃសេចក្តីថ្លែងអំពីប្រវត្តិចាក់ថ្នាំបង្ការរោគ AIR របស់កូនពួកគេនៅពេលណាមួយ រហូតដល់កូនរបស់ពួកគេមានអាយុ១៤ឆ្នាំ ហើយសិស្សដែលមានអាយុចាប់ពី១៤ឆ្នាំឡើងទៅ អាចស្នើសុំសេចក្តីថ្លែងអំពីប្រវត្តិចាក់ថ្នាំបង្ការរោគដោយខ្លួនឯងដូចខាងក្រោម៖

- ដោយប្រើគណនី Medicare តាមអនឡាញ តាមរយៈ myGov my.gov.au/
- ដោយប្រើកម្មវិធី Medicare Express Plus App www.humanservices.gov.au/individuals/subjects/express-plus-mobile-apps
- ទូរសព្ទទៅបណ្តាញទូរសព្ទសាកសួរទូទៅរបស់ AIR តាមលេខ 1800 653 809។

## សំណួរ. តើខ្ញុំត្រូវធ្វើដូចម្តេច ប្រសិនបើកូនរបស់ខ្ញុំខកខានការចាក់វ៉ាក់សាំងដោយសារមានជំងឺ ឬអវត្តមាននៅថ្ងៃគិលានុបដ្ឋាកអញ្ជើញមក?

អ្នកគួរទាក់ទងមកវេជ្ជបណ្ឌិតក្នុងតំបន់របស់អ្នក ហើយរៀបចំការចាក់វ៉ាក់សាំងសម្រាប់កូនរបស់អ្នក។

## សំណួរ. តើមានអ្វីកើតឡើងដល់ព័ត៌មានរបស់កូនខ្ញុំ?

ព័ត៌មានដែលអ្នកផ្តល់នៅលើបែបបទយល់ព្រម នឹងត្រូវបានរក្សាទុកជាសម្ងាត់យ៉ាងម៉ឺងម៉ាត់ និងជាកិច្ចការពារភាពឯកជនដែលមានចែងនៅក្នុងច្បាប់រដ្ឋ NSW និងសហព័ន្ធ (សូមអានសេចក្តីថ្លែងអំពីឯកជនភាពដែលភ្ជាប់មកជាមួយ)។ ព័ត៌មាននេះនឹងត្រូវបានដាក់បញ្ចូលទៅក្នុងបញ្ជីចាក់ថ្នាំបង្ការរោគរបស់ NSW Health រួចមកនឹងត្រូវបានផ្ទុកទៅក្នុងបញ្ជីចាក់ថ្នាំបង្ការរោគអូស្ត្រាលី (AIR) ដើម្បីភ្ជាប់វាទៅនឹងប្រវត្តិនៃការចាក់ថ្នាំបង្ការរោគដែលមានស្រាប់របស់កូនអ្នក ហើយមើលឃើញនៅលើ MyGov។

## សំណួរ. តើខ្ញុំអាចស្វែងរកព័ត៌មានបន្ថែមនៅកន្លែងណាអំពីការចាក់វ៉ាក់សាំងនៅសាលារៀន?

ព័ត៌មានបន្ថែមអាចទទួលយកបាន៖

- ដោយចូលមើលគេហទំព័រ NSW Health នៅត្រង់គេហទំព័រ www.health.nsw.gov.au/schoolvaccination
- ដោយទាក់ទងអង្គភាពសុខភាពសាធារណៈក្នុងតំបន់របស់អ្នក តាមទូរសព្ទលេខ 1300 066 055

September 2022 © NSW Ministry of Health. SHPN (HP NSW) 220731-1-13

## កិច្ចការដែលត្រូវធ្វើ បន្ទាប់ពីការចាក់វ៉ាក់សាំង

- សូមរក្សាទុកកំណត់ត្រានេះ ដោយហេតុថាអ្នកនឹងត្រូវបានតម្រូវឱ្យផ្តល់ព័ត៌មាននេះនៅពេលក្រោយទៀត។
- ព័ត៌មានអំពីការចាក់វ៉ាក់សាំងរបស់កូនអ្នក នឹងត្រូវបានផ្ទុកឡើងដោយស្វ័យប្រវត្តិទៅក្នុងបញ្ជីចាក់ថ្នាំបង្ការអូស្ត្រាលី (AIR)។ អ្នកប្រហែលជាចង់ធ្វើបច្ចុប្បន្នភាព GP របស់អ្នក ទាក់ទងនឹងកាលបរិច្ឆេទការចាក់វ៉ាក់សាំង។

## អ្វីដែលត្រូវធ្វើ ប្រសិនបើកើតមានប្រតិកម្មនៅត្រង់កន្លែងចាក់ថ្នាំ

- ដាក់ក្រណាត់សើមត្រជាក់ទៅលើកន្លែងចាក់ថ្នាំ ដើម្បីបន្ថយការឈឺចាប់។
- ផឹកថ្នាំផារ៉ាស៊ីតាម៉ុល ដើម្បីបន្ថយការឈឺចាប់។
- ផឹកវត្ថុរាវឱ្យច្រើន។

**ប្រសិនបើកូនរបស់អ្នករងទុក្ខពីប្រតិកម្មណាមួយដែលអ្នកកើតមានកង្វល់ សូមទាក់ទងជាមួយវេជ្ជបណ្ឌិតក្នុងតំបន់អ្នក។**

NSW GOVERNMENT


## កិច្ចការដែលត្រូវធ្វើ បន្ទាប់ពីការចាក់វ៉ាក់សាំង

- សូមរក្សាទុកកំណត់ត្រានេះ ដោយហេតុថាអ្នកនឹងត្រូវបានតម្រូវឱ្យផ្តល់ព័ត៌មាននេះនៅពេលក្រោយទៀត។
- ព័ត៌មានអំពីការចាក់វ៉ាក់សាំងរបស់កូនអ្នក នឹងត្រូវបានផ្ទុកឡើងដោយស្វ័យប្រវត្តិទៅក្នុងបញ្ជីចាក់ថ្នាំបង្ការអូស្ត្រាលី (AIR)។ អ្នកប្រហែលជាចង់ធ្វើបច្ចុប្បន្នភាព GP របស់អ្នក ទាក់ទងនឹងកាលបរិច្ឆេទការចាក់វ៉ាក់សាំង។

## អ្វីដែលត្រូវធ្វើ ប្រសិនបើកើតមានប្រតិកម្មនៅត្រង់កន្លែងចាក់ថ្នាំ

- ដាក់ក្រណាត់សើមត្រជាក់ទៅលើកន្លែងចាក់ថ្នាំ ដើម្បីបន្ថយការឈឺចាប់។
- ផឹកថ្នាំផារ៉ាស៊ីតាម៉ុល ដើម្បីបន្ថយការឈឺចាប់។
- ផឹកវត្ថុរាវឱ្យច្រើន។

**ប្រសិនបើកូនរបស់អ្នករងទុក្ខពីប្រតិកម្មណាមួយដែលអ្នកកើតមានកង្វល់ សូមទាក់ទងជាមួយវេជ្ជបណ្ឌិតក្នុងតំបន់អ្នក។**

NSW GOVERNMENT


220731-2-13

Khmer

# ការយល់ព្រមដើម្បីទទួលការចាក់វ៉ាក់សាំងរោគកញ្ជ្រឹល សាលាទែន និងស្អូច (MMR)

NSW GOVERNMENT

ត្រូវបំពេញដោយឪពុក ឬម្តាយ/អាណាព្យាបាល។ សូមសរសេរជា**អក្សរពុម្ព**ដោយប្រើប៊ិចពណ៌**ខ្មៅ** ឬ**ខៀវ**។

## 1. ព័ត៌មានលម្អិតរបស់សិស្ស

នាមត្រកូល

នាមខ្លួន

ថ្ងៃខែឆ្នាំកំណើត __ __ / __ __ / 2 0 __ __

ភេទ ☐ ប្រ ☐ ស្រ ☐ មិនជាក់លាក់/អន្តរភេទ/មិនបានបញ្ជាក់

ថ្នាក់រៀន

ឈ្មោះសាលារៀន

លេខមេឌីឃែរ

☐ លេខនៅក្បែរឈ្មោះកូនរបស់អ្នកនៅលើប័ណ្ណមេឌីឃែរ

## 2. ស្ថានភាពជាជនជាតិដើម

☐ ទេ ☐ បាទ/ចាស ជនជាតិដើម ☐ បាទ/ចាស អ្នកកោះ Torres Strait ☐ បាទ/ចាស ជនជាតិដើម និងអ្នកកោះ Torres Strait

## 3. ព័ត៌មានលម្អិតរបស់អ្នក – ឪពុក ឬម្តាយ/អាណាព្យាបាល

ខ្ញុំបានអាន ហើយយល់ដឹងអំពីព័ត៌មានដែលបានផ្តល់មកឱ្យខ្ញុំ ទាក់ទិននឹងគុណប្រយោជន៍ និងផលប៉ះពាល់បន្ទាប់បន្សំដែលអាចកើតមានពីវ៉ាក់សាំងរោគកញ្ជ្រឹល សាលាទែន និងស្អូច (MMR)។

តាមរយៈនេះ ខ្ញុំសូមផ្តល់ការយល់ព្រមឱ្យកូនរបស់ខ្ញុំ ដូមានឈ្មោះខាងលើ ទទួលការចាក់ពីរដូសនៃវ៉ាក់សាំងរោគកញ្ជ្រឹល សាលាទែន និងស្អូច (MMR)។

ខ្ញុំសូមប្រកាស តាមដែលខ្ញុំដឹងជាក់ច្បាស់ថាកូនរបស់ខ្ញុំ៖

1. ពុំដែលមានប្រតិកម្មអាណាហ្វីឡាក់ទិច (ប្រតិកម្មទាស់យ៉ាងធ្ងន់ធ្ងរ) បន្ទាប់ពីចាក់វ៉ាក់សាំងណាមួយឡើយ។
2. មិនមានប្រតិកម្មអាណាហ្វីឡាក់ទិច (ប្រតិកម្មទាស់យ៉ាងធ្ងន់ធ្ងរ) ចំពោះសមាសធាតុវ៉ាក់សាំងណាមួយដែលមានរាយក្នុងសន្លឹកព័ត៌មានសម្រាប់ឪពុកម្តាយដែលដាក់ភ្ជាប់មកជាមួយទេ។
3. មិនមានផ្ទៃពោះទេ។

ឈ្មោះឪពុក ឬម្តាយ/អាណាព្យាបាល (ឧទាហរណ៍ JOHN SMITH)

អាសយដ្ឋានផ្ទះ (ឧទាហរណ៍ 5 SMITH LANE)

តំបន់

លេខកូដប្រៃសណីយ៍

លេខទូរសព្ទចល័ត

លេខទូរសព្ទផ្សេងទៀតដែលល្អជាងគេ (មានរួមទាំងលេខតំបន់ ឧទាហរណ៍ 02)

ហត្ថលេខាឪពុក ឬម្តាយ/អាណាព្យាបាល

ថ្ងៃទី __ __ / __ __ / 2 0 __ __

## កំណត់ត្រានៃការចាក់វ៉ាក់សាំងរោគ MMR

✍ ត្រូវបំពេញដោយឪពុក ឬម្តាយ/អាណាព្យាបាល

**ឈ្មោះសិស្ស** (ឧទាហរណ៍ JANE SMITH)

### សម្រាប់ការិយាល័យប្រើប៉ុណ្ណោះ

ដូសទី 1

ដៃ ☐ ឆ្វេង ☐ ស្តាំ

ម៉ោងចាក់វ៉ាក់សាំង (24 ម៉ោង)

លេខក្រុមវ៉ាក់សាំង

ហត្ថលេខារបស់គិលានុបដ្ឋាក

ថ្ងៃទី __ / __ 2 0 __

ដូសទី 2

ដៃ ☐ ឆ្វេង ☐ ស្តាំ

ម៉ោងចាក់វ៉ាក់សាំង (24 ម៉ោង)

លេខក្រុមវ៉ាក់សាំង

ហត្ថលេខារបស់គិលានុបដ្ឋាក

✕

ថ្ងៃទី __ / __

**កំណត់ចំណាំរបស់គិលានុបដ្ឋាក**

មូលហេតុមិនបានចាក់ថ្នាំ

- ☐ អវត្តមាន
- ☐ បដិសេធ
- ☐ មិនស្រួលខ្លួន
- ☐ ពុំមានហត្ថលេខា
- ☐ ដកចេញការយល់ព្រម
- ☐ ផ្សេងទៀត

## ឪពុក ឬម្តាយ/អាណាព្យាបាល

កំណត់ត្រានៃការចាក់វ៉ាក់សាំងរោគកញ្ជ្រឹល សាលាទែន និងស្អូច (MMR)

### កំណត់ត្រានៃការចាក់វ៉ាក់សាំងរោគ MMR — ដូសទី 1

✍ ត្រូវបំពេញដោយឪពុក ឬម្តាយ/អាណាព្យាបាល

**ឈ្មោះសិស្ស** (ឧទាហរណ៍ JANE SMITH)

សម្រាប់ការិយាល័យប្រើប៉ុណ្ណោះ

ដៃ ☐ ឆ្វេង ☐ ស្តាំ

ម៉ោងចាក់វ៉ាក់សាំង (24 ម៉ោង) __ __ : __ __

លេខក្រុមវ៉ាក់សាំង

ហត្ថលេខារបស់គិលានុបដ្ឋាក

✕

ថ្ងៃទី __ / __ 2 0 __

### កំណត់ត្រានៃការចាក់វ៉ាក់សាំងរោគ MMR — ដូសទី 2

✍ ត្រូវបំពេញដោយឪពុក ឬម្តាយ/អាណាព្យាបាល

**ឈ្មោះសិស្ស** (ឧទាហរណ៍ JANE SMITH)

សម្រាប់ការិយាល័យប្រើប៉ុណ្ណោះ

ដៃ ☐ ឆ្វេង ☐ ស្តាំ

ម៉ោងចាក់វ៉ាក់សាំង (24 ម៉ោង) __ __ : __ __

លេខក្រុមវ៉ាក់សាំង

ហត្ថលេខារបស់គិលានុបដ្ឋាក

✕

ថ្ងៃទី __ / __ 2 0 __

# វ៉ាក់សាំងបង្ការជំងឺគ្រុនស្វិតដៃជើង

Polio vaccine

NSW Health (ក្រសួងសុខាភិបាល រដ្ឋញូវសៅវែល) ផ្តល់ជូនវ៉ាក់សាំងដែលបានណែនាំសម្រាប់មនុស្សជំទង់ ដោយក្រុមប្រឹក្សាស្រាវជ្រាវផ្នែកសុខភាព និងវេជ្ជសាស្ត្រជាតិក្នុងកម្មវិធីចាក់វ៉ាក់សាំងនៅតាមសាលារៀន។ ត្រូវផ្តល់ការយល់ព្រមដែលបានចុះហត្ថលេខាដោយមាតាបិតាឬបិតា/អាណាព្យាបាល។

## វិធានការបន្ទាប់របស់អ្នក

- សូមអានសន្លឹកព័ត៌មាននេះដោយប្រុងប្រយ័ត្ន។
- ប្រសិនបើអ្នកចង់ឱ្យកូនរបស់អ្នកចាក់វ៉ាក់សាំងប្រឆាំងទល់នឹងជំងឺគ្រុនស្វិតដៃជើង សូមបំពេញបែបបទយល់ព្រម ហើយប្រគល់បែបបទយល់ព្រមដែលបានចុះហត្ថលេខារួច ទៅឱ្យកូនរបស់អ្នកដើម្បីយកទៅសាលារៀនវិញ។
- ប្រសិនបើអ្នកមិនចង់ឱ្យកូនរបស់អ្នកចាក់វ៉ាក់សាំងប្រឆាំងទល់នឹងជំងឺគ្រុនស្វិតដៃជើងទេ សូមកុំបំពេញ ឬក៏បញ្ជូនបែបបទយល់ព្រមនេះទៅសាលារៀនវិញឱ្យសោះ។

## សំណួរ. តើអ្វីជារោគគ្រុនស្វិតដៃជើង?

ជំងឺគ្រុនស្វិតដៃជើង គឺជាមេរោគបង្កឡើងដោយមេរោគគ្រុនស្វិតដៃជើងដែលអាចបណ្តាលឱ្យខ្វិន និងស្លាប់។ មនុស្សភាគច្រើនដែលបានឆ្លងជំងឺគ្រុនស្វិតដៃជើងមិនមានរោគសញ្ញាណាមួយឡើយ។ អាការៈមានជំងឺតិចតួចបង្កឱ្យមានគ្រុនក្តៅ ឈឺក្បាល ល្វិតល្វៃ ចង់ក្អួត និងចង្អោរ កើតឡើងប្រហែលជា១០ភាគរយនៃមនុស្សដែលមានផ្ទុកមេរោគនេះ។ ខណៈពេលដែលមនុស្សទាំងនេះភាគច្រើនបានធូរស្រាលឡើងវិញ ប្រហែលជា២ភាគរយមានការឈឺសាច់ដុំធ្ងន់ធ្ងរជាមួយនឹងអាការៈរឹងខ្នង ឬក ដែលបណ្តាលមកពីការរលាកនៃស្រទាប់ខួរក្បាល។ តិចជាង១ភាគរយនៃមនុស្សដែលបានឆ្លងមេរោគនេះ កើតមានអាការៈទន់ខ្សោយធ្ងន់ធ្ងរដែលគេហៅថា អាការៈខ្វិនទន់ខ្សោយខ្លាំងដែលអាចប៉ះពាល់ដល់អវៈយវៈសាច់ដុំក្បាល និងក ហើយនិងសាច់ដុំប្រើប្រាស់សម្រាប់ដកដង្ហើម។

## សំណួរ. តើជំងឺគ្រុនស្វិតដៃជើងឆ្លងរាលដាលដោយរបៀបណា?

ជំងឺគ្រុនស្វិតដៃជើង ឆ្លងតាមរយៈទំនាក់ទំនងជិតស្និទ្ធជាមួយអ្នកមានផ្ទុកមេរោគនេះ តាមរយៈការប៉ះពាល់លាមកក្នុងបរិមាណតិចតួច (ឧ. នៅលើដៃមិនបានលាងទឹកសម្អាត) ឬទឹកមាត់ពីអ្នកមានផ្ទុកមេរោគនេះ។ មេរោគជំងឺគ្រុនស្វិតដៃជើងចូលក្នុងរាងកាយតាមច្រមុះ ឬមាត់ ហើយការឆ្លងមេរោគចាប់ផ្តើមនៅក្នុងពោះវៀន។ បន្ទាប់មកវាចូលក្នុងផ្លូវសរសៃឈាម ហើយចម្លងទៅកាន់ផ្នែកផ្សេងទៀតនៃរាងកាយ រួមមានប្រព័ន្ធសរសៃប្រសាទ។ ករណីភាគច្រើន ឆ្លងមេរោគនេះក្នុងរយៈពេល១០ថ្ងៃមុន និង១០ថ្ងៃបន្ទាប់ពីចាប់ផ្តើមចេញរោគសញ្ញា។

## សំណួរ. តើវ៉ាក់សាំងដំណើរការដោយរបៀបណា?

វ៉ាក់សាំងដំណើរការដោយធ្វើឱ្យប្រព័ន្ធភាពស៊ាំ ប្រយុទ្ធប្រឆាំងនឹងមេរោគជាក់លាក់មួយចំនួន។ ប្រសិនបើមនុស្សដែលបានចាក់វ៉ាក់សាំងប៉ះពាល់ជាមួយមេរោគទាំងនេះ ប្រព័ន្ធភាពស៊ាំរបស់គេអាចឆ្លើយតបបានកាន់តែប្រសិទ្ធិភាពដោយបង្ការកុំឱ្យជំងឺវិវត្ត ឬកាត់បន្ថយភាពធ្ងន់ធ្ងររបស់វាបានយ៉ាងច្រើន។

## សំណួរ. តើវ៉ាក់សាំងបង្ការជំងឺគ្រុនស្វិតដៃជើង មានប្រសិទ្ធិភាពយ៉ាងណាដែរ?

វគ្គបឋមនៃការចាក់វ៉ាក់សាំងបង្ការជំងឺគ្រុនស្វិតដៃជើង៣ដូស មានប្រសិទ្ធិភាពយ៉ាងហោចណាស់៩៩ភាគរយប្រឆាំងទល់នឹងជំងឺនេះ។

## សំណួរ. តើអ្នកណាខ្លះគួរតែចាក់វ៉ាក់សាំង?

សិស្សដែលមិនបានទទួលវគ្គបឋម នៃការចាក់វ៉ាក់សាំងបង្ការជំងឺគ្រុនស្វិតដៃជើង (ការចាក់វ៉ាក់សាំង៣ដូស យ៉ាងហោចណាស់៤សប្តាហ៍គម្លាតពីគ្នា) គួរតែបានចាក់វ៉ាក់សាំង។ ដោយសារសិស្សភាគច្រើននឹងបានចាក់វ៉ាក់សាំងបង្ការជំងឺគ្រុនស្វិតដៃជើងយ៉ាងហោចណាស់មួយដូស រហូតដល់ទៅ២ដូសនឹងមានផ្តល់នៅមជ្ឈមណ្ឌលសិក្សាភាសាអង់គ្លេសល្វិតល្វន់ ហើយឪពុកម្តាយសិស្សនឹងត្រូវបានណែនាំឱ្យទៅជួបវេជ្ជបណ្ឌិតក្នុងតំបន់របស់ពួកគេ ដើម្បីចាក់ដូសទីបីក្នុងករណីចាំបាច់។

## សំណួរ. តើអ្នកណាខ្លះមិនគួរចាក់វ៉ាក់សាំង?

មិនគួរចាក់វ៉ាក់សាំងបង្ការជំងឺគ្រុនស្វិតដៃជើង ឱ្យមនុស្សដែល៖

- ធ្លាប់មានប្រតិកម្មទាស់អាណាហ្វីឡាក់ស៊ី បន្ទាប់ពីបានចាក់វ៉ាក់សាំងមួយដូសពីលើកមុន
- ធ្លាប់មានប្រតិកម្មទាស់អាណាហ្វីឡាក់ស៊ី បន្ទាប់ពីសារធាតុផ្សំបន្ថែមនៃវ៉ាក់សាំងណាមួយ (ចុះនៅទំព័រម្ខាងទៀត)។

## សំណួរ. តើអ្វីជាប្រតិកម្មទាស់អាណាហ្វីឡាក់ស៊ី (anaphylaxis)?

អាណាហ្វីឡាក់ស៊ី គឺជាប្រតិកម្មទាស់នឹងសារធាតុយ៉ាងធ្ងន់ធ្ងរដែលអាចនាំឱ្យសន្លប់ពុំដឹងខ្លួន និងស្លាប់បាត់បង់ជីវិតទៀតផង ប្រសិនបើពុំបានព្យាបាលជាបន្ទាន់ទេ។

**ការនេះកើតឡើង*ដោយកម្របំផុត*បន្ទាប់ពីការចាក់វ៉ាក់សាំង។** គិលានុបដ្ឋាកចាក់វ៉ាក់សាំងនៅតាមសាលារៀន មានការហ្វឹកហ្វឺនយ៉ាងពេញលេញក្នុងការព្យាបាលប្រតិកម្មទាស់អាណាហ្វីឡាក់ស៊ី។

## សំណួរ. តើខ្ញុំគួរធ្វើដូចម្តេចប្រសិនបើខ្ញុំមិនមានកំណត់ត្រា ឬខ្ញុំមិនអាចចាំបានថាកូនរបស់ខ្ញុំបានចាក់វ៉ាក់សាំងបង្ការជំងឺគ្រុនស្វិតដៃជើងរួចហើយ ឬក៏អត់?

កូនក្មេង និងមនុស្សជំទង់អាចចាក់វ៉ាក់សាំងបង្ការជំងឺគ្រុនស្វិតដៃជើងដោយសុវត្ថិភាព ប្រសិនបើពុំមានភស្តុតាងបញ្ជាក់ពីការចាក់វ៉ាក់សាំងពីមុនទេ។

## សំណួរ. តើវ៉ាក់សាំងបង្ការជំងឺគ្រុនស្វិតដៃជើងមានសារធាតុផ្សំបន្ថែមអ្វីខ្លះ?

វ៉ាក់សាំងបង្ការរោគមានផ្ទុកនូវសារធាតុ phenoxyethanol, formaldehyde, polysorbate 80 និងបរិមាណតិចនៃ neomycin, streptomycin, polymyxin B និង bovine សេរ៉ូម albumin។

សារធាតុផ្សំបន្ថែមក្នុងបរិមាណយ៉ាងតិចបំផុតត្រូវបានដាក់បញ្ចូល ដើម្បីជួយឱ្យវ៉ាក់សាំងបំពេញមុខការរបស់វា ឬជួយកុំឱ្យវាខូច។

វ៉ាក់សាំងនេះត្រូវបានដាក់ប៉ះពាល់ទៅនឹងសម្ភារៈ ដែលទទួលបានមកពីសត្វគោក្នុងអំឡុងពេលផលិត។

## សំណួរ. តើវ៉ាក់សាំងមានប្រសិទ្ធិភាពយ៉ាងណាដែរ?

វ៉ាក់សាំងដែលប្រើប្រាស់នៅក្នុងប្រទេសអូស្ត្រាលីមានសុវត្ថិភាព ហើយត្រូវតែឆ្លងកាត់ការធ្វើតេស្តសុវត្ថិភាពយ៉ាងតឹងរ៉ឹង មុនពេលត្រូវបានអនុម័តដោយរដ្ឋបាលគ្រប់គ្រងលើទំនិញទាក់ទងនឹងការព្យាបាល (TGA)។ លើសពីនេះទៀត TGA តាមដានសុវត្ថិភាពនៃវ៉ាក់សាំងនៅពេលកំពុងត្រូវបានប្រើប្រាស់។

## សំណួរ. តើការចាក់វ៉ាក់សាំងមានផលប៉ះពាល់បន្ទាប់បន្សំអ្វីខ្លះ?

ផលប៉ះពាល់បន្ទាប់បន្សំជាទូទៅមិនធ្ងន់ធ្ងរទេ ហើយតាមធម្មតាទាក់ទិននឹងការឡើងក្រហម ការឈឺចាប់ និងហើមប៉ោងនៅត្រង់កន្លែងចាក់ថ្នាំ ឬកើតគ្រុនក្តៅ។ ផលប៉ះពាល់បន្ទាប់បន្សំដែលធ្ងន់ធ្ងរកម្រកើតមានណាស់។ ព័ត៌មានបន្ថែមអំពីផលប៉ះពាល់បន្ទាប់បន្សំ អាចរកបាននៅក្នុងព័ត៌មានផ្នែកវេជ្ជសាស្ត្រសម្រាប់អ្នកប្រើប្រាស់ (CMI) សម្រាប់វ៉ាក់សាំង ដែលអាចរកបានពីគេហទំព័រ www.health.nsw.gov.au/schoolvaccination។ មាតាបិតាដែលព្រួយបារម្ភអំពីផលប៉ះពាល់បន្ទាប់បន្សំបន្ទាប់ពីការចាក់វ៉ាក់សាំង គួរទាក់ទងមកវេជ្ជបណ្ឌិតព្យាបាលរោគទូទៅរបស់ពួកគេ ដែលពេលនោះវេជ្ជបណ្ឌិតគួរធ្វើរបាយការណ៍ទៅអង្គភាពសុខភាពសាធារណៈផងដែរ។

## សំណួរ. តើគួរចាក់វ៉ាក់សាំងដល់សិស្សស្រីដែលមាន ឬដែលគិតថាប្រហែលជាមានផ្ទៃពោះទេ?

ទេ។ សិស្សស្រីណាដែលមាន ឬដែលគិតថាប្រហែលជាមានផ្ទៃពោះ ពុំគួរចាក់វ៉ាក់សាំងទេ។ នៅថ្ងៃចាក់ថ្នាំ គិលានុបដ្ឋាកផ្នែកចាក់វ៉ាក់សាំងនឹងសួរសិស្សស្រីទាំងឡាយប្រសិនបើគេមាន ឬអាចមានផ្ទៃពោះ។ ប្រសិនបើសិស្សឆ្លើយទៅនឹងសំណួរនេះថាមាន នោះពុំត្រូវបានគេចាក់វ៉ាក់សាំងឱ្យឡើយ។ សិស្សនឹងត្រូវបានណែនាំឱ្យពិភាក្សាអំពីរឿងនេះជាបន្ទាន់ ជាមួយមាតាបិតា/អាណាព្យាបាល ហើយស្វែងរកជំនួយផ្នែកវេជ្ជសាស្ត្រ។ សិស្សក៏នឹងទទួលបានព័ត៌មានលម្អិតផងដែរ ដើម្បីទាក់ទងជាមួយសេវាកម្មបញ្ជូនបន្តសុខភាពដទៃទៀតដែលនឹងផ្តល់ដំបូន្មាន ការគាំទ្រ និងការណែនាំ។

## សំណួរ. ចុះប្រសិនបើកូនរបស់ខ្ញុំកើតរោគហឺត ហើយប្រើថ្នាំ cortisone ‘ខទីហ្សូន’ ឬ prednisone ‘ប្រ៊ីននីហ្សូន) ដោយប្រើ “បំពង់ហឺត” (puffer)?

វ៉ាក់សាំងបង្ការជំងឺគ្រុនស្វិតដៃជើង អាចផ្តល់ឱ្យអ្នកណាម្នាក់ដែលកើតរោគហឺតបានដោយសុវត្ថិភាព ដោយមិនគិតអំពីថ្នាំពេទ្យណាមួយដែលគេកំពុងប្រើប្រាស់ឡើយ។

## សំណួរ. តើអ្នកណាអាចយល់ព្រមលើការចាក់វ៉ាក់សាំង ហើយតើគេអាចដកចេញការយល់ព្រមបានទេ?

មានតែមាតាបិតា/អាណាព្យាបាលប៉ុណ្ណោះ អាចផ្តល់ការយល់ព្រមលើការចាក់វ៉ាក់សាំងសម្រាប់សិស្សអាយុតិចជាង១៨ឆ្នាំ។ សិស្សទាំងឡាយដែលមានអាយុ១៨ឆ្នាំ និងលើសពីនេះ អាចធ្វើការយល់ព្រមដោយខ្លួនឯងដើម្បីចាក់វ៉ាក់សាំង ហើយគួរតែបំពេញ និងចុះហត្ថលេខាលើបែបបទយល់ព្រមនៅកន្លែងណាដែលមានបង្ហាញ ‘មាតាបិតា/អាណាព្យាបាល’។ ការយល់ព្រមអាចដកចេញបាននៅពេលណាក៏បាន ដោយផ្តល់ដំណឹងជាលាយលក្ខណ៍អក្សរទៅសាលារៀនអំពីការដកចេញការយល់ព្រម ឬទូរសព្ទទៅសាលារៀនដើម្បីដកចេញការយល់ព្រម។

## សំណួរ. តើខ្ញុំអាចចូលប្រើកំណត់ត្រានៃការចាក់វ៉ាក់សាំងដោយរបៀបណា?

ព័ត៌មានអំពីការចាក់វ៉ាក់សាំងរបស់កូនអ្នក នឹងត្រូវបានផ្ទុកទៅក្នុងបញ្ជីចាក់ថ្នាំបង្ការរោគអូស្ត្រាលី (AIR) ដើម្បីភ្ជាប់វាទៅនឹងប្រវត្តិនៃការចាក់ថ្នាំបង្ការរោគដែលមានស្រាប់របស់កូនអ្នក។

មាតាបិតាអាចស្នើសុំច្បាប់ចម្លងនៃសេចក្តីថ្លែងអំពីប្រវត្តិចាក់ថ្នាំបង្ការរោគ AIR របស់កូនពួកគេនៅពេលណាមួយ រហូតដល់កូនរបស់ពួកគេមានអាយុ១៤ឆ្នាំ ហើយសិស្សដែលមានអាយុចាប់ពី១៤ឆ្នាំឡើងទៅ អាចស្នើសុំសេចក្តីថ្លែងអំពីប្រវត្តិចាក់ថ្នាំបង្ការរោគដោយខ្លួនឯងដូចខាងក្រោម៖

- ដោយប្រើគណនី Medicare តាមអនឡាញ តាមរយៈ myGov my.gov.au/
- ដោយប្រើកម្មវិធី Medicare Express Plus App www.humanservices.gov.au/individuals/subjects/express-plus-mobile-apps
- ទូរសព្ទទៅបណ្តាញទូរសព្ទសាកសួរទូទៅរបស់ AIR តាមលេខ 1800 653 809។

## សំណួរ. តើខ្ញុំត្រូវធ្វើដូចម្តេច ប្រសិនបើកូនរបស់ខ្ញុំខកខានការចាក់វ៉ាក់សាំងដោយសារមានជំងឺ ឬអវត្តមាននៅថ្ងៃគិលានុបដ្ឋាកអញ្ជើញមក?

អ្នកគួរទាក់ទងមកវេជ្ជបណ្ឌិតក្នុងតំបន់របស់អ្នក ហើយរៀបចំការចាក់វ៉ាក់សាំងសម្រាប់កូនរបស់អ្នក។

## សំណួរ. តើមានអ្វីកើតឡើងដល់ព័ត៌មានរបស់កូនខ្ញុំ?

ព័ត៌មានដែលអ្នកផ្តល់នៅលើបែបបទយល់ព្រម នឹងត្រូវបានរក្សាទុកជាសម្ងាត់យ៉ាងម៉ឺងម៉ាត់ និងជាកិច្ចការពារភាពឯកជនដែលមានចែងនៅក្នុងច្បាប់រដ្ឋ NSW និងសហព័ន្ធ (សូមអានសេចក្តីថ្លែងអំពីឯកជនភាពដែលភ្ជាប់មកជាមួយ)។ ព័ត៌មាននេះនឹងត្រូវបានដាក់បញ្ចូលទៅក្នុងបញ្ជីចាក់ថ្នាំបង្ការរោគរបស់ NSW Health រួចមកនឹងត្រូវបានផ្ទុកទៅក្នុងបញ្ជីចាក់ថ្នាំបង្ការរោគអូស្ត្រាលី (AIR) ដើម្បីភ្ជាប់វាទៅនឹងប្រវត្តិនៃការចាក់ថ្នាំបង្ការរោគដែលមានស្រាប់របស់កូនអ្នក ហើយមើលឃើញនៅលើ MyGov។

## សំណួរ. តើខ្ញុំអាចស្វែងរកព័ត៌មានបន្ថែមនៅកន្លែងណាអំពីការចាក់វ៉ាក់សាំងនៅសាលារៀន?

ព័ត៌មានបន្ថែមអាចទទួលយកបាន៖

- ដោយចូលមើលគេហទំព័រ NSW Health នៅត្រង់គេហទំព័រ www.health.nsw.gov.au/schoolvaccination
- ដោយទាក់ទងអង្គភាពសុខភាពសាធារណៈក្នុងតំបន់របស់អ្នក តាមទូរសព្ទលេខ 1300 066 055

## កិច្ចការដែលត្រូវធ្វើ បន្ទាប់ពីការចាក់វ៉ាក់សាំង

- សូមរក្សាទុកកំណត់ត្រានេះ ដោយហេតុថាអ្នកនឹងត្រូវបានតម្រូវឱ្យផ្ដល់ព័ត៌មាននេះនៅពេលក្រោយទៀត។
- ព័ត៌មានអំពីការចាក់វ៉ាក់សាំងរបស់កូនអ្នក នឹងត្រូវបានផ្ទុកឡើងដោយស្វ័យប្រវត្តិទៅក្នុងបញ្ជីចាក់ថ្នាំបង្ការអូស្ត្រាលី (AIR)។ អ្នកប្រហែលជាចង់ធ្វើបច្ចុប្បន្នភាព GP របស់អ្នក ទាក់ទងនឹងកាលបរិច្ឆេទការចាក់វ៉ាក់សាំង។

## អ្វីដែលត្រូវធ្វើ ប្រសិនបើកើតមានប្រតិកម្មនៅត្រង់កន្លែងចាក់ថ្នាំ

- ដាក់ក្រណាត់សើមត្រជាក់ទៅលើកន្លែងចាក់ថ្នាំ ដើម្បីបន្ថយការឈឺចាប់។
- ផឹកថ្នាំផារ៉ាស៊ីតាម៉ុល ដើម្បីបន្ថយការឈឺចាប់។
- ផឹកវត្ថុរាវឱ្យច្រើន។

**ប្រសិនបើកូនរបស់អ្នករងទុក្ខពីប្រតិកម្មណាមួយដែលអ្នកកើតមានកង្វល់ សូមទាក់ទងជាមួយវេជ្ជបណ្ឌិតក្នុងតំបន់អ្នក។**

NSW GOVERNMENT


## កិច្ចការដែលត្រូវធ្វើ បន្ទាប់ពីការចាក់វ៉ាក់សាំង

- សូមរក្សាទុកកំណត់ត្រានេះ ដោយហេតុថាអ្នកនឹងត្រូវបានតម្រូវឱ្យផ្ដល់ព័ត៌មាននេះនៅពេលក្រោយទៀត។
- ព័ត៌មានអំពីការចាក់វ៉ាក់សាំងរបស់កូនអ្នក នឹងត្រូវបានផ្ទុកឡើងដោយស្វ័យប្រវត្តិទៅក្នុងបញ្ជីចាក់ថ្នាំបង្ការអូស្ត្រាលី (AIR)។ អ្នកប្រហែលជាចង់ធ្វើបច្ចុប្បន្នភាព GP របស់អ្នក ទាក់ទងនឹងកាលបរិច្ឆេទការចាក់វ៉ាក់សាំង។

## អ្វីដែលត្រូវធ្វើ ប្រសិនបើកើតមានប្រតិកម្មនៅត្រង់កន្លែងចាក់ថ្នាំ

- ដាក់ក្រណាត់សើមត្រជាក់ទៅលើកន្លែងចាក់ថ្នាំ ដើម្បីបន្ថយការឈឺចាប់។
- ផឹកថ្នាំផារ៉ាស៊ីតាម៉ុល ដើម្បីបន្ថយការឈឺចាប់។
- ផឹកវត្ថុរាវឱ្យច្រើន។

**ប្រសិនបើកូនរបស់អ្នករងទុក្ខពីប្រតិកម្មណាមួយដែលអ្នកកើតមានកង្វល់ សូមទាក់ទងជាមួយវេជ្ជបណ្ឌិតក្នុងតំបន់អ្នក។**

NSW GOVERNMENT




Khmer

# ការយល់ព្រមដើម្បីទទួលការចាក់វ៉ាក់សាំងគ្រុនស្វិតដៃជើង

NSW GOVERNMENT

ត្រូវបំពេញដោយឪពុក ឬម្ដាយ/អាណាព្យាបាល។ សូមសរសេរជា**អក្សរពុម្ព**ដោយប្រើប៊ិចពណ៌**ខ្មៅ** ឬ**ខៀវ**។

## 1. ព័ត៌មានលម្អិតរបស់សិស្ស

នាមត្រកូល

នាមខ្លួន

ថ្ងៃខែឆ្នាំកំណើត  __ __ / __ __ / 2 0 __ __

ភេទ ☐ ប្រ ☐ ស្រ ☐ មិនជាក់លាក់/អន្តរភេទ/មិនបានបញ្ជាក់

ថ្នាក់រៀន

ឈ្មោះសាលារៀន

លេខមេឌីឃែរ

☐ លេខនៅក្បែរឈ្មោះកូនរបស់អ្នកនៅលើប័ណ្ណមេឌីឃែរ

## 2. ស្ថានភាពជាជនជាតិដើម

☐ ទេ ☐ បាទ/ចាស ជនជាតិដើម ☐ បាទ/ចាស អ្នកកោះ Torres Strait ☐ បាទ/ចាស ជនជាតិដើម និងអ្នកកោះ Torres Strait

## 3. ព័ត៌មានលម្អិតរបស់អ្នក – ឪពុក ឬម្ដាយ/អាណាព្យាបាល

ខ្ញុំបានអាន ហើយយល់ដឹងអំពីព័ត៌មានដែលផ្ដល់ ទាក់ទិននឹងគុណប្រយោជន៍ និងផលប៉ះពាល់បន្ទាប់បន្សំដែលអាចកើតមានពីវ៉ាក់សាំងគ្រុនស្វិតដៃជើង។

តាមរយៈនេះ ខ្ញុំសូមផ្ដល់ការយល់ព្រមឱ្យកូនរបស់ខ្ញុំ ដូចមានឈ្មោះខាងលើ ទទួលការចាក់ពីរដូសនៃវ៉ាក់សាំងគ្រុនស្វិតដៃជើង។

ខ្ញុំសូមប្រកាស តាមដែលខ្ញុំដឹងជាក់ច្បាស់ថាកូនរបស់ខ្ញុំ៖

1. ពុំដែលមានប្រតិកម្មអាណាហ្វីឡាក់ទិច (ប្រតិកម្មទាស់យ៉ាងធ្ងន់ធ្ងរ) បន្ទាប់ពីចាក់វ៉ាក់សាំងណាមួយឡើយ។
2. មិនមានប្រតិកម្មអាណាហ្វីឡាក់ទិច (ប្រតិកម្មទាស់យ៉ាងធ្ងន់ធ្ងរ) ចំពោះសមាសធាតុវ៉ាក់សាំងណាមួយដែលមានរាយក្នុងសន្លឹកព័ត៌មានសម្រាប់ឪពុកម្ដាយដែលដាក់ភ្ជាប់មកជាមួយទេ។
3. មិនមានផ្ទៃពោះទេ។

ឈ្មោះឪពុក ឬម្ដាយ/អាណាព្យាបាល (ឧទាហរណ៍ JOHN SMITH)

អាសយដ្ឋានផ្ទះ (ឧទាហរណ៍ 5 SMITH LANE)

តំបន់

លេខកូដប្រៃសណីយ៍

លេខទូរសព្ទចល័ត

លេខទូរសព្ទផ្សេងទៀតដែលល្អជាងគេ (មានរួមទាំងលេខតំបន់ ឧទាហរណ៍ 02)

ហត្ថលេខាឪពុក ឬម្ដាយ/អាណាព្យាបាល

✕

ថ្ងៃទី __ __ / __ __ / 2 0 __ __

## កំណត់ត្រានៃការចាក់វ៉ាក់សាំងគ្រុនស្វិតដៃជើង

✍ ត្រូវបំពេញដោយឪពុក ឬម្ដាយ/អាណាព្យាបាល

**ឈ្មោះសិស្ស** (ឧទាហរណ៍ JANE SMITH)

សម្រាប់ការិយាល័យប្រើប៉ុណ្ណោះ

ដូសទី 1

**ដៃ** ☐ ឆ្វេង ☐ ស្ដាំ

ម៉ោងចាក់វ៉ាក់សាំង (24 ម៉ោង)

លេខក្រុមវ៉ាក់សាំង

ហត្ថលេខារបស់គិលានុបដ្ឋាក

×

ថ្ងៃទី __ __ / __ __ 2 0 __ __

ដូសទី 2

**ដៃ** ☐ ឆ្វេង ☐ ស្ដាំ

ម៉ោងចាក់វ៉ាក់សាំង (24 ម៉ោង)

លេខក្រុមវ៉ាក់សាំង

ហត្ថលេខារបស់គិលានុបដ្ឋាក

×

ថ្ងៃទី __ __ / __ __ 2 0 __ __

**កំណត់ចំណាំរបស់គិលានុបដ្ឋាក**

មូលហេតុមិនបានចាក់ថ្នាំ

- ☐ អវត្តមាន
- ☐ បដិសេធ
- ☐ មិនស្រួលខ្លួន
- ☐ ពុំមានហត្ថលេខា
- ☐ ដកចេញការយល់ព្រម
- ☐ ផ្សេងទៀត

## ឪពុក ឬម្ដាយ/អាណាព្យាបាល
## កំណត់ត្រានៃការចាក់វ៉ាក់សាំងគ្រុនស្វិតដៃជើង

### កំណត់ត្រានៃការចាក់វ៉ាក់សាំងគ្រុនស្វិតដៃជើង — ដូសទី 1

✍ ត្រូវបំពេញដោយឪពុក ឬម្ដាយ/អាណាព្យាបាល

**ឈ្មោះសិស្ស** (ឧទាហរណ៍ JANE SMITH)

សម្រាប់ការិយាល័យប្រើប៉ុណ្ណោះ

**ដៃ** ☐ ឆ្វេង ☐ ស្ដាំ

ម៉ោងចាក់វ៉ាក់សាំង (24 ម៉ោង) __ __ : __ __

លេខក្រុមវ៉ាក់សាំង

ហត្ថលេខារបស់គិលានុបដ្ឋាក

×

ថ្ងៃទី __ __ / __ __ 2 0 __ __

### កំណត់ត្រានៃការចាក់វ៉ាក់សាំងគ្រុនស្វិតដៃជើង — ដូសទី 2

✍ ត្រូវបំពេញដោយឪពុក ឬម្ដាយ/អាណាព្យាបាល

**ឈ្មោះសិស្ស** (ឧទាហរណ៍ JANE SMITH)

សម្រាប់ការិយាល័យប្រើប៉ុណ្ណោះ

**ដៃ** ☐ ឆ្វេង ☐ ស្ដាំ

ម៉ោងចាក់វ៉ាក់សាំង (24 ម៉ោង) __ __ : __ __

លេខក្រុមវ៉ាក់សាំង

ហត្ថលេខារបស់គិលានុបដ្ឋាក

×

ថ្ងៃទី __ __ / __ __ 2 0 __ __

# សេចក្ដីថ្លែងអំពីឯកជនភាព

## កាតព្វកិច្ចរបស់យើង

យើងប្ដូរផ្ដាច់ដើម្បីចាត់ទុកព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកស្របតាមច្បាប់ឯកជនភាព។

សេចក្ដីថ្លែងនេះពន្យល់ពីរបៀប និងហេតុផលដែលយើងប្រមូលព័ត៌មានផ្ទាល់ខ្លួនអំពីអ្នក និងកូនរបស់អ្នក របៀបដែលអ្នកទទួលបានព័ត៌មានរបស់អ្នក និងរបៀបដែលគេអាចប្រើប្រាស់ព័ត៌មានរបស់អ្នកនៅក្នុងវង្វង់សេវាសុខភាពសាធារណៈរដ្ឋញូវសៅវែល ឬលាតត្រដាងទៅឱ្យភាគីដទៃទៀត។ ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក រួមមានព័ត៌មានលម្អិតអំពីអ្នក និងកូនរបស់អ្នក និងព័ត៌មានសុខភាពផ្ទាល់ខ្លួនទាក់ទិននឹងការចាក់ថ្នាំបង្ការរោគរបស់កូនអ្នក។

## ការប្រមូលព័ត៌មាន

យើងប្រមូលព័ត៌មានផ្ទាល់ខ្លួន ដើម្បីឱ្យយើងមានលទ្ធភាពផ្ដល់កិច្ចបំរើចាក់ថ្នាំបង្ការរោគដែលសមស្របសម្រាប់កូនរបស់អ្នក។

យើងប្រមូលព័ត៌មានដែលទាក់ទិន ហើយចាំបាច់សម្រាប់ការចាក់ថ្នាំបង្ការរោគរបស់កូនអ្នក ហើយដើម្បីចាត់ចែងសេវាកម្មចាក់ថ្នាំបង្ការរោគប៉ុណ្ណោះ។

យើងប្រមូលព័ត៌មានពីអ្នកដោយផ្ទាល់ នៅទីណាដែលអាចធ្វើទៅបាន។ យើងប្រហែលជាចាំបាច់ត្រូវប្រមូលព័ត៌មានសាលារៀនរបស់កូនអ្នក និងអ្នកវិជ្ជាជីវៈផ្នែកសុខភាពឯទៀតដែលបានព្យាបាលកូនរបស់អ្នក។ នៅក្នុងគ្រាអាសន្នណាមួយ យើងប្រហែលជាចាំបាច់ត្រូវប្រមូលព័ត៌មានពីសមាជិកណាម្នាក់ក្នុងក្រុមគ្រួសារ មិត្តភ័ក្តិ អ្នកថែទាំ ឬក៏ជនដទៃផ្សេងទៀត ដែលអាចជួយយើងក្នុងការផ្ដល់ការមើលថែសុខភាពដ៏គាប់ប្រសើរបំផុតចំពោះកូនរបស់អ្នក។

## សន្តិសុខនៃព័ត៌មានដែលបានប្រមូល

ព័ត៌មានផ្ទាល់ខ្លួនអាចត្រូវបានរក្សាទុកក្នុងលំនាំផ្សេងៗគ្នា។ ភាគច្រើនទូទៅ ព័ត៌មានអាចត្រូវបានរក្សាទុកជាកំណត់ត្រាក្រដាសស្នាមពេទ្យ និង/ឬកំណត់ត្រាពេទ្យតាមបែបអេឡិកត្រូនិកពេទ្យ ដែលបង្កើតផ្នែកនៃទិន្នន័យកុមព្យូទ័រដែលមានសន្តិសុខ។ យើងចាប់យកវិន័យ និងគោលការណ៍យ៉ាងតឹងរ៉ឹងទាក់ទិននឹងព័ត៌មានគ្រប់បែបយ៉ាងដើម្បីធ្វើឱ្យប្រាកដថាព័ត៌មានអំពីអ្នករួចផុតពីការបាត់បង់ ការបើកមើលដោយគ្មានការអនុញ្ញាត និងការប្រើប្រាស់ខុស។

## ការប្រើប្រាស់ និងការលាតត្រដាងព័ត៌មាន

ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក ឬរបស់កូនអ្នកអាចត្រូវបានប្រើប្រាស់ដោយសេវាកម្មសុខភាពសាធារណៈរដ្ឋញូវសៅវែល ឬត្រូវបានលាតត្រដាងនៅក្រៅសេវាកម្មសុខភាពដើម្បីផ្ដល់ការថែទាំ និងការព្យាបាលសមរម្យដែលត្រូវផ្ដល់ជូនអ្នក។ ឧទាហរណ៍ ព័ត៌មានរបស់អ្នកអាចត្រូវបានប្រើប្រាស់ ឬលាតត្រដាងទៅឱ្យវេជ្ជបណ្ឌិតព្យាបាលរោគទូទៅរបស់អ្នក ទៅឱ្យវេជ្ជបណ្ឌិតព្យាបាលរោគទូទៅរបស់កូនអ្នក ទៅឱ្យសេវាកម្មសុខភាព ឬមន្ទីរពេទ្យដែលកំពុងព្យាបាលមួយផ្សេងទៀត ទៅឱ្យសេវាកម្មឡានពេទ្យរដ្ឋញូវសៅវែល ទៅឱ្យគ្រូពេទ្យឯកទេសសម្រាប់ការបញ្ជូនឬការធ្វើតេស្តជំងឺ។ ព័ត៌មានផ្ទាល់ខ្លួនក៏អាចត្រូវបានប្រើប្រាស់ ឬលាតត្រដាងផងដែរសម្រាប់គោលបំណងទាក់ទិននឹងប្រតិបត្តិការនៃសេវាកម្មសុខភាពរដ្ឋញូវសៅវែល និងការព្យាបាលអ្នកជំងឺរបស់យើង រួមមានការផ្ដល់មូលនិធិ ការរៀបផែនការ សកម្មភាពកែលម្អសុវត្ថិភាព និងគុណភាព។

ព័ត៌មានផ្ទាល់ខ្លួនត្រូវតែបានលាតត្រដាងទៅភ្នាក់ងាររដ្ឋាភិបាលរដ្ឋ និងសហព័ន្ធ ដើម្បីអនុលោមតាមច្បាប់ទាក់ទិននឹងការធ្វើរបាយការណ៍ ពីជំងឺដែលតម្រូវឱ្យរាយការណ៍ ដើម្បីផ្តល់ព័ត៌មានលម្អិតអំពីមេឌីឃែរ និងស្ថិតិស្តីពីការចាក់ថ្នាំបង្ការរោគ។

យើងក៏អាចប្រើព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកផងដែរ ដើម្បីទាក់ទងមកអ្នក ទាក់ទិននឹងការស្ទង់មតិលើការពេញចិត្តរបស់អតិថិជន និងដើម្បីតាមដានសុវត្ថិភាពវ៉ាក់សាំង។ ការចូលរួមគឺជាការស្ម័គ្រចិត្ត ហើយការមិនចូលរួមពុំមានផលប៉ះពាល់ដល់ការថែទាំសុខភាពដែលបានផ្តល់ឡើយ។

## សិទ្ធិចូលប្រើប្រាស់ព័ត៌មានរបស់អ្នក

អ្នកមានសិទ្ធិសំណូមពរសុំព័ត៌មានផ្ទាល់ខ្លួនទាំងអស់របស់អ្នកដែលយើងរក្សាទុក ហើយនឹងកំណត់ត្រាពេទ្យឯទៀតរបស់កូនអ្នក។ គេអាចគិតថ្លៃអ្នក ប្រសិនបើអ្នកស្នើសុំច្បាប់ចម្លងនៃព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក ឬកំណត់ត្រាផ្នែកពេទ្យ។

## ព័ត៌មានបន្ថែម និងដើម្បីទាក់ទងមកយើង

សម្រាប់ព័ត៌មានបន្ថែម អំពីរបៀបដែលព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកត្រូវបានគ្រប់គ្រង សូមមើលសៀវភៅណែនាំអំពីឯកជនភាពរបស់ NSW Health (ក្រសួងសុខាភិបាល រដ្ឋញូវសៅវែល) សម្រាប់ព័ត៌មានអំពីសុខភាព៖ www.health.nsw.gov.au/patients/privacy

ប្រសិនបើអ្នកមានសំណួរទាំងឡាយ ឬបណ្តឹងតវ៉ាអំពីឯកជនភាពនៃព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក សូមទាក់ទងមកអង្គភាពសុខភាពសាធារណៈក្នុងតំបន់របស់អ្នក តាមទូរសព្ទលេខ 1300 066 055។

October 2022 © NSW Health. SHPN (HP NSW) 220726-P-13